ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៨ លេខ ១ ខែមករា

ព.ស. ២៥០១ គ.ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


បញ្ជីរឿង


ផ្នែកសាសនា ... ទំព័រ

- បណ្ឌិតកថា របស់ព្រះមហា អ៊ុក-អ៊ីន . . . . . . . . . . . . ១
- អាភាកថា របស់ភិក្ខុ កែវ-សារឿន . . . . . . . . . . . ១៥
- រឿងវិទូឧភ: របស់ព្រះមហា ឌៀក-អម៌ . . . . . . . . . . . . ២៧

ផ្នែកអក្សរសាស្ត្រ

- ច្បាប់ស្រីព្រះរាជនិពន្ធដោយព្រះបាទអង្គឌួង លោកបាប-ពិន ពិនិត្យ . . . . . ៣៩
- រឿងបព្វសិទ្ធិ របស់ ហ្វ៊ិនភ៏ីអក្សរ តន់ លោក ប៊ូ-អ៊ី ចំឡងពីសាស្ត្រាស្លឹករឹត . . ៥៣
- ទំនៀមបេះក្រវិញ អ្នកស្រី ពេជ-សល់ រៀបរៀង . . . . . . . . . ៦២
- សុភាសិតជាតិស៊ីវ៉ីនឹងល័បង់ លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង . . . . . . . ៦៦
- រឿងសាមក្ក (តមក) ឧកញ៉ា ត្វ-កន ប្រែ. . . . . . . . . . ៧៦
- រឿងនាយឆ្មា លោក លាង-ហាប់-អាន ប្រែរៀបរៀង . . . . . . . ៨៨

ផ្នែកកំណត់ទីប្រវត្តិការណ៍

- អនុស្សាវរីយ៍: មហាសន្និបាតលើកទី ១៥ នៃមន្ត្រីសង្ឃ ស្រី-អ៊ូ រៀបរៀង . . . . ៩៧
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ១១៤



មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ២៣០១០០

# KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :

-Panditakatha par vén. OUK-INN . . . . . . . . . . 1
-Abhakatha par vén. KEO-SARŒUN . . . . . . . . . 15
-Histoire de Vidudabha par vén. DŒUK-AMARA . . . 27

### Partie littéraire :

-Chbap Srey Preah Bat Ang Duong revu et corrigé par M. CHAP-PIN. . . . . . . . . . . . . . . 39
-Histoire de Sabbasiddhi de Phakdei Aksar TAN revue et corrigée par M. BOU-PO . . . . . . . . . . . 53
-La cueillette des cardamomes par Mme PICH-SAL . . . . 62
-Proverbes syriens et libanais traduits par M. RAY-BUC . . 66
-Histoire de Sam Kok (suite) traduite par M. NOU-KAN . . 76
-Légende d'un chat par M. LEANG HAP-AN . . . . . 88

### Notes et Chroniques :

-Quinzième réunion annuelle des dignitaires religieux pour l'année 1959 par M. SREY-OU. . . . . . . . . . . 97
-Dictionnaire Sanskrit-Khmer (suite) par vén. PANG KHAT . . 114

Prix d'abonnement annuel (comprenant 12 numéros): 230ϡ00 .

ផ្នែកសាសនា

# បណ្ឌិតកថា

របស់ព្រះមហា អ៊ុក-អ៊ីន ទេសនាតាមវិទ្យុជាតិថ្ងៃទី ១៦-១១-៥៨

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ពុទ្ធសាសនិកជនទាំងឡាយ !

ថ្ងៃនេះជាថ្ងៃឧបោសថ ដែលពុទ្ធបរិស័ទជាគ្រហស្ថ គួរលះបង់កង្វល់កិច្ចៈ អប់រំឧបោសថសីល ដើម្បីញាំញីរាគៈ ទោសៈ មោហៈ មានៈ ជាដើម ។ ដើម្បីធ្វើឧបោសថឱ្យមានផលច្រើន គួរបំពេញកិច្ចពិសេសតាមកាលគួរ គឺការស្តាប់ធម្មទេសនា ការសាកសួរធម៌ ការហាត់ធ្វើឧបោសថ ។ ឯកាលនេះ ជាកាលគួរស្តាប់ធម្មទេសនា ។

វិទ្យុជាតិ ផ្សាយធម្មទេសនា អំពីបណ្ឌិតកថា ជូនជាសណ្តាប់ចំពោះពុទ្ធបរិស័ទ ដើម្បីនឹងតម្រូវនឹងឧបោសថកាលផង ដើម្បីជួយអប់រំ-ចរិតអធ្យាស្រ័យ នៃមនុស្សជាតិឲ្យឆាកចេញ អំពីពាលភាពមកកាន់បណ្ឌិតភាព តាមន័យនៃពុទ្ធវចនៈផង ។

ព្រះពុទ្ធជាបណ្ឌិតឯកខាងសទ្ធិភាព ឥតមានអាមិស មានការពិសោធន៍គ្រប់គ្រាន់ ទ្រង់ណែនាំពួកសត្វឲ្យលះបង់អំពើពាល ដែលបណ្ដាលឲ្យកើតទុក្ខទោស ភ័យ អន្តរាយ ឧបសគ្គ គ្រោះថ្នាក់ ឧបទ្រពអពមង្គលគ្រប់ប្រការ ឲ្យខំសង្វាតបំពេញអំពើបណ្ឌិត ដែលប្រព្រឹត្តទៅដើម្បីសុខសួស្ដី សិរីមង្គលគ្រប់យ៉ាង បានខាងសុខមនុស្ស សុខសួគ៌ សុខនិព្វានគ្មានគង្វល់វល់ទីងកើតចាស់ស្លាប់ដាអវសាន ទ្រង់ទូន្មានបុគ្គលដែលជាពាល ឲ្យប្រញាប់ប្រញាល់ឆ្លៃខ្លួនឲ្យជាបណ្ឌិត ទ្រង់ឲ្យខំរៀនបន្ថែមដល់បណ្ឌិតឲ្យរឹតតែកាន់ភាពបណ្ឌិតល្អឡើង ៗ

សឹងមានព្រះពុទ្ធភាសិតពីរគាថាក្នុងធម្មបទ បណ្ឌិតវគ្គ ដែលមានអត្ថន័យសំដែងអំពីបណ្ឌិត និងធម៌របស់បណ្ឌិតជាទិទស្សន៍ថា :

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ៗ

បណ្ឌិតចេញចាកអាល័យ អាស្រ័យនិព្វាន ឥតអាល័យ គប្បីលះឲ្យស្រឡះនូវធម៌ខ្មៅ គប្បីចំរើននូវធម៌ស បណ្ឌិតលះបង់ នូវកាមទាំងឡាយ

អស់គន្លង់ គប្បីប្រាថ្នានូវសេចក្ដីត្រេកអរក្រៃលែងក្នុងវិវេក ដែលសត្វកម្រត្រេកអរបាន គប្បីញុំាងខ្លួនឲ្យស្អាតផូរផង់ ចាកធម៌ទាំងឡាយជាគ្រឿងសៅហ្មងចិត្ត ។

## សេចក្ដីអធិប្បាយ :

ពាក្យថា «បណ្ឌិត» បានសេចក្ដីថា អ្នកប្រព្រឹត្តទៅដោយបញ្ញា ដោយញាណគតិអ្នកប្រកបដោយបញ្ញាស្អាត អ្នកប្រាជ្ញ អ្នកមានប្រាជ្ញា អ្នកចេះដឹង អ្នកចេះសំដែងសេចក្ដីឲ្យច្បាស់លាស់ អ្នកចេះវែកញែកបើកបង្ហាញសំដែងពន្យល់ ឲ្យងាយយល់នូវអាថ៌ធម៌ អ្នកឈ្លាស អ្នកប៉ិនប្រសប់ អ្នកវាងវៃមានប្រាជ្ញាវីងប៉ុន អ្នកមានប្រាជ្ញាខ្ជាប់ខ្ជួន អ្នកមានប្រាជ្ញាកាប់ក្ដា អ្នកចេះលៃលក អ្នកមានញាណ អ្នកមានមតិល្អ អ្នកមានឧត្ដមគតិ អ្នកចេះថែខ្លួន អ្នកអប់រំខ្លួនដោយសុចរិត ។

ពាក្យថា ចេញចាកអាល័យ អាស្រ័យនូវព្រះនិព្វានគ្មានអាល័យ បានសេចក្ដីថា ចេញចាកលំនៅគឺ ឃរាវាសធម៌ ជាលំនៅតណ្ហា ជាបំណងមារ ជាគ្រឿងអាល្ពះអាល័យរបស់ចិត្ត ដែលធ្លាប់ជក់ត្រាំ លះគេហគ្រហស្ថទាំងអស់ហើយនាំយកព្រះនិព្វាន ដែលចេញផុតអាល័យ គឺតណ្ហាឲ្យជាអារម្មណ៍ ហើយបំពេញនេក្ខម្មក្នុងសាសនា ។

ពាក្យថា គប្បីលះបង់ឲ្យស្រឡះនូវធម៌ខ្មៅ បានសេចក្ដីថា កាលបាន

បួសហើយ គួរលះបង់នូវអកុសលទាំងអស់ មានទុច្ចរិតជាដើម ហើយបំពេញចតុប្បារិសុទ្ធិសីលឲ្យផូរផង់ឲ្យស្អាត ឲ្យបរិបូណ៌ជាអបរិមាណ ។

ពាក្យថា គប្បីចំរើននូវធម៌ស បានសេចក្តីថា គួរប្រឹងប្រែងព្យាយាមតាំងសម្មប្បធាន ៤ ឲ្យម៉ឺងម៉ាត់ទាំងឥទ្ធិបាទ ៤ ឲ្យរឹងប៉ឹង បំពេញនូវកុសលធម៌ទាំងអស់ មានសុចរិតជាដើមឲ្យបានចំរើន ធ្វើសមាធិចិត្តឲ្យមាំមួនដរាបដល់បានអរហត្តមគ្គ ។

ពាក្យថា លះបង់នូវកាមទាំងឡាយឲ្យអស់កង្វល់ បានសេចក្តីថា លះបង់ ផ្តាច់បង់ រំលើងចោលនូវកាមពីរយ៉ាងគឺ វត្ថុកាម បានដល់កាមគុណារម្មណ៍ ៥ ឧបភោគបរិភោគវត្ថុ សវិញ្ញាណកាវិញ្ញាណកវត្ថុ ។ កិលេសកាម បានដល់ឆន្ទៈ រាគៈ សង្កប្បៈ តណ្ហា ស្នេហៈ មុច្ឆា អជ្ឈោសានៈ លោភៈ ឧបាទានៈ ចំពោះវត្ថុកាមនោះ ហើយអស់មានការរវល់ខ្វល់ស្មុគ្រស្មាញ ព្រោះកង្វល់គឺ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ នៅជាស្រួល ។

ពាក្យថា គប្បីប្រាថ្នានូវសេចក្តីត្រេកអរក្រៃលែងក្នុងវិវេក ដែលពួកសត្វកម្រត្រេកអរកេ បានសេចក្តីថា បន្ទាប់មក ចង់បាននូវសេចក្តីរីករាយស្រោះស្រាយ កន្លងនូវសេចក្តីរីករាយប្រកបដោយអាមិស ក្នុងព្រះនិព្វានដ៏ស្ងប់ស្ងាត់ចាកកិលេស ខន្ធ អភិសង្ខារ បានដោយងាយ ព្រោះសេចក្តីត្រេកអររីករាយបែបនេះ ពួកសត្វដែលត្រូវកាមទឹកកង្វល់រួបរឹតជិះ

ជាន់ញាំញីជានិច្ច កុំបានឱកាសត្រេកអរនឹកដល់ទេ ។

ពាក្យថា គប្បីញុំាងខ្លួនឲ្យស្អាតផូរផង់ ចាកធម៌ទាំងឡាយជាគ្រឿងសៅហ្មងចិត្ត បានសេចក្តីថា តមកទៀត គប្បីជុសខាត់អាត្មនគឺចិត្ត ឲ្យរឹតតែផូរផង់ពិសេសជាងនោះទៅទៀត ឲ្យជ្រះលែងអំពីកិលេសរបស់ចិត្ត គឺនីវរណធម៌ ៥ យ៉ាង ។

បណ្ឌិតលោកយកនិព្វានជាអារម្មណ៍ហើយ ឈានទៅកាន់និព្វានដោយនេក្ខម្ម: សីល សមាធិ បញ្ញា ជាបសម្រេចអវសានកិច្ច ។

បណ្ឌិតចែកដោយន័យដំណើរមក ដោយសង្ខេបមាន ៤០ គឺ

១ - សិប្បិយបណ្ឌិត បណ្ឌិតព្រោះស្ទាត់ខាងសិល្ប:មានសិល្ប:ជ្បជាដើម,

២- ឧគ្គណ្ហនបណ្ឌិត បណ្ឌិតព្រោះរៀនបេះគេក្យសាស្ត្រ ធម្មសាស្ត្រ បរិយត្តិជាដើម,

៣- ពាហុសច្ចបណ្ឌិត បណ្ឌិតព្រោះចេះចាំច្រើន រៀនសូត្រស្តាប់ច្រើន,

៤- បណ្ឌិតូបសេវីបណ្ឌិត បណ្ឌិតព្រោះចូលសេពបណ្ឌិតរៀនស្តាប់ជាមួយ,

៥- សុតបណ្ឌិត បណ្ឌិតព្រោះស្តាប់អ្នកប្រាជ្ញសំដែងរឿយៗ,

៦– ចិត្តបណ្ឌិត បណ្ឌិតព្រោះការគិតត្រិះរិះ រាវរក ពិនិត្យ ពិសោធ ល្បង,

៧– ភាវនាបណ្ឌិត បណ្ឌិតព្រោះការចំរើននូវខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ សច្ច,

៨– សជាតិបណ្ឌិត បណ្ឌិតព្រោះមានបញ្ញាពីកំណើត ដែលកើតអំពីឆ្លាប់គប់រ,

៩– អត្តវិមោចនបណ្ឌិត បណ្ឌិតព្រោះចេះដោះខ្លួនឲ្យរួចអំពីឧបសគ្គ កណ្ដាប់ដៃសត្រូវ,

១០– ឧបាយកោសល្លបណ្ឌិត បណ្ឌិតព្រោះឈ្លាសក្នុងឧបាយសព្វគ្រប់,

១១– ការណាការណជានបណ្ឌិត បណ្ឌិតព្រោះស្គាល់ហេតុតូច-ធំ គួរមិនគួរ,

១២–លោកវត្តជានបណ្ឌិត បណ្ឌិតព្រោះចេះស្គាល់វត្តទំនៀមលោក ប្រើឫកពាសមតាម,

១៣– កាលវិចក្ខណាបណ្ឌិត បណ្ឌិតព្រោះប្រសប់ទុកដាក់ខ្លួនតាមកាលៈទេសៈ,

១៤-បញ្ញាវិសុទ្ធិនបណ្ឌិត បណ្ឌិតព្រោះវាងវៃក្នុងការដោះស្រាយបញ្ហា,

១៥-ធនសញ្ចយបណ្ឌិត បណ្ឌិតព្រោះចេះដំកើងខ្លួនដោយសន្សំទ្រព្យឲ្យមាន,

១៦-ឃរាវាសបណ្ឌិត បណ្ឌិតព្រោះគ្រប់គ្រងផ្ទះ តាមប្រយោជន៍ទាំងក្នុងនិងក្រៅ,

១៧-អជ្ឈាសយគ្គាហណបណ្ឌិត បណ្ឌិតព្រោះចេះតម្រូវអធ្យាស្រ័យ បុគ្គល បរិស័ទ,

១៨-កតញ្ញូកតវេទិបណ្ឌិត បណ្ឌិតព្រោះដឹងគុណគេ ហើយធ្វើតបវិញ,

១៩-សង្គហបណ្ឌិត បណ្ឌិតព្រោះចេះសង្គ្រោះដោយទាន សំដីផ្អែម ប្រយោជន៍ស្មោះស្មើ,

២០ អត្តប្បដិជិគ្គនបណ្ឌិត បណ្ឌិតព្រោះចេះថែទាំខ្លួនដោយល្អ ប្រាសចាកអកុសល,

២១-បដិរូបនិវាសនបណ្ឌិត បណ្ឌិតព្រោះចេះដាក់ខ្លួនក្នុងគុណដ៏សមគួរ,

២២_កល្យាណបណ្ឌិត បណ្ឌិតព្រោះមានកល្យាណកម្ម អំពើល្អជាទីគាប់ចិត្ត,

២៣_មលនិទ្ធមបណ្ឌិត បណ្ឌិតព្រោះព្យាយាមកំចាត់មន្ទិល ដោយបំពេញកុសល,

២៤-បុញ្ញឧប្ចយបណ្ឌិត បណ្ឌិតព្រោះចេះសន្សំបុណ្យ បន្តិចម្តងៗ

២៥-បរិច្ចាគបណ្ឌិត បណ្ឌិតព្រោះលះកំណាញ់បំពេញទាន,

២៦_សីលបណ្ឌិត បណ្ឌិតព្រោះមានសីល ៥-៨-១០-៤,

២៧_បញ្ញាបណ្ឌិត បណ្ឌិតព្រោះមានបញ្ញាដឹងនូវទុក្ខ ហេតុទុក្ខ ការរលត់ទុក្ខ ហេតុរលត់ទុក្ខ,

២៨_ពុទ្ធិបណ្ឌិត បណ្ឌិតព្រោះត្រាស់ដឹងនូវសច្ចៈ ហើយឲ្យគេត្រាស់ដឹងផង,

២៩_អនុពុទ្ធិបណ្ឌិត បណ្ឌិតព្រោះត្រាស់ដឹងនូវសច្ចៈតាមក្រោយ,

៣០-ខន្តិបណ្ឌិត បណ្ឌិតព្រោះចេះអត់ធន់នឹងសភាវធម៌ ធម្មជាតិ អន្តរាយ,

៣១- វីរិយបណ្ឌិត បណ្ឌិតព្រោះព្យាយាមកំចាត់កំលេស អកុសលលាមក,

៣២- អវេរបណ្ឌិត បណ្ឌិតព្រោះមិនមានពៀរភ័យរវាងខ្លួននឹងអ្នកដទៃ,

៣៣- សមចរិយាបណ្ឌិត បណ្ឌិតព្រោះការប្រព្រឹត្តស្មើដោយកាយ វាចា ចិត្ត,

៣៤- មោនបណ្ឌិត បណ្ឌិតព្រោះការដឹងនូវលោក ព្រោះស្ងៀមចាកអកុសល,

៣៥- បច្ចវេក្ខណបណ្ឌិត បណ្ឌិតព្រោះពិចារណាឃើញត្រកូលវ័យជាដើម វៀរចាកអកុសល,

៣៦- អត្ថគ្គហណបណ្ឌិត បណ្ឌិតព្រោះមានបញ្ញាចក្ខុកាន់យកនូវប្រយោជន៍ទាំងពីរ,

៣៧- អត្ថបរហិតបណ្ឌិត បណ្ឌិតព្រោះធ្វើប្រយោជន៍ឲ្យខ្លួនផងឲ្យអ្នកដទៃផង,

៣៨- សុខីករណបណ្ឌិត បណ្ឌិតព្រោះធ្វើខ្លួនឲ្យបានស្រួលឲ្យសុខសាន្ត,

៣៩- អត្ថវិសោធនបណ្ឌិត បណ្ឌិតព្រោះការធ្វើខ្លួនឲ្យបាន ចំរើនល្អ ចេះ,

៤០- កាមាទីនវទស្សនបណ្ឌិត បណ្ឌិតព្រោះការឃើញទោស កាមគុណារម្មណ៍ ។

បណ្ឌិតទាំងនេះ មានសទិសភាពតែមួយ ដោយលក្ខណៈ ៣ គឺ ការធ្វើល្អ ការនិយាយស្តីល្អ ការគិតល្អ ៗ បំប្រួញមកនៅត្រឹម ៣ គឺ

១- សយម្ភូបណ្ឌិត បណ្ឌិតចេះ ដឹងឯង ដោយផលបារមីធម៌,

២- អនុបណ្ឌិត បណ្ឌិតចេះដឹង តាមសយម្ភូបណ្ឌិត,

៣- ពីជបណ្ឌិត បណ្ឌិតដែលមានពូជជាតិបណ្ឌិតក្នុងខ្លួន ។

ក្នុងទីនេះ គួរយកពីជបណ្ឌិតជាប្រមាណ ព្រោះជាទានដើម ។

ក្នុងលោកនេះ បុគ្គលដែលបានកើតជាមនុស្សហើយ បានជាបណ្ឌិត តែម្តង. កម្រមានណាស់ ប៉ុន្តែ បុគ្គលដែលមិនក្លាយជាបណ្ឌិតសោះនោះ មិនមានទេ បើទុកជាបុគ្គលនោះ កាន់អំពើពាលយ៉ាងណាក៏ដោយ គង់អាចធ្វើខ្លួនបាន ដោយការសេពគប់បណ្ឌិត ព្យាយាមជាដើម ព្រោះក្នុង សន្តានរបស់គេ តែងតែមានពូជជាតិបណ្ឌិតបិតនៅ ដូចជាធាតុថ្នាំតែងតែ មានក្នុងទឹកជ្រាំ ឬដូចជាតិសៅផ្អែមតែងតែមានក្នុងផ្លែស្វាយខ្ចី ឬក៏ដូចពូជ ឈូកមាននៅក្នុងស្រះរឺងទឹកក្នុងគម្ពរជ្រៅ ៗ ដូច្នេះ មនុស្សឈ្មោះថាបណ្ឌិត

ដោយពូជជាតិបណ្ឌិត ។ ពូជជាតិបណ្ឌិតនេះនឹងដុះដាលឡើង ដោយការរៀន ដោយការសេពគប់បណ្ឌិតកល្យាណមិត្ត ដោយព្យាយាមជាដើម ដូចពូជឈើនៅក្នុងស្រែ តែងតែដុះក្នុងពេលមានទឹក ក្នុងវស្សានរដូវ ដូច្នោះ បើពុំដូច្នោះទេ មិនលូតលាស់ ដើម្បីបណ្ឌិតភាពឡើយ ដូចពូជឈើមិនដុះក្នុងស្រែ ឥតទឹកដូច្នោះ ។

បុគ្គលជាពីជបណ្ឌិត អាចដើម្បីនាំខ្លួនឲ្យជាសយម្ភូបណ្ឌិត ឬ អនុបណ្ឌិតបាន ដោយព្យាយាមបណ្ដុះពូជបណ្ឌិត ដោយឧដ្ឋានៈ អប្បមាទ សញ្ញមៈ ទមៈ ដោយការសេពគប់សប្បុរស ដោយការមមាំខ្លួនក្នុងការរៀន វិជ្ជាស្ថាន វិទ្យាល័យ ដោយការនៅក្នុងសំណាក់អាចារ្យចេះច្រើន មានការពិសោធន៍ច្រើន មានសីលាចារៈសមរម្យស្រគត់ស្រគំ ដោយការស្ដាប់ គិត ពិចារណា ដោយការលះបង់ចិត្ត គំនិត ចរិត អធ្យាស្រ័យអាក្រក់ ដោយ[illegible]បន្តិចម្ដងៗ ដោយការជឿនឹងគ្រូ ទទួលសុភាសិតប្រដៅងាយ ដោយទាន សីល ព្រហ្មវិហារ ។

ពីជបណ្ឌិត កាលបានអប់រំខ្លួនយ៉ាងនេះហើយ បានឈ្មោះថាបណ្ដុះពូជបណ្ឌិតឲ្យដុះតាមលំដាប់ យូរៗទៅ មានបញ្ញាចាស់ក្លា មានកំឡាំងក្លៃថ្លា អាចមើលឃើញច្បាស់ នូវត្រៃលោក ដូចគំនរភ្លើងគគីរ ពេញក្នុងពិភព នូវលោកដែលកើតទីនឹងត្រៃលក្ខណ៍ នូវភ្លើងទុក្ខ ភ្លើងកិលេស នូវសង្សារវដ្ដឥតចុងឥតដើម នូវភ័យក្នុងសំសារសាគរដ៏ធំជ្រៅស្រឡូន

ឃើញយករសធម៌ពេញដោយកន្ទួលសាំញ៉ាំ ។ ឃើញទេ ទោសកាម ជាមេអសន្តិសុខ ព្យាបាទ វិហឹសា ជាមេភ្លើង ប្រល័យលោក ដុតពលលោក ឲ្យខ្លោចក្រៀមក្រំសៅហ្មងសោកសៅ ហើយធុញទ្រាន់នឹងលោក នឹងការកើត ចាស់ ឈឺ ស្លាប់ ឃើញច្បាស់នូវអានិសង្សនេក្ខម្មជាក្សេម ឥតកន្ទួល លះបង់គេហគ្រហស្ថទាំងអស់ ថ្វាយជីវិតបួសក្នុងព្រះពុទ្ធសាសនា ប្រាសចាកទុក្ខករណ៍ក្នុងផ្ទះ ។

បណ្ឌិតចេញចាកអាល័យរបស់គ្រហស្ថគឺកាមតណ្ហាហើយ កំដួងចិត្តពោះគោលលើព្រះនិព្វាន ដែលឥតអាល័យឲ្យជាអារម្មណ៍ជាខាងដើម ឲ្យជាទិសម្រាប់ដើរទៅនៃចិត្ត ។ តមក លោកតាំងយកអសុភានុទស្សនៈ សំវរៈ មត្តញ្ញុតា សទ្ធា វីរិយៈ ជាសេនាឯក ហើយតាំងញាំញីមារ លះបង់ឲ្យជ្រះស្រឡះនូវធម៌ខ្មៅ គឺអកុសលធម៌ទាំងអស់ ដែលជាធម៌នាំចិត្តឲ្យខ្មៅ ឲ្យសៅហ្មងល្អក់កករ នាំសត្វទៅកាន់កន្លែងខ្មៅ កំណើតខ្មៅ ឥតសេរីសុខចំរើន ដែលជាធម៌មានឫស ៣ គឺ លោភៈ ទោសៈ មោហៈ បែកទៅមានទុច្ចរិត ៣ ជាដើម ។ តមក លោកព្យាយាមចំរើនធម៌ស គឺកុសលធម៌ទាំងអស់ មានសុចរិតបីជាដើម ដែលជាធម៌ស្អាតបរិសុទ្ធម៉ដ្ឋចត់ផូរផងឥតទោស ជាធម៌នាំចិត្ត ឲ្យសឲ្យភ្លឺថ្លា នាំសត្វទៅកាន់កន្លែងស្អាត កំណើតស្អាត នាំសត្វទៅកាន់និព្វាន ដែលជាកន្លែងស្អាតចាកតណ្ហាមន្ទិលទុក្ខគ្រប់ប្រការ ។ លុះលោកបានចំរើនធម៌សហើយ លោកត្រូវការបង់

បាននូវអភិរតិ សេចក្ដីត្រេកអរដែលកន្លងលែងនូវត្រេកអរជារបស់មនុស្ស ទេវតាទាំងអស់ ក្នុងរវាងគឺអមតនិព្វាន ដែលស្ងប់ស្ងាត់ស្ងួនឡាកចបង គឺកិលេស ១០ អភិសង្ខារ រម្ងាប់សង្ខារទាំងអស់ រលាស់ចោលចប-ងកិលេសទាំងអស់ អស់តណ្ហា ប្រាកបាកតម្រេក រលត់ទុក្ខ អស់កង្វល់ វានវណ្ណ គឺតណ្ហាគ្រឿងជោត ដែលពួកសត្វកំពុងត្រូវអវិជ្ជាបិទបាំងមុខ ក្នុងជិត មិនដែលទឹកឃើញ បន្ធូរកាយសប្បាយសោះ ហើយលោកក៏លះបង់នូវកាមពីរយ៉ាង :

១- វត្ថុកាម អារម្មណ៍របស់ជាទីត្រូវការ ផ្ទាញ់នៃកាមលោក បានដល់អារម្មណ៍ជាទីពេញចិត្ត ៥ គឺ រូប សំឡេង ក្លិន រស សម្ផស្ស បានដល់អវិញ្ញាណកវត្ថុ គឺសំពត់ មាស ប្រាក់ ផ្ទះ ស្រែ ចំការ ស្រុក ដែន លោក សវិញ្ញាណកវត្ថុគឺ ប្រពន្ធ បុត្រ ជីតា ទាសី ទាសា គោ ក្របី ដំរី សេះ ។

២- កិលេសកាម បានដល់សេចក្ដីពេញចិត្ត តម្រេក ជន្ទរាគ តម្រិះរកកាម សេចក្ដីគាប់ចិត្ត សេចក្ដីរីករាយត្រេកត្រអាល អន្ទះសា រសាប់រសល់ជ្រួលក្នុងកាម ការស្និតស្នាមជាប់ក្នុងកាម សេចក្ដីក្ដៅពេល ពលរលាកព្រោះកាម ការជ្រួលជ្រើល ងងុល ល្ងង់ លង់ក្នុងកាម ការគ្រៀក ជាប់ ប្រកាន់ស្អិតក្នុងកាម ការរំពឹងការពារកាម លុះលះហើយ

លោកជាបុគ្គលទំនេរ ស្រាលអស់កង្វល់ អស់អំពល់ចិត្ត ។

លំដាប់ពីនោះ លោកសំអាតខ្លួនលោកឲ្យតែស្អាតចាកកិលេស គឺឲ្យផូរផង់រលីងចាកធម៌ដែលនាំឲ្យសៅហ្មង ធម៌ដែលនាំឲ្យចិត្តសៅហ្មង បានដល់នីវរណធម៌ ៥ យ៉ាងគឺ

១- កាមច្ឆន្ទៈ សេចក្តីពេញចិត្តនឹងកាម,

២- ព្យាបាទៈ សេចក្តីឈ្នានីសបំផ្លិចបំផ្លាញ,

៣- ថីនមិទ្ធៈ សេចក្តីងោកងុយ,

៤- ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីអណ្តែតអណ្តូងរាយមាយ,

៥- វិចិកិច្ឆា សេចក្តីសង្ស័យ មិនអស់ហើយ ។

បណ្ឌិតថ្កត់គោលដៅនឹងព្រះនិព្វានហើយ បានប្រព្រឹត្តធម៌បណ្ឌិត តាំងអំពីថ្នាក់ទាប កណ្តាលរហូតថ្នាក់ទុក្កដ ដើម្បីឲ្យសម្រេចនិព្វាន ក៏បានដល់នូវទីបំផុតនៃគោលដៅ គ្រង់ការអស់អាសវៈជាទីបំផុត ។

## និគមវចនៈ

ពាក្យថា លះបង់នូវធម៌ខ្មៅ គួរចូលគុណសីល ចំរើននូវធម៌ស គួរចូលគុណសមាធិ, ចេញចាកអាល័យ គួរចូលគុណបញ្ញា, លះបង់កាមឥតកង្វល់ គួរចូលគុណបញ្ញា, សំអាតចិត្តឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត គួរចូលគុណបញ្ញា ។

X

X X

# អាភាកថា

របស់ភិក្ខុ កែវ-សារឿន ទេសនាតាមវិទ្យុជាតិពីថ្ងៃទី ៩-៦-៥៨

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះត្រៃរត្ន ដោយគោរព ។

វេលានេះ សូមសំដែងអំពីពាក្យថា "ពន្លឺ" តាមឧគ្ឃោសនស័ព្ទវិទ្យុជាតិកម្ពុជា ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា និងជាវត្តប្រតិបត្តិនៃពុទ្ធសាសនិកជនគ្រប់ជាន់ថ្នាក់ដូចតទៅ :

ពាក្យថា ពន្លឺ មាន ៤ យ៉ាងគឺ

ពន្លឺព្រះអាទិត្យ ១ ពន្លឺព្រះចន្ទ ១

ពន្លឺភ្លើង ១ ពន្លឺប្រាជ្ញា ១ ។

ពន្លឺទាំង ៤ យ៉ាងនេះ សូមអធិប្បាយដូចតទៅ :

១ ពន្លឺព្រះអាទិត្យ សម្រាប់ចុះបំភ្លឺបានតែត្រឹមវេលាថ្ងៃប៉ុណ្ណោះ បើហួសពីវេលាថ្ងៃហើយ កុំសង្ឃឹមថាមានពន្លឺអាចនឹងចុះបំភ្លឺដល់សត្វនិករ ឲ្យប្រកបការងារផ្សេងៗ នោះបានឡើយ ។

២ ពន្លឺព្រះចន្ទក៏ចុះបំភ្លឺបានត្រឹមតែវេលាយប់ប៉ុណ្ណោះ បើហួសពីវេលាយប់ហើយ មិនអាចនឹងបំភ្លឺវត្ថុធម្មជាតិឲ្យភ្លឺស្វាង ដោយសារតែពន្លឺខ្លួនបានឡើយ ។

៣ – ពន្លឺភ្លើង មានប្រទីប ចង្កៀងជាដើម ក្រោលបំភ្លឺបានតែត្រឹម

ព្រំដែនរបស់ខ្លួនប៉ុណ្ណោះ បើផុតពីព្រំដែនរបស់ខ្លួនហើយ ក៏មិនអាចនឹងចុះបញ្ចាំងបំភ្លឺបានទេ ។

បណ្ដាពន្លឺទាំង ៣ ដែលបានសំដែងមកខាងលើនេះ មានអានុភាពអាចចុះបំភ្លឺបាន ចំពោះតែវត្ថុដែលមានខាងក្រៅប៉ុណ្ណោះ មិនអាចចុះបំភ្លឺឲ្យឃើញអាថ៌កំបាំងជ្រៅឆ្ងាយបានទេ គឺចុះក្នុងសន្តានរបស់សត្វលោកឲ្យឃើញឲ្យស្គាល់ថា នេះជាហេតុនៃទុក្ខ នេះជាហេតុនៃសុខ-ជាហេតុនៃវិនាស ចម្រើន ឬថា. ឲ្យស្គាល់គុណ-ទោសបុណ្យបាបដូច្នេះ ពុំបានឡើយ គ្រាន់តែបំភ្លឺឲ្យដឹងពេលយប់ថ្ងៃល្ងាចព្រឹកប៉ុណ្ណោះ ឬថា សម្រាប់ចំអិននូវភោជនាហារ ដែលជួយគាំទ្រជីវភាពឲ្យរស់នៅ ដើម្បីនឹងត្រិះរិះរកពន្លឺឧត្តមវិសេសតទៅទៀត ។

៤-ពន្លឺប្រាជ្ញា ទើបអាចចុះបំភ្លឺឲ្យឃើញនូវហេតុផល នៃសុខ-ទុក្ខ-ចម្រើន-វិនាសបាន ព្រមទាំងមានកម្លាំងអាចចុះបំភ្លឺឲ្យវិសេសជាងពន្លឺដទៃដូចមានពុទ្ធភាសិតថា :

នត្ថិ បញ្ញា សមា អាភា រកពន្លឺអ្វីឲ្យភ្លឺស្មើនឹងពន្លឺប្រាជ្ញានេះគ្មានៗ

បុគ្គលដែលសំអាតចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផុតស្រឡះចាកគ្រឿងសៅហ្មងបាន ក៏ព្រោះប្រាជ្ញា ។ គឺបញ្ញានេះ លោកប្រៀបដូចកែវភ្នែក នរជនអាចគយគន់គុណទោស ដែលជាមេនាំឲ្យមាននៅក្នុងចិត្ត ទោះបីបន្តិចក៏អាចសម្លឹងឃើញច្បាស់លាស់ ហើយចំរើន ឬ លះបង់ចោលចេញ បើទុក

ជាទោសធ្លាប់ប្រឡាក់ប្រឡូសមកពីមុន ព្រោះតែល្ងង់ខ្លៅងងឹត មិនដឹងគុណទោស គឺគង់ត្រឡប់បរិសុទ្ធបាន សមដូចសុភាសិតថា បញ្ញាយ បរិសុជ្ឈតិ បុគ្គលដែលបរិសុទ្ធបាន ដោយសារប្រាជ្ញា ។

បុគ្គលដែលឥតប្រាជ្ញាមិនអាចធ្វើខ្លួនឲ្យមានសិរីជ័យមង្គលបានទេ មានតែជនអ្នកមានប្រាជ្ញា ទើបដឹកលាំខ្លួនឯងនិងអ្នកដទៃឲ្យថ្លៃថ្លាបាន ដូចសុភាសិតថា បញ្ញា ហេ នំ បសាសតិ បញ្ញាតែងរក្សានូវបុរស-ស្ត្រី ។ ព្រោះហេតុនោះ បានជាអ្នកប្រាជ្ញពោលថា ប្រាជ្ញានេះសំខាន់បំផុតក្នុងពេលដែលប្រកបកិច្ចការគ្រប់យ៉ាង ឲ្យបានសម្រេចទាំងអស់ ថែមទាំងអាចដោះខ្លួនឲ្យរួចផុតពីសេចក្តីអន្តរាយដល់ជីវិត បានដោយងាយ ។

ន័យមួយទៀតថា បញ្ញាដែលនឹងកើតមានដល់បុគ្គលណា បុគ្គលនោះត្រូវរកគ្រឿងឧបសម្ភារៈមកជំនួយជួយឧបត្ថម្ភ ឯគ្រឿងជំនួយនោះ បានដល់បញ្ញាវុឌ្ឍិធម៌ ។ បញ្ញាវុឌ្ឍិធម៌មាន ៤ យ៉ាងគឺ

១- សប្បុរិសសំសេវៈ ការចូលទៅសេពគប់សប្បុរស,

២- សទ្ធម្មស្សវនៈ ការស្តាប់ព្រះសទ្ធម្ម,

៣- យោនិសោមនសិការៈ ការធ្វើទុកក្នុងចិត្តដោយឧបាយ,

៤- ធម្មានុធម្មប្បដិបត្តិ ការប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។

ទី១- សេចក្តីឈ្លាសវៃស្ទាត់ជំនាញក្នុងការងារ ព្រមទាំងកិរិយា

មារយាទត្រឹមត្រូវល្អ ទីនឹងបញ្ញាដែលសម្រាប់សង្កេតរកហេតុផល ទីនឹងកើតឡើងបាន គឺមកពីការចូលទៅអង្គុយជិតស្និទ្ធស្នាលគប់ប្រសព្វនឹងលោកអ្នកស្ងប់ស្ងាប់ដោយកាយ-វាចា ចិត្ត ហៅថា "សប្បុរិសូបសំសេវ" ។

ទី ២- បើចូលទៅអង្គុយជិតលោកអ្នកសប្បុរសហើយ កុំគ្រាន់តែនៅជាមួយនោះ ឥតបានសម្រេចគុណប្រយោជន៍អ្វីទេ ត្រូវស្ដាប់ឱវាទរបស់លោកអ្នកសប្បុរស ដែលលោកទូន្មានប្រៀនប្រដៅឱ្យមានរបៀបរៀបរយល្អ ហើយប្រុងស្មារតីចាំស្ដាប់ ចំពោះពាក្យប្រៀនប្រដៅរបស់លោកដោយគោរព ហៅថា "សទ្ធម្មស្សវនៈ" ។

ទី ៣-- បើបុរសស្ត្រីណា បានស្ដាប់ព្រះសទ្ធម្មដោយគោរពហើយ ត្រូវរិះរកហេតុ-ផលឱ្យស្គាល់ល្អ-អាក្រក់ ដោយយោបល់ដ៏ប្រពៃ គឺឱ្យត្រឹមត្រូវតាមគន្លងធម៌ ។

បណ្ដាកិច្ចការគ្រប់ជំពូកក្នុងលោកនេះ ដែលបុគ្គលធ្វើហើយក្ដី កំពុងធ្វើក្ដី ក៏ត្រូវតែមានយោនិសោមនសិការៈ គឺយកចិត្តទុកដាក់ក្នុងកិច្ចការនោះ ៗ ទើបអាចសម្រេចទៅបាន បើមិនដូច្នេះទេ បញ្ញា ក៏មិនកើតមានឡើយ សមដូចពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយថា នត្ថិ បញ្ញា អយោ-និសោ បុគ្គលដែលមិនរំពឹងពិនិត្យល្បងមើល មិនដែលមានបញ្ញាឡើយ ។ ហេតុនោះ លុះត្រាតែស្ទង់មើលពិនិត្យពិច័យឲ្យច្បាស់លាស់ទើបកើតបញ្ញាដ៏ក្លាហានបាន ។

កាលបើសិក្ខាកាម កុមារ កុមារីទាំងឡាយមានប្រាថ្នានឹងសិក្សាវិជ្ជាផ្លូវលោក ផ្លូវធម៌ណាមួយ ក៏ត្រូវប្រើគំនិតគិតតាមពាក្យប្រដៅ ស្តាប់ពាក្យរបស់លោក ព្រោះថា ពាក្យប្រៀនប្រដៅនេះ ជាមេគំនិតមួយយ៉ាងសំខាន់បំផុត នាំឲ្យកើតបញ្ញាសេចក្តីចេះដឹងភ្លឺស្វាងឡើងបាន សមដូចសុភាសិតថា សុតមយេ បញ្ញា ប្រាជ្ញាកើតឡើងដោយសារការស្តាប់ ។

ព្រោះហេតុនោះ ការដែលត្រិះរិះដោយឧបាយដ៏ប្រពៃនេះ អ្នកប្រាជ្ញទ្រង់ទាត់ថា គុណធម៌ជាគ្រឿងចំរើនបញ្ញា ដ៏សំខាន់បំផុត នេះហៅថា "យោនិសោមនសិការៈ" ។

ទី ៤- បើបានត្រិះរិះ ដោយឧបាយល្អប្រពៃតាមគន្លងធម៌ហើយ ត្រូវប្រតិបត្តិឲ្យសមគួរដល់ធម៌នោះ ៗ ទើបបានជួបប្រទះនឹងសេចក្តីសុខ-ចំរើន តាមសមគួរដល់សេចក្តីប្រតិបត្តិរបស់ខ្លួន ។ មួយវិញទៀត បុគ្គលបញ្ញាខ្លះ ប្រព្រឹត្តធម៌នឹងគេដែរ តែមិនបានជួបប្រទះនឹងសេចក្តីសុខ-ចំរើនដ៏បរិបូណ៌សោះ មកពីការប្រព្រឹត្តធម៌ មិនទាន់សមគួរដល់ធម៌ គឺប្រព្រឹត្តច្រឡំច្រាស ហេតុដាក់ការចេះដឹងរបស់ខ្លួនខុសក៏មាន ខ្វះឧបាយដាក់ការចេះដឹងក៏មាន បានជាមិនជួបប្រទះនឹងសេចក្តីសុខ-ចំរើន ដែលជាកម្រៃនៃសេចក្តីប្រតិបត្តិ ដោយត្រឹមត្រូវនោះ ៗ លុះណាតែប្រតិបត្តិធម៌ឲ្យសមគួរដល់ធម៌នោះ ទើបប្រយោជន៍សព្វយ៉ាងសម្រេចទៅបាន នេះហៅថា "ធម្មានុធម្មប្បដិបត្តិ" ។

ឯពទ្ធីពោលគឺបញ្ញានេះ មិនមែនមានតែក្នុងសន្តានបុរសទេ សូម្បីជាស្ត្រីក៏ដោយ គង់មានបញ្ញាដែរ ដូចសុភាសិតក្នុងគម្ពីរខុទ្ទកនិកាយថា

ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។

បុរសមិនមែនឈ្មោះថាជាបណ្ឌិត ក្នុងទីទាំងពួងទេ ទោះ
បីជាស្ត្រីក៏ដោយ ឲ្យតែមានសេចក្តីភាន់វៃ ក៏គង់ឈ្មោះថា
ជាបណ្ឌិតបានដែរ ។

ម្យ៉ាងទៀត ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ត្រាស់ដាស់តឿនឲ្យខំដុសខាត់បញ្ញាឲ្យល្អ ហើយរកគ្រឿងជំនួយជួយដែលនាំលាយឡើងនូវបញ្ញា ដូចជាអំបិលដែលនាំលាយឡើងនូវម្ហូបសម្លដូច្នោះ ឯបញ្ញាក៏មានគុណធម៌ដទៃជាច្រើនយកមកជួយផងដែរ ។

ហេតុហ្នឹងហើយ បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា គុណជាតិដែលសម្រេចប្រយោជន៍ដោយឆាប់រហ័ស ដូចចិត្តប្រាថ្នាយ៉ាងនេះ ក៏ជាតួបញ្ញាដោយពិត ។

ឯធម៌នោះ បានដល់ឥទ្ធិបាទ ៤ ឬវេសារជ្ជករណធម៌ទាំង ៥ ។ ឥទ្ធិបាទ ៤ នោះគឺ

១_ ឆន្ទៈ ការចូលចិត្តស្រឡាញ់ក្នុងកិច្ចការនោះៗ,

២- វិរិយៈ ការព្យាយាមប្រកបកិច្ចការនោះៗ,

៣- ចិត្តៈ យកចិត្តទុកដាក់ក្នុងកិច្ចការនោះ ៗ មិនលះបង់ធុរៈ ចោល,

៤- វិមំសា ៖ ឧស្សាហ៍ពិចារណាត្រិះរិះរកហេតុ-ផលនោះ ៗ ។

សេចក្តីថា ការចូលចិត្តស្រឡាញ់វិជ្ជាផ្លូវលោកក្តី ផ្លូវធម៌ក្តី លុះតែខំស្វះស្វែងរក ទើបបានជួបប្រទះនឹងចំណេះវិជ្ជាការចេះដឹង ហើយត្រូវមានសេចក្តីព្យាយាម ថែរក្សាទុកការចេះដឹងឲ្យមាំទាំឡើង ត្រូវដុសខាត់ចំណេះវិជ្ជារបស់យើង ឲ្យមានពន្លឺភ្លឺរលើង កុំឲ្យសាបសូន្យទៅវិញបាន ខំប្រឹងប្រែងក្នុងការចេះដឹង មិនលះបង់ចោល ឧស្សាហ៍ត្រិះរិះរកហេតុផល បានដល់កុសលវិតក្កៈទាំង ៣ គឺសេចក្តីត្រិះរិះចេញចាកកាម ដើម្បីកាន់ឧត្តមភេទ ១ សេចក្តីត្រិះរិះ មិនយកចិត្តចងគំនុំគំគួន ចំពោះសត្វនិងសង្ខារ ១, សេចក្តីត្រិះរិះមិនបៀតបៀនអ្នកដទៃ ឲ្យបានសេចក្តីរងទុក្ខវេទនា ដោយសារខ្លួន ១ ។

ធម៌សម្រាប់អ្នកប្រតិបត្តិតាម ឲ្យមានបញ្ញាធំអាចក្លាហានបន្ថែមទៀត តាមក្របព័ន្ធនោះ ៗ គឺវេសារជ្ជករណធម៌មាន ៥ យ៉ាង គឺ

១- សទ្ធា ការជឿតែដែលគួរជឿ,

២- សីលៈ ការរក្សាកាយវាចាចិត្ត ឲ្យរៀបរយល្អ,

៣- ពាហុសច្ចៈ ការជាអ្នកសិក្សារៀនសូត្រច្រើន,

៤ វីរិយារម្ភៈ ការប្រារព្ធសេចក្តីព្យាយាម ,

៥_បញ្ញា សេចក្តីដឹងប្រាកដ ចំពោះរបស់ដែលគួរដឹង ៗ

ទី១- សទ្ធា ការជឿចំពោះវត្ថុទាំង ៣ ប្រការ មានព្រះពុទ្ធជាដើម ដែលជាវត្ថុស័ក្តិសិទ្ធិ ប្រសើរលើសលុប និងរកវត្ថុដទៃប្រសើរជាងគ្មាន ៗ ជំនឿបែបនេះ ជាគ្រឿងប្រកបផ្សំឲ្យបញ្ញាក្លាហានមួយផ្នែកដែរ ៗ

ទី២- សីលៈ ការរក្សាកាយវាចាចិត្តឲ្យមានរបៀបរៀបរយល្អ គឺ សហធម្មិក ក្នុងព្រះពុទ្ធសាសនានេះ ជាបុគ្គលមានសីលបរិបូណ៌ ពេញ-លេញ សង្រួមប្រយ័ត្ន ដោយធម៌ជាគ្រឿងឃុំគ្រងទុក មិនធ្លោយប្រហែស ក្នុងការរក្សាសិក្ខាបទទាំងឡាយ ដែលជាពុទ្ធបញ្ញត្តិខ្លះ ពុទ្ធានុញ្ញាតខ្លះ ព្រមទាំងជាអ្នកសម្បូណ៌ ដោយអាចារៈនិងគោចរដ៏សមគួរ ឃើញភ័យ ក្នុងទោសសូម្បីមានប្រមាណតិចតួចជាប្រក្រតី ហើយសមាទាននិងរក្សា រៀនសូត្រសិក្ខាបទទាំងឡាយនោះៗ ៗ

ទី៣- ពាហុសច្ចៈ ភាវៈជាអ្នកសិក្សារៀនសូត្រច្រើន ហើយ ទ្រទ្រង់នូវធម៌ ដែលខ្លួនបានរៀនសូត្រ បានស្តាប់ចេះចាំនោះៗ ព្រមទាំង សន្សំនូវធម៌មានពិរោះបទដើម-កណ្តាល-ចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថនិងព្យញ្ជនៈ ពេញគ្រប់គ្រាន់បរិសុទ្ធគ្រប់យ៉ាង មិនមាន

សេសសល់ ធម៌ទាំងពួងដែលមានសភាពដូច្នេះ លោកបានរៀន បានស្ដាប់ចេះដឹងច្រើន ហើយទ្រទ្រង់សន្សំទុក ត្រិះរិះពិចារណាដោយចិត្តនឹងបានចាក់ធ្លុះធម៌ល្អ ដោយសេចក្ដីយល់ឃើញត្រូវ ។

ទី ៤– វីរិយារម្ភៈ ការប្រារព្ធសេចក្ដីព្យាយាម គឺពុទ្ធបរិស័ទក្នុងព្រះពុទ្ធសាសនា ជាបុគ្គលបានប្រឹងប្រែងឧស្សាហ៍ ដើម្បីលះបង់នូវអកុសលធម៌ ហើយបំពេញកុសលធម៌ ជាអ្នកមានកម្លាំងកំហែងនឹងសេចក្ដីប្រឹងប្រែងមាំមួន មិនលះកិច្ចធុរៈក្នុងកុសលធម៌ចោលឡើយ សមដូចសុភាសិតថា

វីរិយពលោ ភិក្ខវេ អរិយសាវកោ

អកុសលំ បជហតិ កុសលំ ភាវេតិ

សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ

សទ្ធម្មា ន បរិហាយតិ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកតែងមានសេចក្ដីព្យាយាមជាកម្លាំង លះបង់នូវអកុសលធម៌ទាំងអស់ មិនឲ្យជិតដាមនៅក្នុងចិត្ត ហើយញុំាងកុសលធម៌ឲ្យចម្រើនឡើង លះបង់នូវចំណែកធម៌ដែលជាទោស ហើយញុំាងចំណែកធម៌ដែលជាគុណឲ្យចំរើនឡើង រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ។

ទី ៤– បញ្ញា ការដឹងប្រាកដចំពោះវត្ថុដែលគួរដឹង ជាគុណជាតិប្រកបព្រមដោយបញ្ញា ជាគ្រឿងពិចារណាឃើញការកើត និងការរលត់នៃសង្ខារទាំងពួងដោយជាក់ច្បាស់ ជាបញ្ញាដ៏ប្រសើរ អាចកំចាត់កិលេសសេចក្តីសៅហ្មងរបស់ចិត្តឥតមានសល់ និងជាគ្រឿងធ្វើឲ្យដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ឬពិចារណាឃើញច្បាស់នូវអរិយសច្ចទាំង៤ រហូតដល់បានសម្រេច នូវធម៌ជាន់ខ្ពស់ មានសោតាបត្តិផលជាដើម ហើយកាប់ផ្តាច់ផ្តិលនូវសំយោជនៈ ១០ យ៉ាងគឺ

១– សក្កាយទិដ្ឋិ សេចក្តីយល់ឃើញថា ខន្ធ ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជារបស់ខ្លួនទាំងអស់,

២– វិចិកិច្ឆា សេចក្តីសន្ទេះសង្ស័យមិនដាច់ស្រេច ក្នុងខន្ធទាំង ៥ ដែលមានក្នុងកាល ៣ គឺ កាលដែលកន្លងហួសទៅហើយ អាត្មាអញធ្លាប់បានកើតជាអ្វីដែរ ឬ ទេ? ជំណាតទៅមុខ អាត្មាអញមានខ្លួនដែរ ឬ មិនមានទេ? ឥឡូវនេះ អញ ឬ មិនមែនអញ?

៣– សីលព្វតបរាមាសៈ សេចក្តីប្រកាន់អង្អែល ប្រកាន់វត្តប្រតិបត្តិប្រក្រតីរបស់ខ្លួន គឺប្រកាន់ថា នេះវត្តបរិសុទ្ធជាដើម,

៤– កាមច្ឆន្ទៈ សេចក្តីត្រេកត្រអាលក្នុងកាមភព,

៥- ព្យាបាទ: ចិត្តចង់គំនុំអ្នកដទៃឲ្យវិនាស,

៦- រូបរាគ: សេចក្ដីត្រេកត្រអាល ក្នុងរូបកត,

៧- អរូបរាគ: សេចក្ដីត្រេកត្រអាល ក្នុងអរូបកត,

៨- មានះ: សេចក្ដីរើងរឹងរូស ប្រកាន់ខ្លួន,

៩- ឧទ្ធច្ចៈ: សេចក្ដីរាយមាយចិត្ត,

១០- អវិជ្ជា សេចក្ដីល្ងង់ខ្លៅ វង្វេងងងើងងងោង មមិងមមាំង មិនដឹងអ្វី ។

សំយោជនធម៌ទាំង ១០ យ៉ាងនេះឯង ចងភ្ជាប់រឹតរឹតចិត្តសត្វឲ្យសៅហ្មង មិនឲ្យមានពន្លឺស្មើកើតឡើងបាន ហើយញ៉ាំងសត្វឲ្យវិលវល់កើតស្លាប់ ៗ ក្នុងវដ្ដសង្សារ ។

យោគាវចរកុលបុត្រ ដែលលោកបានកាត់ផ្ដាច់ផ្ដិលនូវសំយោជនធម៌ទាំងនេះបាន តាមលំដាប់នៃអរិយមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម ឲ្យជ្រះស្រឡះចាកខន្ធសន្ដានទៅបាន ដោយអំណាចនៃអរិយមគ្គញាណ គឺជាប្រាជ្ញាជាន់ខ្ពស់ កាលបើយោគាវចរកុលបុត្រស្វែងកកេរ្តិ៍ផ្សំនឹងបញ្ញាបានជួបប្រទះហើយ មុខជានឹងបានសម្រេចនូវសុខ-ចំរើន ក្នុងជាតិនេះ នឹងជាតិខាងមុខទៀត មិនលែងឡើយ ។

បញ្ញាបើមានក្នុងសន្តានចិត្តនៃបុគ្គលណា ហើយបុគ្គលនោះអាចរក ហេតុ-ផល ដែលជាឧបាយជួយដោះទុក្ខទោសអ្នកដទៃ បានដោយងាយ ព្រមទាំងសេចក្តីអន្តរាយរបស់ខ្លួនឯងទៀត ឥតទើសទាក់ ។

ការសំដែងអំពីពន្លឺ ៤ ប្រការ គឺ ពន្លឺព្រះចន្ទ, ពន្លឺព្រះអាទិត្យ, ពន្លឺភ្លើង, ពន្លឺបញ្ញា, ក៏សន្មតថា ចប់តែប៉ុណ្ណោះឯង ។

x

x x

## និគមវចនៈ

ពន្លឺក្នុងលោកបួនប្រការ ភ្លឺច្បាស់អស្ចារ្យគ្រប់វេន
ព្រះចន្ទបំភ្លឺលោកច្បាស់ទែង គ្រប់ទីកន្លែងក្នុងពេលយប់ ។
ឯព្រះអាទិត្យមានអាភា ភ្លឺតែវេលាថ្ងៃលើសលុប
ដល់ពេលរាត្រីអាកាសខ្ទប់ ឲ្យងងឹតឈប់បាត់រស្មី ។
ឯពន្លឺភ្លើងផងទាំងឡាយ ដែលភ្លឺសុះសាយលើផែនដី
ដោយសារគេដុតឧសប្រេងក្តី ទើបមានរស្មីភ្លឺឡើងបាន ។
រីឯពន្លឺគឺប្រាជ្ញា ភ្លឺឥតឧបមាយល់សព្វឋាន
បំភ្លឺដឹកនាំសត្វគ្រប់ប្រាណ ឲ្យបានឈ្វេងយល់ផ្លូវបាបបុណ្យ ។

# រឿងវិឌូឌភៈ

ព្រះមហា ឡឹក-អម៉រ រៀបរៀង

ក្នុងសម័យពុទ្ធកាល មានព្រះរាជកុមារ ៣ ព្រះអង្គ គឺ បសេនទិ (ព្រះរាជបុត្រព្រះចៅមហាកោសល នៅរាជធានីសាវត្ថី) ១, មហាលិ (ព្រះរាជបុត្រវង្សលិច្ឆវី នៅក្រុងវេសាលី) ១, ពន្ធុល (ព្រះរាជបុត្រមល្លក្សត្រនៅក្រុងកុសិនារា) ១ ។

ព្រះរាជកុមារទាំង ៣ អង្គនេះ បានចេញទៅសិក្សាសិល្បសាស្ត្រនៅមហាវិទ្យាល័យនាក្រុងតក្កសិលា, មកជួបគ្នាត្រង់សាលាមួយនៅក្រៅនគរ ក៏សាកសួរត្រកូលនិងព្រះនាមរៀងៗខ្លួន រួចសុំចងមិត្រនឹងគ្នា ហើយបានចូលទៅរៀន ក្នុងសំណាក់សាស្ត្រាចារ្យជាមួយគ្នា លុះរៀនចេះចប់អស់ហើយ ក៏លាគ្រូវិលទៅកាន់រាជធានីរៀងពល់អង្គវិញ ។ ព្រះអង្គម្ចាស់បសេនទិ បានសំដែងសិល្បសាស្ត្របង្ហាញព្រះបិតា ហើយបានជាទីសព្វព្រះទ័យនៃព្រះមហាក្សត្រជាអនេក ទើបទ្រង់អភិសេក ឲ្យគ្រងរាជ្យស្នងព្រះអង្គ ។

ឯព្រះអង្គម្ចាស់មហាលិ ក៏បានខំប្រឹងបញ្ចេញនូវចំណេះរបស់ទ្រង់ បង្ហាញដល់ព្រះរាជវង្សានុវង្សណាស់ដែរ តែអកុសល បណ្ដាលឲ្យបែកព្រះនេត្រខ្វាក់ទាំងសងខាង ។ តែទោះបីដូច្នោះ ក៏គង់ព្រះរាជវង្សា

នុវង្ស មិនលះបង់ចោលទ្រង់ដែរ បានជួយឧបត្ថម្ភយ៉ាងពេញបន្ទុក គឺប្រគល់ទ្វារព្រះនគរមួយចំហៀង ដែលមានស្រុកចំណុះរាប់សែន ឲ្យទៅជាកម្មសិទ្ធិនៃព្រះរាជកុមារអង្គនេះ ។ ព្រះអង្គម្ចាស់មហាលិ ទ្រង់មិនបោះបង់ព្យាយាមចោលសោះ ថ្វីបើព្រះនេត្រទាំងពីរពិការដូច្នោះ, មានព្រះរាជបុត្រនៃវង្សលិច្ឆវី ចំនួន ៥០០ អង្គ បានមកសិក្សាសិល្បសាស្រ្ត ក្នុងសំណាក់ទ្រង់ ។

ចំណែកខាងព្រះអង្គម្ចាស់ពន្ធុល ក្រោយដែលបានចូលមកដល់ព្រះរាជធានីវិញ ព្រះរាជវង្សានុវង្សបានយកឫស្សី ៣៦០០ ដើម ហើយប្រកសួលដែក ទៅក្នុងដើមឫស្សីទាំងនោះឥតឲ្យសល់ រួចចងផ្តុំជា ៦០ បាច់ ក្នុង ១ បាច់មាន ៦០ ដើម ហើយប្រកាសប្រាប់ថា ចូលព្រះរាជកុមារពន្ធុល មកកាត់ឫស្សី ៦០ បាច់នេះឲ្យដាច់ចុះ ។ លំដាប់នោះព្រះរាជកុមារកាន់ដាវចេញមកហើយ លោតទៅលើកំពស់ ៨០ ហត្ថ កាប់ខ្ទាប់ ក៏ឮសូរគ្រិក ! ទ្រង់លាន់ព្រះឱស្ឋថា យើ ! អ៊ីហ្នឹង ? លុះទ្រង់ជ្រាបថា គេប្រកសួលដែកក្នុងដើមឫស្សីដូច្នោះ ក៏ទ្រហោយំរៀបរាប់ថា «បណ្តាញាតិមិត្រទាំងប៉ុន្មាននេះ គ្មានអ្នកណាម្នាក់ប្រាប់រឿងនេះឲ្យអញបានដឹងផងសោះ ប្រសិនបើអញដឹងមុន នឹងកាប់ដែកទាំងអស់ឲ្យដាច់មិនឲ្យឮសូរទៀតផង » ទើបទូលព្រះមាតាព្រះបិតាថា « ទូលព្រះបង្គំជាខ្ញុំនឹងសម្លាប់ពួកទាំងនេះ យករាជ្យសម្បត្តិឲ្យបាន » ។ ឯព្រះមាតា

ព្រះបិតា បានឃាត់ថា «នែបុត្រសំឡាញ់! ការគ្រងរាជ្យនេះ គឺជាប្រពៃណីតៗគ្នាតាមវង្សទេ កូនឯងមិនត្រូវបានទេ» ។ ទើបព្រះរាជកុមារទូលថា «បើដូច្នោះ កូនសុំលាលោកអ្នកមានគុណទៅនៅជាមួយសំឡាញ់ ឯក្រុងសាវត្ថីហើយ» ។

ថ្ងៃនោះ ព្រះបាទបសេនទិ លុះជ្រាបថា ព្រះអង្គម្ចាស់ពន្ធុលជាសំឡាញ់យាងមក ក៏ទ្រង់ទៅទទួលនាំទៅគាល់ព្រះរាជនិវេសន៍, តមកទ្រង់តាំងឲ្យធ្វើជាសេនាបតី ។ ព្រះអង្គម្ចាស់សេនាបតី បានយកព្រះមាតាព្រះបិតា ពីក្រុងកុសិនារាមកឲ្យនៅជាមួយទ្រង់ ឯក្រុងសាវត្ថីវិញ ។

សម័យមួយ ព្រះបាទបសេនទិ ទ្រង់កំពុងប្រថាប់នៅក្នុងប្រាសាទព្រះរាជតំណាក់ បានទៀងព្រះនេត្រទៅ ឃើញភិក្ខុសង្ឃពីរពាន់អង្គកំពុងនិមន្តដើរ តាមផ្លូវទៅទទួលភត្ត នៅគេហដ្ឋានមហាឧបាសកឧបាសិកា អនាថបិណ្ឌិក វិសាខា ជាដើម ទ្រង់សាកសួរពួកស្នំបំរើ លុះជ្រាបពត៌មាននេះ ព្រះបាទមានព្រះរាជបំណងចង់ធ្វើដូច្នោះដែរ ទើបយាងទៅកាន់វត្តជេតពន ដោយព្រះអង្គឯង ហើយនិមន្តព្រះពុទ្ធជាម្ចាស់ព្រមទាំងភិក្ខុសង្ឃ ១ ពាន់អង្គ ឲ្យទៅទទួលចង្ហាន់ ឯព្រះរាជតំណាក់គ្រប់កំណត់៧ថ្ងៃ ។ ក្នុងថ្ងៃបង្ហើយ ទ្រង់បវារណាចំពោះព្រះភក្ត្រព្រះសម្ពុទ្ធថា «សូមព្រះអង្គស្តេចមកទទួលភត្តនៅទីនេះ រាល់ៗថ្ងៃកុំបីខាន ព្រមទាំង

ព្រះសង្ឃ ៥០០ អង្គទៀតផង ៗ ព្រះបរមគ្រូទ្រង់ត្រាស់តបទៅវិញថា " មហារាជ ! តាំងពីបុរាណកាលមក ព្រះពុទ្ធទាំងឡាយ មិនដែលទទួលភិក្ខាហារតែផ្ទះមួយ ៗ ជាប់ជានិច្ច រៀងរាល់ថ្ងៃទេ ព្រោះថា បើធ្វើដូច្នេះទៅ នឹងនាំឲ្យពួកជនអ្នកមានសទ្ធាឯទៀត គេទទួលចាំជាមិនខាន " ៗ ទើបព្រះរាជាទូលបន្ថែមតទៅទៀតថា " បើដូច្នេះ សូមព្រះអង្គទ្រង់មេត្តាប្រោសអនុញ្ញាតភិក្ខុ ១ រូប ឲ្យធ្វើជាប្រធានសង្ឃឲ្យបាន " ៗ ព្រះបរមសាស្តាបានបាត់ព្រះមហាអានន្ទឲ្យទទួលការៈនេះ ៗ ការរៀបគ្គប្រគេនភិក្ខុសង្ឃ នៅក្នុងព្រះបរមរាជវាំង បានប្រព្រឹត្តទៅដោយរៀបរយ តែក្នុងកំឡុង ១ សប្តាហ៍ប៉ុណ្ណោះទេ ត្បិតព្រះមហាក្សត្រទ្រង់បាត់បែងផ្គាល់ព្រះអង្គឯង ៗ លុះដល់ថ្ងៃទី ៨ ព្រះរាជាមានព្រះទ័យរវើរវាយ យាងមកមិនទៀងទាត់ពេលវេលា ក្នុងការបំរើព្រះសង្ឃ ហើយថែមទាំងមិនបានបង្គាប់ដល់ជនណាម្នាក់ ឲ្យកាន់ការនេះជំនួសព្រះអង្គសោះ ៗ ថ្ងៃតមកព្រះរាជាបេះតែធ្វើដំណើរយឺតយូរ ហាក់ដូចជាពុំសូវយកព្រះទ័យទុកដាក់បំរើព្រះសង្ឃ ជាហេតុនាំឲ្យមានការយឺតយោកហួសប្រមាណ ៗ ចំណែកព្រះសង្ឃវិញ លែងមានសេចក្តីគក់ក្តៅចំពោះព្រះរាជនិមន្តនេះ ដូចថ្ងៃមុន ៗ ទៀត ព្រោះថា ដូនកាលពេលនិមន្តមកដល់ ពុំទាន់ឃើញមានរៀបចំក្រាលអាសនៈនៅឡើយផង , វិការដូចនេះ ជាបុព្វហេតុនាំឲ្យ

ព្រះភិក្ខុសង្ឃ មានសេចក្ដីស្ញៀសក្នុងរាជត្រកូល ៗ លុះកន្លងមកប្រមាណ ៣ថ្ងៃ ភិក្ខុទាំងនោះពុំអាចនឹងទ្រាំទ្រទទួលភត្ត ក្នុងព្រះរាជតំណាក់តទៅទៀតបាន ក៏បបួលគ្នាឈប់និមន្តទៅទីនោះ នៅសល់តែព្រះមហាអានន្ទ ១អង្គគត់ ៗ ថ្ងៃក្រោយមក ព្រះមហាក្សត្រជ្រាបហេតុនោះ ទ្រង់ព្រះពិរោធចំពោះពួកភិក្ខុសង្ឃជាខ្លាំង ទើបយាងទៅវត្តជេតពន ទូលព្រះសម្ពុទ្ធជាម្ចាស់ថា "ចង្ហាន់ដែលខ្ញុំព្រះអង្គបានចាត់ចែងបំរុងព្រះសង្ឃ៥០០ រូបនោះ ឥឡូវនេះ សំលេះពារពាស ព្រោះមានតែព្រះអានន្ទតែមួយអង្គប៉ុណ្ណោះ ព្រះសង្ឃឯទៀត ពុំដឹងហេតុអ្វីបានជាលោកពុំព្រមនិមន្តទៅសោះ?" ៗ ព្រះបរមសាស្ដាទ្រង់ពុំបានថ្លែងនូវទោសកំហុសរបស់ពួកភិក្ខុទាំងនោះទេ, ទ្រង់ត្រាស់ទៅកាន់ព្រះរាជាវិញថា "មហារាជ! សេចក្ដីស្និទ្ធស្នាលរវាងមហារាជនឹងបុត្រតថាគត គ្មានបន្តិចបន្តួចសោះ បានជាបុត្រតថាគតលែងទៅ" រួចទ្រង់ប្រជុំពួកភិក្ខុសង្ឃ ប្រកាសប្រាប់ នូវហេតុគួរនឹងមិនគួរចូលទៅកាន់ត្រកូលទាំងឡាយ ហើយទ្រង់សំដែងព្រះសូត្រ ដូចតទៅនេះ ៖

ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ៩ (ដូចតថាគតនឹងសំដែងខាងក្រោមនេះ) បើភិក្ខុមិនទាន់ចូលទៅរកនៅឡើយទេ មិនគួរចូលទៅជិតឡើយ, បើចូលទៅហើយ មិនគួរអង្គុយ (ក្នុងផ្ទះនៃត្រកូលបែបនេះ) សោះឡើយ:

១– គេមិនក្រោកទទួលភិក្ខុ ដោយសេចក្ដីពេញចិត្ត,

២. គេមិនថ្វាយវន្ទភិក្ខុ ដោយសេចក្ដីពេញចិត្ត,

៣– គេមិនពេញចិត្តនឹងឲ្យភិក្ខុអង្គុយលើអាសនៈ,

៤– គេលាក់លៀមទ្រព្យរបស់ ( មានខំពិណពីជាដើមឲ្យកំបាំង ) ពីមុខភិក្ខុ,

៥– គេមានវត្ថុច្រើន គេតែងឲ្យភិក្ខុបន្តិចបន្តួចសោះតែខាន,

៦– គេមានវត្ថុយ៉ាងប្រណីត តែបែរជាគេឲ្យរបស់សៅហ្មង (ដែលគេលែងត្រូវការទៅហើយ),

៧ គេឲ្យដោយសេចក្ដីមិនគោរព,

៨– គេមិនចូលមកស្ដាប់ធម៌,

៩– គេមិនត្រេកអរចំពោះភិក្ខុ ដែលកំពុងនិយាយពីធម៌ការជ ៗ

ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ៩(ផ្សេយពីអង្គខាងលើនេះ) បើភិក្ខុមិនទាន់ចូលទៅរកនៅឡើយ ក៏គួរបូលទៅចុះ. បើចូលទៅជ្រុលហើយ ក៏គួរអង្គុយ (សន្ទនាស្និទ្ធស្នាលនឹងត្រកូលបែបនេះ)បាន ៗ

(អង្គទាំង៩ នៃត្រកូលដែលភិក្ខុគួរចូលទៅរកនោះ មិនបានសំដែងទៀតទេ ព្រោះដូចគ្នាខាងលើដែរ គ្រាន់តែផ្ទុយគ្នា ប៉ុណ្ណោះ ) ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់បញ្ជាក់ទៅព្រះចៅបសេនទិទៀតថា មហាពជរស្សាវកតថាគត មិនបានទទួលវិស្សាសៈ អំពីសំណាក់មហាពជ ដូចតថាគត

សំដែងមកនេះសោះ បានជាសាកែតាំងនោះលែងទៅ ” រួចទ្រង់តាញ និមន្តជាគតពីព្រៃនាយ ដែលមានដំណើរទំនងដូចគ្នានឹងរឿងពួកភិក្ខុ ប្អូលៈ ៧នាក់ គួរព្រះរាជដំណាក់ដែរ មកសំដែងឲ្យព្រះរាជាទ្រង់ព្រះសណ្ដាប់ទៀត ដើម្បីឲ្យទ្រង់រឹតតែបានយល់ច្បាស់នូវលទ្ធផលផុយ គួរការទំនុកបំរុងបព្វជិត មិនគ្រប់អង្គ (លក្ខណៈ) ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ នូវធម្មកថានេះហើយ ទ្រង់មានព្រះវិតក្កផ្សេងៗ ដូច្នេះ «ដើម្បីនឹងធ្វើ នូវសម្ពន្ធភាពនឹងព្រះសង្ឃ ឲ្យបានប្រសើរដោយមុខ គួរតែគ្នាអញគិតវែងឆ្ងាយយ៉ាងណាទេ? ក្នុងករណីនេះ គួរតែគ្នាអញ យកធីតាម្នាក់ ជាព្រះញាតិរបស់ព្រះពុទ្ធអង្គធ្វើជាភរិយា ទើបពួកភិក្ខុ សាមណេរ ដែលជាអ្នកទាំងនេះមកទទួលភត្ត នៅក្នុងដំណាក់របស់អាត្មាអញ ព្រោះហេតុតាំងពីនោះតទៅទៀតតែឃើញថា អាត្មាអញជាញាតិរបស់ព្រះសម្ពុទ្ធ”, រួចទ្រង់បានផ្ញើព្រះរាជសារទៅឲ្យពួកសាក្យៈ ឲ្យរើសកេតិតាម្នាក់ ថ្វាយព្រះអង្គធ្វើជាមហេសី ។ លុះសារនេះទៅដល់ ពួកសាក្យៈបានចាត់ការប្រជុំព្រះរាជវង្សានុវង្សទាំងអស់ ហើយបានបញ្ចេញយោបល់ជំទាស់ថា ព្រះមហាក្សត្រអង្គនេះ ជាពូជស្ដេចជោគជាប ជាមិត្រគ្រូលយើង មិនគួរលើកកូនយើង ថ្វាយព្រះអង្គទេ ប៉ុន្តែបើយើងមិនព្រមថ្វាយ មុខជានឹងមានគ្រោះថ្នាក់ទៅថ្ងៃក្រោយមិនខាន, ដូច្នេះគេៈយើងគួរដោះស្រាយបញ្ហានេះយ៉ាងណា! ។ ខណៈនោះ ព្រះអង្គម្ចាស់មហានាម បានឡើងថ្លែងថា « ខ្ញុំមានកូនក្រមុំបាវស្រីខ្ញុំម្នាក់ ឈ្មោះ

វាសភខត្តិយា(១) រូបពន់ស្អាតបាតល្អ មលើកថ្វាយទៅស្តេចនោះបាន ។ ព្រះរាជវង្សានុវង្សទាំងអស់ បានយល់ព្រមតាមមហានាម ទើបប្រើទូតឲ្យនាំពត៌មាន ទៅថ្វាយព្រះបាទបសេនទិវិញថា ពួកទូលព្រះបង្គំជាខ្ញុំព្រមលើកធីតាម្នាក់ ថ្វាយព្រះមហាក្សត្រ តាមព្រះរាជបំណងហើយ នាងនោះឈ្មោះវាសភខត្តិយា ត្រូវជាបុត្រីមហានាម ។ រាជទូតក៏នាំពត៌មាននោះទៅទូលព្រះរាជាតាមដំណើរ ។ ទើបព្រះមហាក្សត្រមានបន្ទូលថា បើពិតមែនជាការប្រពៃហើយ តែខ្ញុំថប់ណាស់ ព្រោះធម្មតាពួកសាក្យៈច្រើនមានពុតត្បុតអាក្រក់ ដូនយកខ្ញុំបំរើខ្លួនមកបន្ទំថា ពូជសាក្យៈដែរ ដូច្នេះអ្នកឯងគប្បីយកស្ត្រីណា ដែលបរិភោគអាហារជួបជុំនឹងពុកទើបបរិសុទ្ធ ។ រាជទូតក៏នាំព្រះរាជសាសន៍នេះទៅថ្វាយដំណឹងដល់ពួកសាក្យៈវិញ ។ ទើបព្រះអង្គម្ចាស់មហានាមឆ្លើយថា ល្អហើយអ្នក រូបគាំនឹងបង្គាប់ទៅចាវស្រីដែលទ្រង់បំរុងលើកថ្វាយទៅស្តេច ឲ្យស្អិតស្អាងគ្រឿងអលង្ការរួចហៅឲ្យមកបរិភោគអាហារជាមួយទ្រង់ ។ រាជទូតឃើញដូច្នោះ អស់សង្ស័យតទៅទៀត ទើបនាំទៅកាន់ក្រុងសាវត្ថី ។ ព្រះបាទបសេនទិ ក្រោយដែលរាជទូតថ្វាយពត៌មានសព្វគ្រប់ ទ្រង់មានព្រះរាជហឫទ័យសោមនស្ស

---

១- ក្នុងមង្គលត្ថទីបនីបញ្ជាក់ថា នាងនេះត្រូវជាកូននៃនាងមុណ្ឌា ដែលជាខ្ញុំបំរើព្រះអង្គម្ចាស់មហានាម ហើយដែលព្រះអង្គម្ចាស់នេះ បានរួមសង្វាសជាមួយ ទាល់តែកើតបាននាងវាសភខត្តិយានេះ ។

ជាអនេក ក៏តាំងនាងនោះធ្វើជាអគ្គមហេសីធំលើសស្រីស្នំ ៩០០ នាក់ ។ មិនយូរប៉ុន្មាន ព្រះនាងបានប្រសូតព្រះរាជឱរសមួយព្រះអង្គ មានសម្បុរដូចមាស ទើបចាត់បុរសម្នាក់ឲ្យយកដំណឹងទៅទូលព្រះអយ្យិកា ឲ្យបានជ្រាបថា ព្រះនាងប្រសូតបុត្រហើយ ។ សូមឲ្យដាក់នាមដល់អយ្យបុត្រនេះផង ។ ចំណែកខាងបុរសនោះ ជាមនុស្សត្រចៀកធ្ងន់បន្តិចផង ស្ដាប់ពាក្យដីដូនតាគេនិយាយមិនច្បាស់ ព្វគេរៀបរាប់សរសើរគ័ត្ដសំណាងម្ដាយតាគេនោះមកដល់ឃ្លាមួយថា វល្លកៈ ។ (ប្រែថា គាប់ចិត្ត) ក៏ស្មានថា ដីដូននោះដាក់ឈ្មោះឲ្យតាគេថា វិឌូឌកៈ ក៏កំណត់ពាក្យនេះយកមកទូលស្ដេចវិញ ។ ព្រះមហាក្សត្រក៏ដាក់នាមដល់ព្រះរាជបុត្រ តាមអាមាត្យតម្ពង់នោះទៅ ។ ម្យ៉ាងទៀត ដោយទ្រង់បង្កឲ្យគាប់ព្រះទ័យ នៃព្រះពុទ្ធជាម្ចាស់ខ្លាំងពេក ព្រះមហាក្សត្របានតាំងព្រះរាជបុត្រ ឲ្យតំណែងនៃសេនាបតីតាំងពីនៅជាកុមារតូច ។

លុះព្រះរាជកុមារបានព្រះជន្ម ១៦ វស្សា មានព្រះទ័យនឹកក្ដុកចង់ទៅលេងខាងត្រកូលព្រះអយ្យកា ទើបសុំអនុញ្ញាតអំពីព្រះវរមាតា តែព្រះនាងបានឃាត់ថា «កុំទៅអីកូន ស្រុកព្រះអយ្យកាកូនឯង នៅឆ្ងាយណាស់» ។ ទោះបីឃាត់ខាំងយ៉ាងណា ក៏ព្រះរាជកុមារនៅតែទទូចសុំទៅទាល់តែបាន ទើបទៅក្រាបបង្គំលាព្រះមហាក្សត្រ ចេញដំណើរទៅដោយមានព្រះរាជ-បរិពារយ៉ាងច្រើន ដង្ហែជូនព្រះអង្គទៅផង ។ ឯព្រះនាងវាសភខត្តិយា ជាព្រះ

វរមាតា បានផ្ញើសារសម្ងាត់ទៅមុន ថ្វាយដំណឹងដល់ម្ចាស់ថា "ខ្ញុំម្ចាស់នៅឯនាយបានសេចក្ដីសុខសប្បាយជាទេ ប៉ុន្តែឥឡូវនេះ ព្រះអយ្យបុត្រមានបំណងចង់មកលេងទីនេះ ដូច្នេះ សូមម្ចាស់កុំមានសេចក្ដីទើសទាល់អ្វី សូមទ្រង់ប្រោសទទួលមួយគ្រាផងចុះ" ។ ចំណែកពួកសាក្យៈ លុះបើកសំបុត្រនោះមើល ក៏ប្រឹក្សាគ្នាថា "យើងមិនត្រូវទៅរង់ចាំទទួលស្វាមីភក្ដិទេ" ទើបទៅកេណ្ឌកូនបណ្ដាក្សត្រក្មេងៗ តាំងពីខែត្រក្រៅ ឲ្យមករង់ចាំទទួលព្រះអង្គម្ចាស់សេនាបតីខ្លួនឯង ។ លុះទ្រង់យាងមកដល់, កុមារតូចៗទាំងនោះ ក៏នាំទៅសំណាក់នៅសណ្ឋាគារមួយ ។ លំដាប់នោះ ពួកសាក្យៈ ដែលមានអាយុច្រើនប្រហែលជា ៥០ ឬ ៦០ ឆ្នាំទៅហើយ ក៏នាំគ្នាមកបង្ហាញខ្លួន ឲ្យព្រះរាជកុមារស្គាល់ ហើយបង្អុលប្រាប់ព្រះនាមថា នេះត្រូវជាព្រះអយ្យកោ នេះត្រូវជាព្រះមាតុលា (ឪពុកមា)(១) ។ ឯព្រះរាជកុមារមិនឃើញមានអ្នកណា ថ្វាយបង្គំព្រះអង្គសោះ ក៏សាកសួរទៅព្រះញាតិថា "ចុះគេទៅណាអស់ហើយ បានជាមិនឃើញមកសមគួរនឹងខ្ញុំ?" សាក្យៈដែលនៅគង់ជិតក៏ទូលថា "ក្មេងៗទៅលេងខែត្រក្រៅអស់ហើយ នៅសល់តែចាស់ៗទេ" ។ នៅឱកាសសំណាក់អាស្រ័យនាក្រុងកបិលពស្តុនោះ គេបានថ្វាយគ្រឿងសក្ការៈ ដល់ព្រះរាជកុមារ

---

១- បានជាពួកសាក្យៈមិនឲ្យពួកក្មេងៗមក ព្រោះមិនចង់ឲ្យចំណុះព្រះរាជកុមារ, ចំណែកចាស់ៗ ត្រូវតែព្រះរាជកុមារថ្វាយបង្គំគេវិញ ព្រោះគេចាស់ជាងខ្លួន ។

ជាច្រើន ៗ គង់នៅមកបានពីរបីថ្ងៃ ទ្រង់និវត្តមកកាន់ព្រះរាជធានីសាវត្ថីវិញ ៗ ក្រោយនោះ, បាវស្រីម្នាក់ បានយកទឹកមកលាងសន្លឹកក្តារគ្រែកន្លែងព្រះរាជកុមារគង់, លាងបណ្តើរ ស្រែកជេរបណ្តើរថា «កន្លែងនេះឯង ដែលកូនមេរាំសកខត្តិយាអង្គុយ» ៗ ចៃដន្យអ្វី មានសហការព្រះរាជកុមារម្នាក់ កាលចេញទៅបានភ្លេចអាវុធចោលនៅទីនោះ ដល់ត្រឡប់មកយកវិញ ស្រាប់តែឮនាងនោះ កំពុងតែប្រទេចផ្តាសា ព្រះរាជកុមារជាអនេកប្បការ, ទើបឆ្ងល់ណាស់ ក៏សួរទៅស្ត្រីនោះ ទើបគេប្រាប់ថា អ្នកឯងមិនដឹងទេឬ មេរាំសកខត្តិយាជាកូនបាវស្រីមហានាមទេតើ ៗ បានដំណឹងនេះកាលណា បុរសនោះតាំងយកមកចរិហារ ប្រាប់សហការីរបស់ខ្លួនដឹងឮសុសសាយគ្រប់ៗគ្នា កើតទៅជាកោលាហលមួយយ៉ាងធំ ៗ ព្រះរាជកុមារទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏នឹកតូចព្រះទ័យ ចងគំនុំទុកថា "មិនអីទេ រឿងនេះ លើកទុកសិនចុះ ចាំមើលអញបានសោយរាជ្យកាលណា នឹងកាត់កពួកវាអស់នោះ យកឈាមបំពង់កលាងក្តារនោះវិញ" ៗ លុះទៅដល់ក្រុងសាវត្ថីមានពួកមន្ត្រីខ្លះ បានយករឿងនេះទៅក្រាបទូលព្រះមហាក្សត្រ ៗ ព្រះរាជាទ្រង់ប្រឡោភតូង នឹកខ្ញាល់នឹងពួកសាក្យៈដែលហ៊ានមើលងាយព្រះអង្គ គឺយកខ្ញុំបំរើមកឲ្យធ្វើជាមហេសីដូច្នេះ ទ្រង់លាន់ព្រះឱស្ឋថា «ឃើញពួកសាក្យៈ! មិនសមបើហ៊ានប្រព្រឹត្តអំពើថោកទាបដូច្នេះសោះ» ហើយទ្រង់ដកហូតងារព្រះអគ្គមហេសី នឹងព្រះរាជកុមារ

ពីតំណែងអស់ ប្រទានឋានៈស្មើនឹងខ្ញុំបំរើ ។ កន្លងមកបាន ៣ ថ្ងៃ ព្រះ-
សម្ពុទ្ធទ្រង់យាងទៅកាន់ព្រះរាជនិវេសន៍ព្រះចៅអង្គនេះ ។ ព្រះមហាក្សត្រ
ទ្រង់ធ្វើគារវកិច្ចរួច មានព្រះបន្ទូលទៅកាន់ព្រះមានព្រះភាគថា "បពិត្រ
ព្រះអង្គ ខ្ញុំព្រះអង្គ ទើបនឹងបានពត៌មានថ្មី ៗ នេះថា ព្រះញាតិព្រះអង្គ
បានលើកខ្ញុំបំរើ របស់ខ្លួនមកថ្វាយខ្ញុំព្រះអង្គ ឥឡូវនេះ ខ្ញុំព្រះអង្គបានកាត់
កាល់ចោលទាំងភរិយានិងបុត្រ ទុកឋានៈឲ្យនៅស្មើនឹងបាវព្រាវវិញ" ។
ព្រះបរមសាស្តាទ្រង់មានពុទ្ធដីកាទៅព្រះចៅវិញថា "មហារាជ ! ពិតមែន
ហើយ ពួកសាក្យៈធ្វើបែបនេះ មិនសមរម្យទេ, ក៏ហើយចុះ តថាគតសូម
ថ្វាយយោបល់ដល់មហារាជថា នាងវាសភខត្តិយា ពិតជាធីតាខត្តិយរាជ
ហើយថែមទាំងបានអភិសេក យ៉ាងគគឹកគគ៉ងនឹងមហារាជទៀតផង, ឯ
វិឌូឌភៈ ក៏ជាបុត្រក្សត្រដែរ ព្រោះថា តាមទំនៀមទម្លាប់តាំងពីបរមបុរាណ
មក មិនដែលយកគោត្តខាងមាតា ជាប្រមាណទេ គឺគោត្តខាងបិតាទេ
តើមហារាជ ទើបយកជាប្រមាណបាន", រួចទ្រង់លើកជាតកពីព្រេង
នាយ ដែលមានដំណើរស្របនឹងរឿងនេះដែរ សំដែងឲ្យព្រះរាជាទ្រង់ព្រះ
សណ្តាប់ទៀត ។ ព្រះនរបតីបានទ្រង់ព្រះសណ្តាប់ធម្មកថាចប់ ក៏មាន
ព្រះទ័យធូរស្បើយទៅវិញ ហើយព្រះអង្គបានប្រទានដំណែង អគ្គមហេសី
និងឋានៈសេនាបតីដល់ព្រះនាង និងព្រះរាជកុមារ ដូចដើមវិញ ។

( នៅមានត )

# ផ្នែកអក្សរសាស្ត្រ

# ច្បាប់ស្រី

## ព្រះរាជនិពន្ធ

ព្រះបាទសម្ដេច ព្រះហរិរក្សរាមាឥស្សរាធិបតី

ព្រះអង្គឌួង ព្រះបរមកោដ្ឋ


ឧត្តមប្រជា ហាប-ពិន និពន្ធបណ្ឌិត

នាយការិយាល័យនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ


ពិនិត្យតាមច្បាប់សម្រាយនិងបាលី

ច្បាប់នេះ

## បែងអំពីច្បាប់ស្រី ១០៨ បំពូក :

| | | | | | |
|---|---|---|---|---|---|
| ស្រីសុចរិត | ៨ | បំពូក | ស្រីចោក | ១៨ | បំពូក |
| ស្រីមាយា | ៤០ | បំពូក | ស្រីអាស | ២០ | បំពូក |
| ស្រីបង្ហិនប្តី | ១០ | បំពូក | ស្រីមាក់ងាយប្តី | ១២ | បំពូក |

## បែងអំពី :

| | |
|---|---|
| ចិត្តស្រី | ៣ពេល |
| បុរសនឹងស្ត្រីចងមេត្រីដោយហេតុ | ៨ ប្រការ |
| ករិយា | ៧ បំពូក |
| ស្វាមីសង្គ្រោះករិយា | ៥ ស្ថាន |

# លំនាំដើម

ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គឌួង-ព្រះបរមកោដ្ឋ) ព្រះអង្គជាអគ្គបណ្ឌិតខាងទេវសាស្ត្រ, ធម្មសាស្ត្រ, អក្សរសាស្ត្រ និងជាកវីឯកខាងកាព្យឃ្លោង ទ្រង់ជ្រាបក្បួនកាព្យយ៉ាងជំនាញ បានទ្រង់ព្រះរាជនិពន្ធរឿងផ្សេងៗ ច្រើនបែប ជាច្បាប់ខ្លះ ជារឿងប្រលោមលោកខ្លះ ។ ខាងច្បាប់ មានច្បាប់ស្រីនេះជាដើម ។ ខាងរឿងប្រលោមលោក មានរឿងកាកីជាដើម ។

ច្បាប់ស្រី ទ្រង់ព្រះរាជនិពន្ធក្នុងមហាសករាជ ១៧៧៩ ចុល្លសករាជ ១១៩៩ ពុទ្ធសករាជ ២៣៨០ គ្រិស្តសករាជ ១៨៣៧ វេលាព្រះជន្ម ៤១ ព្រះវស្សា ។

រឿងកាកី ទ្រង់ព្រះរាជនិពន្ធក្នុងមហាសករាជ ១៧៣៧ ចុល្លសករាជ ១១៧៧ ពុទ្ធសករាជ ២៣៥៨ គ្រិស្តសករាជ ១៨១៥ វេលាព្រះជន្ម ១៩ ព្រះវស្សា ។

ច្បាប់ស្រីនេះ មានគោលបារកសំខាន់ណាស់ ដោយទ្រង់ព្រះរាជនិពន្ធតាមបាលី សុត្តន្តបិដក ខុទ្ទកនិកាយ ត្រង់អសីតិនិបាតជាតក ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់សំដែងចំពោះភិក្ខុសក្យវង្ស ៥០០ រូប ត្រង់ខ្មេរកុណាលស្រះ (ស្រះជាទីអាស្រ័យនៅនៃពួកតាវ៉េ) ជិតព្រៃហេមពាន្ត ។

ខ្ញុំពេញចិត្តច្បាប់នេះណាស់ បានព្យាយាមពិនិត្យផ្ទៀងផ្ទាត់ ចំពោះបទណាដែលតក់ខ្វះ ដោយការចារសរសេរតៗគ្នា ឲ្យត្រូវតាមច្បាប់សម្រាយនិងបាលីដើមឡើងវិញ ហើយបោះពុម្ពឡើង ដើម្បីរក្សាទុកនូវថ្វីព្រះហស្តនៃព្រះមហាក្សត្រខ្មែរ ដែលទ្រង់ជាអគ្គបណ្ឌិតទាំងខាងពុទ្ធចក្រ-អាណាចក្រឲ្យគង់នៅ ទីងដើម្បីជាសាធារណប្រយោជន៍ដល់ជនជាតិខ្មែរ ដែលត្រូវការរក្សាទុកនូវបវេណីដ៏ល្អរបស់ជាតិទៅអនាគត ។

ខ្ញុំសូមទទួលអំណរគុណយ៉ាងខ្ពស់ ចំពោះអ្នកឧកញ៉ាកត្តិសារទេពកែ·ខេត្រ អតីតចៅក្រមជំរះបញ្ជីនៃព្រះបរមរាជវាំង ទីលំនៅនៅសង្កាត់លេខ ៦ ក្រុងភ្នំពេញ ដែលបានធ្វើអំណោយច្បាប់ដើមច្បាប់ស្រីនេះទុកជាព្រះកេរ្តិ៍នៃព្រះមហាក្សត្រខ្មែរតអង្វែងទៅ ។

១-៨-២៤៩៨-១៩៥៥

ហប-ពិន

# ច្បាប់ស្រី

## បទកាកគតិ

អហំ នាមំ រាជឆ្លូទៀ សុត្តា វញ្ញា ការុញជនគវេ នរេស្សរ អត្តា អាចរិយោ បរិបបិតា, អង្គអញរាជបុត្រ ក្នុង រាជ្យបរិសុទ្ធ ក្រុងកម្ពុជា នាមអនុជនាថ ប្តូឡជាតិក្សត្រា យល់នូវអត្ថា អាចារ្យថែងទុក ៗ និកាយបាលិ ព្រះអសីតិ និបាតជាតក សំដែង លក្ខណា ស្រីមាយាអាក្រក់, ចិត្តបើក, អាសលាមក, បង្ហិន, មាក់ងាយ, សំដែងលក្ខណា ស្រីមានកិរិយា សុចរិតគប់កាយ ឲ្យអស់ប្រុសស្រី លោកិយទាំងឡាយ ដឹងដោយបរិយាយ មាយាស្ត្រី ៗ ឯអង្គអញឯង គនគិតវារថែង ពីព្រះបាលី ជាពាក្យកាព្យ ពណ៌នាសេចក្តី ចងជា ច្បាប់ស្រី ទុកតាមអត្ថ,

ពុទ្ធសាសនា អតិក្កន្តា អសីតិ តេ សត្តាធិកា ទ្វេសហស្សេ[១] មហាសក្ករាជេ ឯកាសប្តបញ្ចឧត្តេ[២] ៗ បុស្សកពេលទៅ ពាទមួយរយកៅ សិបប្រាំ[៣] បូនគ្រប់ ថ្ងៃសៅរ៍ទៀនទេ

---

១- ច្បាប់ស្រីនេះព្រះករុណាបរមពោធិ្ញទ្រង់ព្រះរាជនិពន្ធក្នុង ព.ស. ២៣៨០ ។

២- ឯក ១ សប្ត ៧ បញ្ច ៥ ឧត្ត ៩ រួមគ្នាជា ម.ស. ១៧៥៩ ។

៣- ប.ស. ១១៩៩ គ.ស. ១៨៣៧ ក្នុងព្រះជន្ម ៤១ ។ ព្រះរាជាអង្គនេះ ទ្រង់ព្រះសម្ភព ព.ស. ២៣៣៩ ។ ទ្រង់សោយរាជ្យ ព.ស. ២៣៩១ ក្នុងព្រះជន្ម ៥២ ។ ទ្រង់ព្រះទិវង្គត ព.ស. ២៤០៤ គ.ស. ១៨៦១ ក្នុងព្រះជន្ម ៦៥ ។

នារីខបុស្សដប់ ពេចរិះឯងឃប់ យាមមួយសេសមោង, រៀបរៀងសេចក្តី ជាបទកាកគតិ ដំណាលទំនង ស្រីផ្លូស្រីជា តាមបាលីចង ទុកជាគន្លង ក្បួនច្បាប់តទៅ ។ គ្រាន់មើលគ្រាន់មាន ចិត្តចាំប្រៀនប្រាណ កុំឲ្យអាប្រូវ កុំត្រាប់មាយា ទុកជាធ្វើត្រូវ កុំត្រាប់បើកប្ញូវ ទុកជាស្មោះស្មាន, កុំត្រាប់ស្រីអាស គិតជាផ្សិតខ្មាស អៀនរើងសប្រាណ កុំត្រាប់បង្កិន ជាមិនសាមាគ្យ កុំត្រាប់សន្តាន មាក់ងាយស្វាមី ។ គិតជាគួរទេ មិនគួរស្និទ្ធស្នេហ៍ ពប់គេជាប្តី មារយាទតាំងប្រាំ ចូរចាំគ្រប់ស្រី សុទ្ធសឹងអប្រិយ គ្មានល្អមួយឡើយ, គួរត្រាប់គួរត្រង់ គួរចាំគួរចង គួរកុំកន្តើយ មារយាទសុចរិត ល្អពិតជាត្រើយ ស្រីណាត្រាប់ហើយ ហៅប្រសើរស្រៀវ គួរមើលឲ្យច្បាស់ គួរចាំឲ្យណាស់ តាមដោយវិធី អាចារ្យថែងចង ក្រងសេចក្តី ក្នុងព្រះបាលី និកាយសុត្តា ។ ៚

នេះទំនងសំដែង បរិយាយតាថែង ដើមបទ អដ្ឋ · ហិ ហ ចេ-ហិ សុចរិតា ឥត្ថីលក្ខណា មង្គលប្រះពិត, ប្រែថាស្រីជា កើតកបលក្ខណា ដោយនូវសុចរិត មង្គលប្រាំបី ឲ្យស្រីពិនិត្យ ចាំយកជាក្រឹត្យ គ្រប់រូបស្រ្តី ៖

១(១) - ដើមបទពណ៌នា លោកថា ស្រីជា សុចរិតកក្តី

១.- ពីត្រឹមនេះទៅមុខ ត្រង់ដែលដាក់លេខដើមៗ ទាំងប៉ុន្មាន គ្រាន់តែជាសញ្ញាប្រាប់ចំនួនប៉ុណ្ណោះ មិនឲ្យអានទេ ។

បុកពបស្រែគត់ ផ្គន់ផ្គត់សំដី ការកើតខាសស្រី បរិសុទ្ធមែនមួន,

២- លោកថា ស្រីត្រង់ កាន់សុចរិតផ្គង់ គំនិតបេះស្ងួន អស់ទ្រព្យសម្បត្តិ ប្រយ័ត្នថែជួន ទុកដាក់ខ្ជាប់ខ្ជួន មិនមានប្រមាទ ។

៣- លោកថា ស្រីតាប់ កាន់សុចរិតខ្ជាប់ ឧស្សាហ៍សង្វាត ធ្វើការសន្សំ តឿនខ្ញុំឲ្យឃ្លាត ឲ្យខំឧហាត មិនមានស្ងៀមដៃ ,

៤- លោកថា ស្រីប្រាជ្ញ សុចរិតអង់អាច បេះអញ្ញាស្រ័យ ញាតិត្រៀងទៅមក រាប់រកស្រស់វៃ ទោះជនដទៃ ក៏ពប់តាមពិត ។

៥- លោកថា ស្រីស្អាត សុចរិតគ្មានឃ្លាត មែនមានគំនិត បេះ រៀបអាហារ ភ្លាត់ផាស្រែពិត រណ្ដាប់ផ្គាប់ចិត្ត ប្ដីប្រុងវេលា ,

៦- លោកថា ស្រីស្មោះ កាន់សុចរិតឆ្ពោះ ចាំចិត្តស្នេហា តែ ទីងអផ្គប្ដី ឥតបីរេក ស្មុគ្រស្មោះស្មើជា និត្យនៅរៀបរៀង ។

៧- លោកថា ស្រីស្លូត សុចរិតហ្មត់ អបអត់ឥតល្អៀង តាម ពាក្យប្ដីផ្ដាំ ចងចាំទុកទៀង ពោលពាក្យមិនឃ្វៀង មិនឃ្លាតសត្យា ។

៨ លោកថា ស្រីស្មើ សុចរិតសរពើ អាចរេងធានា ទម្ងន់ចិត្តប្ដី ទោះបីទុក្ខា ក្សត្រក្រម្ដេចម្ដា អាចទទួលប្រាណ ។

សុចរិតប្រាំបី ជាមង្គលស្រី ប្រសើរក្រមាន អ្វីមកផ្ទឹមផ្ទាល់ ឲ្យដល់នេះបាន ស្រីណាអាចធ្វាន ចិត្តចាំរៀនយក, ទាំងប្រាំបីច្បាប់ ហៅ ស្រីមហាតាប់ លោកិយកម្រ ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថា

ក្រ ធ្វើតាមពុំបាន ។ លោកថាស្រីនោះ ចិត្តអាក្រក់សោះ ស្អប់ដំបូន្មាន ផ្កាដោយសារចិត្ត ទុច្ចរិតសន្តាន បង្កើតជនពាល ធ្វើការ, ភាស, មារយាទ, គឺជួរប្រើទកល ក្រដឹងបេះដល់ លែបខាយពុតជា ធ្វើចិត្តចង់ស្រាប់ ចង់ស្លាប់ហាក់ជា អាយដាយសោះសា បេះឯងដឹងឯង ។ ឯក្រង់ច្បាប់ ល្អ តិចទេយល់ក្រ កម្រៃក្រលែង ក្រព្រោះមិនចង់ ប្រឹងអង្គឲ្យស្តែង ក្រដោយចិត្តល្បែង បំណង់តណ្ហា, អំពើសុចរិត អធ្យាស្រ័យចិត្ត សំអាតឧស្សាហ៍ ស្មើស្មោះស្លូតត្រង់ គត់ផ្គត់ក្រឹត្យា ប្រាំបីនេះណា សុចរិតប្រាកដ ។ ឯសុចរិតស្រី គត់គង់ស្វាមី លោកឲ្យអបអត់ ទុះអៀន ចិត្តទន់ បេះគន់បែបបទ តាមតែប្តីពត់ ម្តេចៗតាមបាន, មិនមានប្រកែក មិនមានជជែក ថាធ្វើមិនបាន ពោះអៀនអន់អត់ សង្កត់ចិត្តប្រាណ តាមចិត្តប្តីធ្យាន ម្តេចៗមិនថា ។ ច្បាប់នេះគួរស្រី នៅនាលោកិយ ផ្គង់ចិត្តឧស្សាហ៍ កាន់គ្គីសុចរិត ជាក្រឹត្យថ្លៃថ្លា ឲ្យខ្ជាប់ជាក់ជា ចរិត សព្វថ្ងៃ, កាន់បានដូច្នោះ ទឹងព្រួតក្តរឈ្មោះ ប្រសើរពេកក្រៃ ទឹងបាន សាន្តសុខ ចៀសទុក្ខចង្រៃ ដល់បរលោកថ្ងៃ សោយសុខសួគ៌សិទ្ធ ។ សំដែងសេចក្តី ពី មង្គលស្រ្តី ប្រសើរពេកពិត គ្រប់ទាំងប្រាំបី ក្រឹត្យស្រីសុចរិត បែងចប់កាសិត តាមព្រះបាលី, គម្ពីរនិកាយ សំដែង អធិប្បាយ មង្គលស្រ្តី នេះទឹងតតែង សំដែងអំពី អសិតិន- បាត ជាតកេ ។

ឥទំ សត្ថា កុណាលទហា ហិមវន្តេ អនភិរ-តិបរេតេ បញ្ច សតេ ភិក្ខូ អាជេសិ, ព្រះសព្វញ្ញូ ព្រះអង្គជាគ្រូ គ្រប់មនុស្សប្រុសស្រី និងទេពនិកាយ ដូចនាយសារថី ទូន្មានពាជី ដោយដូចចិត្តា ៗ ព្រះអង្គគង់ឮ កុណាលស្រះស្រី ទៀបព្រៃហិមវ័ន ប្រារព្ធនឹងអង្គ ភិក្ខុដែលស្រក្យ. ពួកប្រាំរយជា កំលោះ គ្រប់អង្គ, សុទ្ធសឹងមានចិត្ត ស្រើបស្រាលគន់គិត ដល់ក្ដីចំណង់, រសាប់រសាយ ពុំស្ដាយសីលសង្ឃ គន់គិតក្ដួចចង់ សិក្ខាសេពមាតុគ្រាម ៗ ទ្រង់ជ្រាបហើយត្រាស់ ទេសនាច្បាប់ច្បាស់ កុំឲ្យវិមវាម ចិត្តចង់តាម ស្រើប កម្រើបដោយកាម- មគុណតក់តាម មន្ទិលសិក្ខា, ឲ្យភិក្ខុផង ដឹងដោយទំនង ដំណើរ ភរិយា ស្ត្រីទាំងសែសិប បុគ្គល ស្រីណា បង្កិនទ្រព្យ នោះជប់ចរិត ៗ ស្រីចិត្តបើកសព្ទ ទាំបី ជន្លាប់ ស្រីអាសូរចិត្ត មានដល់ប្ដី ឯស្រីតែងគិត ភាគាំងាយ ប្ដីពិត ជប់តំរិកិរិយា, អំពើទុច្ចរិត ទាំងប្រាំគំនិត ប្រមូលផ្ដុំគ្នា ត្រូវ មួយរយកត់ តាមបទព្រះបា. បើលោកទេសនា ក្នុងព្រះគាថ ៗ

បត្តាឡីសា- យ ហ៊ាណេហិ ឥត្ថី សាមិកំ អត្តានេ ត្តា ប្រែបាលីយំ ស្រីភរិយា លោកតាំង សែសិប គំនិត៖

១- នេះដើមស្រីភរិយា អៀនតែប្ដី ពុំព្រមតាមចិត្ត ប្ដីផ្ដាំដូចម្ដេច អៀនគេបមិនស្រៀត ឯស្រីសុចរិត គ្មានអៀនប្ដី ៗ

២- ស្រីមាយាឥតស្លៃ ចូលដេកច្រើនប្រែ ខ្នងឲ្យស្វាមី ហាក់ ដូចហាក់ណាយ ចង់ផាយរកថ្មី មោះប្តូរសេចក្តី ចង់រួមសប្រាណ,

៣- ស្រីមាយាលាយបើគ ក្តលក់លួចបើក ទ្វារលប ចេញបាន ទៅរកគេឯង ប្រឡែងសើចសាន្ត ហើយវិលមកបាន ដេកក្ញើព្រងើយ ។

៤- ស្រីមាយាឥតល់គរុណា ប្តីគង់ប្ដីគាត់ ប្ដីពាល់ខ្ទបហើយ គេចទាត់គេចខ្ទះ បម្រះគោះគើយ ធ្វើហាក់ធ្វើហើយ មិនមានចំណង់,

៥- ស្រីមាយាអប្រិយ ប្តីរួមវេណី ប្រកែកការឌ ដង្ហើម ធំតូច ហាក់ដូចមិនចង់ ព្រោះអាក់គៀនគត្តិ មោះចង់ស្នេហា ។

៦- ស្រីមាយាខូសរ ប្តីទីងរួមរ៉ូ ណាប្រែពាលថា ឈឺ ក្បាលឈឺពោះ គឺដោះវាផា វាតាស់ចិត្តវា វាចង់ដៃរទេ,

៧- ស្រីមាយាកោលី ចូលដេកទីងប្ដី ធ្វើផាដល់ខែ ហើយ ស្លៀកចង់ក្បិន ថាមិនទំនេរ ដល់ប្តីវាយដេរ នាំឲ្យមានមោះ ។

៨- ស្រីមាយាមុខរឹង ដឹងជាប្តីទីង រួមក្បែរស្ពាញស្មុះ ផាស់ គេឯងឡើង រកក្ហើងបន្ទុះ ព្រោះខឹងពុំនោះ ចង់បាកស្វាមី,

៩- ស្រីមាយាបម្រើ ប្ដីពុំដែលស្មើ ធ្វើមុខខ្ញរខ្ញី ក្រិណ ស្រស់ក្រិណក្រៀម ក្រិណស្ងៀមក្រិណស្ដី ព្រោះធុញទ្រាន់ប្ដី តូចចិត្ត គំនិត ។

១០- ស្រីមាយាខិចខូច បំណាំប្ដីបង់ ពុំឲ្យតាមចិត្ត បង់នោះឲ្យនេះ បង្ខើះចេញពិត ព្រោះជនណាយចិត្ត គិតបែកចេញក្រៅ,

១១- ស្រីមាយាលាយអាស ចង់ឲ្យប្ដីប្រុស ចេញពីលំនៅ ទឹបានបើកលេង ត្បាងនឹងអ្នកក្រៅ ប្ដីមានបើទៅ អាងនឹងពន្ទឹក ។

១២- ស្រីមាយាល្បិចល្បែង ប្ដីទៅឆ្ងាយលេង ពាល់ល្ងាចពាល់ព្រឹក សើចលេងតាមចិត្ត គ្មានគិតគ្មានទឹក គ្មានភ្នករឭក អាណិតស្រឡាញ់,

១៣- ស្រីមាយាម៉ានោម៉ានះ ប្ដីមកដល់ផ្ទះ ដាំទុក្ខគ្មានខ្ញាញ់ កញ្ចបកញ្ចូវ ក្រមូវគន្ធាញ់ ផ្សិតចិត្តស្រឡាញ់ សស្រួលទៅផ្សឹង(១) ។

១៤- ស្រីមាយាលែបខាយ ឃើញមុខសហាយ ធ្វើយំឲ្យដឹង អន្ទុយសូតស្ងប់ សញ្ជប់សោតសឹង ធ្វើប្រាប់ដំណឹង ពីខ្លួនទុក្ខទល់,

១៥- ស្រីមាយាលាយអាស ឃើញប្រុសមិនខ្មាស ធ្វើរិះរកគល សាកសួរសុំថ្នាំ ផ្ដែផ្ដាំខ្វាយខ្វល់ នោះចង់ជួបយល់ មុខមិត្រក្នុងក្រៅ ។

១៦- ស្រីមាយាសស្រាញ់ ឃើញមុខសំឡាញ់ ដែលចង់

---

១- សម័យនិពន្ធច្បាប់នេះ ប្រើពាក្យនេះថា " ផ្សឹង " បានជាមានសម្ពត្សប្រុងខ្លួន នៅឃ្លាមុខថា ដឹង-សឹង-ដំណឹង ។ តែសម័យបច្ចុប្បន្ន ប្រើពាក្យនេះថា " ផ្សេង " ។

ចិត្តទៅ មើលៗហើយសើច ធ្វើកើចស្ងៀមនៅ បន្តិចមើលទៅ

ឲ្យប្រុសស្នេហា,

១៧- ស្រីមាយាពេកាគ្គិត(១) ឃើញប្រុសត្រូវចិត្ត ទ្រាំ

ព្រួចចិន្តា ដាក់ក្អែកមមុយ កន្ទុយនេត្រា លួចមើលរេរ ញញឹមធ្វើព្រងើយ ។

១៨- ស្រីមាយាគ្និចក្នាក់ ឃើញប្រុសសុំឡូក កាន់ខេះ

នោះហើយ លើកឡើងថើបថៃ លួចបែរមើលដើយ ថើបទៀតធ្វើតើយ

ញញឹមចោលចេញ,

១៩- ស្រីមាយាពិត ៗ ឃើញប្រុសត្រូវចិត្ត ធ្វើជាម្នាម្នេញ

ជិនឆ្អន់ត្រគោះ គំមោះគិតពេញ ចិត្តចង់លេញ សេពសុខស្នេហា ។

២០- ស្រីមាយាវេះវេ ឃើញប្រុសមានគេ នៅផង់ច្រើនគ្នា

ធ្វើជាព្រងើយ កន្ទើយសោះសា តែស្ងាត់មើលជា ស្រដីចប្រាក,

២១- ស្រីមាយាចេះគ្គិត(២) ឃើញប្រុសធ្វើស្និទ្ធ និយាយ

សួរសាក នៅផ្ទះនៅវាល ស្រើបស្រាលសើចក្អាក ទើបបន្ទិចពាក្យ ទៅ

ប្រុសលលេញ ។

២២- ស្រីមាយាមែនឆ្មួន ឃើញប្រុសតែតួន កិះក្រេបក

---

១-២ សម័យនិពន្ធច្បាប់នេះប្រើពាក្យនេះថា "គ្គិត" បានជាមានសម្ពស្សចុងផ្ទួននៅប្អូនទុំ

ជាស្និទ្ធ ។ តែសម័យបច្ចុប្បន្នប្រើជា "ក្តាត់" ។

បេញ កាច់ម្រាមទាំងដប់ ពត់សព្វដៃម៉ិញ ដ្បិតអៀនស្រឡាញ់ នឹងប្រុសអាត្មា,

២៣-ស្រីមាយា ៗ ល្បែង ឃើញប្រុសធ្វើក្បែង យកដើងព័ន្ធ គ្នា ទះពោតធ្ងេះដី ធ្វើស្ទីមាត់រា លួចឈ្មៀងនេត្រា សំឡក់ធ្វើព្រើយ ៗ

២៤-ស្រីមាយាគិរិយា ឃើញប្រុសធ្វើជា ប្រហោង ព្រងើយ ទុនគួសដីលេង តែឯងតធ្វើយ លួចសំឡក់ហើយ ញញឹម ទុនចុះ,

២៥-ស្រីមាយាល្បិចល្បែង ឃើញប្រុសធ្វើឯង លេងនេះ លេងនោះ លេងលាយអំពើ លេងធ្វើម៉េះម៉ោះ ឲ្យប្រុសកាន់កោះ គ្រេកគ្រេវហួទ័យ ៗ

២៦-ស្រីមាយាគ្មានពិត ឃើញប្រុសដៃក្បិត សំពត់អាវស្បៃ ស្ទួមចង្កេះផ្អៀង មើលមៀងប៉ប្រៃ សំឡក់វិលវៃ ឈរនៅព្រងើយ,

២៧-ស្រីមាយាអំពើ ឃើញប្រុសប្រែធ្វើ មិតពត់ខ្លួនដើយ មុខមៀងក្រឡេក ចុងភ្នែករឿយៗ អង្គុយព្រងើយ ហាក់មិនស្នេហា ៗ

២៨-ស្រីមាយាយល់ប្រុស ធ្វើអ្វីឲ្យជ្រុះ ជជុះរុះរ៉ា មៀង មើលយល់ជាក់ ប្រែកគ្រធ្វើជា រើសរួចហើយរា មើលទៀតញញឹម,

២៩-ស្រីមាយាឆ្នើងឆ្និត ឃើញប្រុសស្អាតស្អិត លាបប្រេង

បំប្រើម ផាត់មុខណាំនួន ក្រមួនមាត់ទឹម សៀតសំពត់ត្រឹម ដណ្ដប់ពាតប៉ិៗ

៣០- ស្រីមាយាឥតស្រាន្ត ឃើញប្រុសហើយបាន សរ.តើចំណី អ្វីៗក្ដីណា ហៅគ្នាមកពី ផ្ដោះផ្ដង់សំដី ញញឹមបញ្ចោរ,

៣១- ស្រីមាយាស្រើបស្រស់ ឃើញប្រុសសម្រស់ សម្រួលអំពើ ដេកដើរឈរគង់-គុយគង់តែធ្វើ អំពើបញ្ចោរ បញ្ចាលស្នេហា ។

៣២- ស្រីមាយាលាយបើគា ប្រុសបាត់ដើរល្ងើក ឆ្កួតលលា ក្សិណសើចក្សិណយំ ក្សិណពុំចរចា ដង្ហិតប្រាជ្ញា ចង់សេពកាមគុណ ,

៣៣- ស្រីមាយាក្រោតក្រើតក្យ កំណាញ់ឥតគិត មិនចង់ធ្វើបុណ្យ មិនធ្វើទានសីល ព្រោះខ្លួលស៊ីបស៊ុន ស៊ីបាយផ្ដាច់ផ្ដុន ប្រុសអស់ពីប្រាណ ។

៣៤- ស្រីមាយាលាមគា ចេះតែគុហក រៀបធ្វើនជាន កំកកំភូត គេស្អូតត្រង់គ្មាន វិលវេះមិនមាន ទប់ទល់សំដី,

៣៥- ស្រីមាយាញិកញ៉ក ឃើញប្រុសបញ្ចុក សរតើចំណី គ្មានស៊ីឯងសើច គេបក់ចសុំខ្លួ ឲ្យប្រុសភ្ជាប់ប្រិយ ជឹងបុគ្គលឯង ៗ

៣៦- ស្រីមាយាគាឆ្នង ឃើញប្រុសបានគ្មាន ពទុបប្រៃ-ខ្សែង ៈគ្មានធ្វើមេ្ដចគាប់ ធ្វើត្រាប់ជាល្បែង ឲ្យប្រុសយល់វែង ចាប់ចិត្តស្រាលស្រើប.

(នៅមានត)

# រឿងសព្វសិទ្ធិ

របស់ហ្លួនភក្តីអក្សរ គង់ លោក ប៊ូ-ប៉ូ ចម្លងពីសាស្ត្រាស្លឹករឹត

## កាព្យពាក្យ ៧

អហំអញខ្ញុំសូមវន្ទី លើកកំរអញ្ជលីខុនអភិវាទ ដូចកលកោសុម
បទុមជាតិ ក្រាបក្រោមវរបាទយុគល ៗ នៃព្រះអរហំស្រីសម្មា ជាមកុដ
លោកាជាទីតាំង ព្រះអង្គជាសុខទិទ្ទុំ ជាគ្រូអស់ទាំងឥន្ទ្រាព្រហ្ម ៗ
ទេវតាគន្ធព្វគ្រប់គ្រុឌា ព្យាដនាគាមារយក្សយម មនុស្សសត្វសុះសព្វកត
តូចធំ មូលមកបង្គំក្រាបប្រញាប់ប្រាណ ៗ ព្រះអង្គទូន្មានសព្វហ្វូងសត្វ នាំ
កាត់ឆ្លងវដ្តសង្សារសាគរ ផុតពីកងទុក្ខសុខសម្រាន្ត ដាក់ដល់ត្រើយត្រាណ
សិវាល័យ ៗ ព្រះធម៌នាគាបរិយវង្ស ទ្រង់សម្រេចករុណាថ្កើងថ្លាថ្លៃ ប្រទាន
ព្រះធម៌បិដកត្រ័យ ទុកជាវិន័យសាមញ្ញសត្វ ៗ ខ្ញុំថ្វាយបង្គំព្រះធម្មា
សេដ្ឋាវេកាចបំបាត់ កិលេសសង្សារឲ្យស្ងួនថ្ងាត់ ដោយព្រះបរមត្ថ
អាវុធថ្លា ៗ ជាអរិយទ្រព្យគាប់បរិសុទ្ធ សម្រាប់កុលបុត្រក្នុងសាសនា
ទន្ទេញសូត្ររៀនប្រៀនប្រាជ្ញា ជាផ្លូវយាត្រាទៅនិព្វាន ៗ បញ្ញត្តិបាត់
ថាកុំប្រមាទ ស្តាប់ពុទ្ធវាទដំបូន្មាន ឲ្យរក្សាសីលបំពេញទាន ទុកទៅ
ជាយានប្រសើរជា ៗ ឲ្យខំបំបាត់កាត់លោភា ទោសាមោហាកុំឧន្ហា
ចង់បានមិនត្រូវផ្លូវធម្មា វេលាអស់ជន្មបានអបាយ ៗ គួរគេះត្រិះត្រាប់ច្បាប់

ប្រពៃ តាមព្រះវិន័យលោកអតិប្រាយ ធ្វើបុណ្យដាក់បាត្រចំណីបាយ បំណាយជាស្បៀងលៀងអាត្មា ៗ ខ្ញុំថ្វាយបង្គំព្រះសង្ឃសម ប្រសើរឧត្តមទ្រង់សិក្ខា ជាតិជាកុលបុត្រពុទ្ធសាសនា ទ្រង់ព្រះមេត្តាសាសនាថ្លៃ ៗ ដែលលោកបណ្ឌិតដល់បដិវេធ ឃើញហេតុសង្ខារជាបច្ច័យ ហើយកាត់លោភគន់កម្មក្ខ័យ សុខក្ស័យរួចចាកភពគតណ្ហា ៗ កាលព្រះអង្គទ្រង់ជិតនិព្វាន ឈ្មោះញាណបារីកទុកសាសនា ឲ្យគ្រប់ប្រាំពាន់ព្រះវស្សា ជាពុទ្ធធម្មតាប្រពៃណី ៗ សម្ដេចសព្វញ្ញូមុនីនាថ ជាន់ទុកព្រះបាទលើគិរី ទុកព្រះពុទ្ធរូបស្តូបមុនី ព្រះមហាពោធិ៍បិដកត្រ័យ ៗ ព្រោះដ្បិតសម្ដេចព្រះសាស្ដា ជ្រាបថាសាសនាឯក្រោយក្រៃ នឹងសាបសូន្យទៅទើបទ្រង់ផ្ញើទុកបូជនេយ្យទាំងប្រាំស្ថាន ៗ ឲ្យអស់សព្វសត្វផងនានា គ្រាន់ជាទីពឹងបម្រុងប្រាណ នមស្ការបូជាទៀនធូបបាន ផលបុណ្យក្សេមក្សាន្តនិទ្ទុក្ខា ៗ

អហំអញខ្ញុំសូមចារចង ល្បើកល្បងពាយរឿងរ៉ាវហារ ពាក្យសៀមប្រែមកជាភាសា ខេមរកម្ពុជាជាតិ ៗ ទោះបីលើសលោះខុសពាក្យពិតពុំពិតពុំជួនសួនឃ្លាឃ្លាត សូមជួយជៀតចែងដោយខ្មីឃ្មាត សម្រាប់ជូនញាតិអ្នកបងជីង ៗ និទានបក្សាជាប្រថម គួរសមនឹងស្ដាប់ស័ព្ទដំណើងដំណើរនេះខ្ញុំខំប្រែប្រឹង សុទ្ធសឹងមានមកពីបាលីៗព្រះពុទ្ធព្រះអង្គទ្រង់បន្ទូបន្ទាយប្រាយប្រែកែសេចក្ដី ប្រោសអស់អរហន្តភិក្ខុនី ដើម្បីឲ្យបានលុះមគ្គផល ៗ ខ្ញុំហ៊ានកក្ដីអក្សរគន់ រិះគិតកែគុនតាមយោបល់ យកបុណ្យៈ

សូមបានសុខសួស្តីសល់ សូមដល់រួចចាកទុក្ខភ័យផង ៗ ព្រះពុទ្ធសកពជ ព្រះសាសនា អតិក្កន្តាហួសកន្ទង ពីរពាន់ប្រាំបួនរយសែសិបសង រំលង ទៅហើយដោយគណនា ៗ ហេមន្តរដូវដប់កើតខែ មិគសិរសៀលថ្ងៃ អង្គារ ឆ្នាំកុរឯកស័កដោយវេលា សុរិយាជ្រេជ្រៀលរសៀលថ្ងៃ ៗ តែង កន្លងលេខពីរទីប៉ុយរ៉ូ ទៅឃុំនគ្រីស្ទូលប្រសើរថ្ងៃ បត្តមុខកំពេញពជក្រុង ក្រៃ រិះគិតកែខែតាមប្រាជ្ញា ៗ

និពានជំណាលព្រះមុនី សពេជ្ញមោលីចមរលោកា ចាប់ជាតិជា សត្វសកុណា នៅព្រៃហេមពាន្តព្រឹក្សាសាន្ត ៗ កាលព្រះអង្គគង់គង់ដេតពន សុគន្ធកុដិកែវសុរិកាន ជាទីសុខោរហោស្ថាន សម្រេចសម្រាន្តកិច្ចាស្មោះ សរ ៗ សម័យមួយនោះអស់អរហន្ត ប្រេនក្រៃអនន្តមកកុះករ គង់ធម្ម-សភាថ្ងៃបវរ សឹងតែត្រេកអរសរសើរថា ៗ ឳព្រះចមមកុដផុតត្រៃភព ព្រះគុណលើសលុបឥតឧបមា ជាគ្រូនៃព្រហ្មមនុស្សទេវតា ទ្រង់ព្រះមេត្តា ករុណាសត្វ ៗ សន្សំសេពសាងបារមីថ្ងៃ បួនអសង្ខៃយ្យសែនយូរក្កាត់ បំពេញពិព្យាយាមទើបកាត់ បានលុះអរហត្តស្ថានបរិយា ៗ ដើម្បីករុណិត គិតស្រោចស្រង់ សព្វសត្វកាត់បង់សង្សារ ឲ្យសូន្យចាកទុក្ខបានសុខា គឺមហានគរទិញ្ញានពិត ៗ កាលនោះសម្តេចព្រះជិនស្រី ជ្រាបអាថិ សេចក្តីដោយញាណពិត ទើបយាងព្រះបាទស្អាតវិចិត្រ តាមពុទ្ធនិម្មិត រៀងមកដល់ ៗ ធម្មសភាសុវណ្ណា ឡើងគង់ក្រឡាព្រះគំនាល់ ទើបទ្រង់

ដម្រិះដោយយោបល់ ត្រាស់សួរកិច្ចកលដល់សាវតារ ។ អាវុសោហៃ អស់ភិក្ខុផង ស្ដីអ្វីអឺងកង់លើសាលា មិនទំប្រតិបត្តិហាត់សិក្សា វិន័យ សិក្ខាអាថ៌បាលី ។ ទើបព្រះមោគ្គល្លានក្រាបទូលសួង ថាអស់ភិក្ខុផង កើតស្រដី សរសើរត្រឹមតែព្រះបារមី អម្ចាស់សិរសីលើសលោកា ។ សម្ដេចសព្វញ្ញូព្រះពុទ្ធអង្គ បានទ្រង់សណ្ដាប់ដោយបញ្ញា ទើបបើកព្រះ ឱស្ឋប្រោសតបថា ហៃបាមោគ្គល្លានមានបារមី ។ អ្នកនាំព្រះសង្ឃមក សរសើរ ដំណើរពីអង្គអញដិនស្រី ថាមានអានុភាពលើសកុពត្រ័យ មោះ មិនតែឥឡូវនេះណា ។ ពីកាលកពត៌នខ័ណ្ឌកប្បខាំង កំបាំងបាត់ស្ងាត់ អតីតា យូរណាស់កាលនោះតញតថា· គតកើតជាមហាបុរសរ័តន៍ មួយមានមហិទ្ធិឫទ្ធិក្លាហាន និត្យនៅដែនដានស្ថានជនបទ ជាបុត្រប្រសើរ ថ្លៃប្រាកដ ប្រកបហ្វត់ចត់ព្រះកាយា ។ ហើយមានសម្លាញ់អញដិតជាក់ មួយពាន់មួយនាក់ស្នេហា តែពោធិវង្សទ្រង់បេស្ដា មានព្រះប្រាជ្ញា លើសអ្នកផង ។ អ្នកលាមាតាបិតាបរ ស្វែងរៀនសិល្បសរដូចបំណង ចង់បេះដានមិត្រពិតដាច្បង ថ្វែកក្រែកទូងគ្មួសវនា ។ សម្ដេចជិនវង្ស ពង្សពុទ្ធរ័តន៍ នាំហេតុតាមបទព្រះគាថា មកជាសណ្ដាប់ប្រាប់សាវកា ឲ្យជាហេតុហើយទ្រង់ឈឹងឈប់ ។

គ្រានោះដំនុំព្រះអរហន្ត ក្រាបទូលនិមន្តព្រះបមភព ថាសូមសន្តោស ប្រោសប្រារព្ធ ទឹងបានដឹងគ្រប់សោះសង្ស័យ ។

អង្គសម្ដេចលោកវិទូ បើកឱស្ឋមបូត្រាស់ថាហៃ ភិក្ខុអើយកាល ព្រេងអន្លើងព្រៃ ប្រើនអសន្ធៃយ្យឥតឧបមា ៗ ក្នុងដើមជាតកខុក្កនិបាត នៃមហាសិបជាតិនោះតថា- គតកើតជាជាតិសកុណា នៅក្នុងព្រឹក្សអគ្គា- ស្ថាន ព្រៃនោះលង្វើកវិសាលវែង ទូលាយត្រខណ្ឌទស្សនាន ជាជៀប- កម្ពស់ជាតិតិចបាន រួមប្រាណនៃបទនីទានីបក្សី ៗ នៅជាមួយគ្នារួមសុខ ទុក្ខ មានទាំងសំបុកជាកូនខ្ចី ចាបឈ្មោលតែងហើរកេចំណី ទុកនាង បក្សីឲ្យគេក្ស ៗ ថែទាំចាំកូននៅសំបុក ជាទីឥតទុក្ខជាសុខា សម័យ- មួយនោះព្រះសុរិយា រៀងរះជ្រះថ្លាព្រហាមស្មោះ ៗ ចាបឈ្មោល ហើរចាកលំនៅស្ថាន ទៅតែមួយប្រាណហើរផ្ដេកផ្ដោះ ចូលពនា ល័យព្រៃបោះ ហើរហោះទៅទៀបទីស្រះស្រី ៗ មួយមានឈូកឈរផុះ រហង់ លំដង់ស្បក្តិផចក្តិលណី រីកបែកបុប្ផាកេសរថ្មី ដោយព្រះសុរិយេ ទើបរៀងរះ ៗ បក្សាទត្រាក្រឡេកឃើញ បុប្ផាវិមលពណ៌ល្អល្អះ បោះ ត្ដុយធៀងធាបស្លាបឧទុះ ចុះទៅក្នុងស្រះទំចំកផ្កា ៗ លួមព្រះទិនករបេរ ត្រៀយត្រៀន អណ្ដែតលយលៀនចាកព្រឹក្សា ស្រូបរស្ងួនបញ្ចាស់វង់ព្រះសុរិ- យា ចំហាយខ្ញុំណ្ហាចំផែនដី ៗ រីឯបុស្សបុងក្នុងស្រះនោះ លង់លុះត្រាតែ ព្រះសុរិយេ រត់រួតក្ដាប់ជិតទៅវិញខ្ចី ចាបនោះឥតបើងំងទៀយណា ៗ កំពុងចិកចាប់ជាតិបទុម លោភជ្រួចគេរំរួបកាយា រួតរិតជិតជាប់នៅក្នុងផ្កា បក្សាភិតភ័យក្រៃស្មើរស្លាប់ ៗ ទំព្រឹងបម្រះក្រឡាសស្លុះ នៅក្នុងផ្កានោះជា

ប្រញាប់ ខ្លួនសោតម្លួលដួលផ្ងារផ្កាប់ ស្ទើរនឹងសូន្យស័ព្ទស្លាប់អាសា ៗ រំពឹងថប់ញ័រញាប់អស់អង្គប្រាណ រំខានខ្សឹកខ្សួលគួលសោកថា ឱះឱ! ភរិយាបុត្រស្នេហា សមនឹកបិតាស្វាមីបាត់ ៗ ខំស្វែងត្រាច់មករកផលា ព្រោះក្តីស្នេហាសង្សារសត្វ ឥឡូវតំនៀរតៀរមកកាត់ ឲ្យកាយខ្វាយខ្វាត់ ដូច្នេះណា ៗ ខ្លួនស្លាប់តាមកម្មមិនចាំគិត អាណិតតែកូននោះឯកា ប្រពន្ធនៅក្រោយសមខ្លោចផ្សា តោមនស្សទុក្ខាឃ្លាតចំណី ៗ រឿងនេះលើកទុកពុំបានថែម ទំនងចាត់សំដែងទៅបក្សី កាលបក្សាហើរចេញទៅវិញ ថ្ងៃនោះព្រោះក្តីអកុសល ៗ បង្កើតភ្លើងព្រៃឆេះព្រៃព្រឹក្ស សន្ធៅសន្ធឹកដោយស័ព្ទខ្សាល់ ពោកបក់ផ្សែងផ្សាចលាចល កាលទៀបមកដល់ទីសកុណី ៗ

នាងចាបឃើញជាក់ធ្លាក់ផ្តើមកក្ក រំជួលក្តួលចុកសព្វមំសី ស្រយុតស្រយង់អង្គឥតបី ហើរចាកឃ្លាតខ្ចីព្រោះភ័យខ្លាំង ៗ ស្ទើញស្ទុះឆ្វេឆ្វាផ្សាដោយគិត អាណិតដល់កូនស្ងៀមរំ សោការន្ធត់ស្លុតស្លាំងកាំង ញាប់ញ័រអស់ទាំងអង្គកាយា ៗ អន្ទះអន្ទែងវិរងផ្សាខ្លោច កណ្តោចកណ្តែងឯងឯកា ទ្រូញថាឱកូនសង្សារ សមក្ស័យជីវិតមិននេះហើយ ៗ ឱអ្នកជាប្តីថ្លៃពន្លក ម្តេចពុំឃើញមកណាអ្នកអើយ ភ្លើងព្រៃឆេះកូនសូន្យឥតត្រើយ កូនអើយម៉ែសមអ្នកក្តៅផ្សា ។ សោកះហើយនាងចាបធាបហើរចុះ ទើបហាចំពុះនៃអាត្មា ចឹកពាំនាំកូនសង្សារ ទឹងចរយាត្រាកំពុំបាន ៗ អនិច្ចាចាបញីញ័រអស់អង្គ ហើរចាក់វិលវង់សោកប្រះប្រាណ ទ្រូញថាឱកូន

ស្ងួនកល្យាណ ម៉េះសមម្ដាយខានឃើញមាសថ្លៃ ៗ ហើយថ្ងៃនអន្ទ្រ អស់ទេព្រ័ក្ស ស្ថិតស្ថានសំណាក់និត្យនៅៗ ជ្រោះជ្រោយសូមជួយគិតកែ ខៃ ឲ្យកូនរួចក្ស័យគ្រោះនេះណា ៗ ភ្លើងនោះឆេះរាលដាលត្រដួច ឆាប ក្របសំបុកខែបក្សា ឆេះពេលកូនស្ងួនឡសង្វាក, ក្បាលក្ស័យដីរាំពេចខ្ចី ៗ នាងដីចាបឃើញកូនក្ស័យដូច្នោះ ស្តុតស្តក់ពង់ពោះបាត់ស្មារតី ទន្ទ្ញថា ឥកូនស្ងួនពិសី គម្ពុមកកាត់ឲ្យខ្លាត់បង់ ៗ តាំងកូនក៏ស្ងួនឡក្នុងភ្លើងព្រៃ តាំងថ្ងៃក៏ព្រាត់ប្រាត់តាំងអគ្គិ ព្រឹកមិញនៅជុំគ្នាហោង ទឹកឡើងមិនបង់រស់ ជិះឡើយ ៗ រស់នៅធ្វើអ្វីឥប្រយោជន៍ ឲ្យតែវិវាទមិនគ្រោះស្បើយ បើ ភ្លើងឆេះផ្លាញស្លាប់ឲ្យហើយ ទ្រូងអើយសោះទីងងើលទនា ៗ

ថ្ងៃពីចាបឈ្មោលដែលចូលផាប់ នៅក្នុងស្រទាប់បុប្ផា លង់លុះ ព្រលប់យប់សន្ធ្យា ចន្ទ្រារឿងរះជ្រះនភា សន្សើមសស្រោកធ្លាក់សស្រោក ចុះដោកត្រពាំងព្រឹក្សាសព្វមាលី រីកពាយរំសាយស្រទាប់ក្ដី បក្សាបពីក្នុងបុស្បៀៗ ហើយហើរម្នាក់ឯងវិវេកពេក ផ្ទោះផ្ទុកផ្ទួចក្ដាមតាមរស្មី ព្រះចន្ទ្រក្នុងពង ក្នុងរាត្រី ឥតបីបង្អង់លង់ឡើយណា ៗ គ្មានសេកេសរដែលរួបអគ្គិ ក្រអូបធុំ ហ្វង់ជាប់កាយា លុះហើរមកដល់ទីអាត្មា ឃើញព្រៃព្រឹក្សាភ្លើងឆេះអស់ បាត់តាំងសំបុកដែលទុកកូន ឈឹងស្ងាត់សោះស្ងួនក្នុងសានគ្រោះ ប្រពន្ធ ក៏បាត់ពិតបំពោះ គឺមោះជាកម្មនៃអាត្មា ៗ រំងឺរតញ័រញាប់ចំប្រប់ប្រាណ

រំភានខ្សឹកខ្សួលក្ដួលសោកា ឲកូនកំសត់បុត្រទ្វេហា ទៅណាពុំឃើញដូចសព្វកាល ៗ

គ្រានោះឯនាងសកុណី ឃើញប្ដីមកដល់សោកដាស្ដាល ទើបចេញពីព្រៃព្រឹក្សាសាល មកផ្ដាលស្រដីឲ្យប្ដីថា ៗ អ្នកឯងទៅព្រៃបានសប្បាយ ត្រេកទីងសហាយត្រូវចិន្តា ឥឡូវកើតព្រៃនេះព្រឹក្សា នេះកូនទ្វេហាមរណៈក្ស័យ ៗ សព្វកាលរៀងមកមកគ្រប់ពេល មិនដែលខាតខានខុសមួយថ្ងៃ គ្រានេះប្រែចិត្តកាត់អាល័យ គេចវេះដោះដៃរកស្មៀតថ្មី ៗ យល់ជាត្រូវចិត្តស៊ិទ្ធស្នេហ៍ ស្មោះស្ម័គ្រស្រឡាញ់ពេញបេតី ថែមធុំខ្ចិនផ្កាជាប់កូនស្រី ទីងមកធ្វើអ្វីអ្នកថ្ងៃកាយ ៗ ហើយធ្វើជាន័គព្រេកកូន ដែលសូន្យប្រល័យក្ស័យអន្តពយ នរណាមិនដឹងកលក្លែងក្លាយ ឲបាយមាយាជាពាក្យពិត ៗ

សកុណាបក្សាបានស្ដែងស្ដាប់ ហារស័ព្ទប្រពន្ធប្រចណ្ឌចិត្ត ទើបឆ្លើយនាងអើយបងវែងគិត ដល់មិត្តមាសស្ងួនទីងកូនថ្ងៃ ៗ តែបងបានហើរដើរដោយជ្រោះ ឃើញស្រះមួយនោះណាតែវថ្ងៃ មានផ្កាឈូករីកច្រើនក្រាស់ក្រៃ មងសោតប្រស្រ័យបុះបិតផ្កា ៗ ដូនថ្ងៃរៀងរះស្រឡះពិត ផ្កាឈូកសោតរីតរួតកាយា ដោយសារកុំដៅព្រះសុរិយា បងជាប់ក្នុងផ្កាចេញពុំបាន ៗ លុះសែងអាទិត្យអស្ដង្គត បរផុតបិទឆ្នាំងព្រះសុរិធានសទៀមពាយរុះបុះសព្វស្ថាន ទើបបានផ្កាសោតរីកឡើងវិញ ៗ ឯបងក៏រួច

អង្គការយា ហិចហើរយាត្រាមកនេះវិញ នាងកុំកាន់ចិត្តកើតទុក្ខមេញ ទោមនស្សទេនួញថាហ្នោះឡើយ ៗ

បក្សីស្តាប់ជាក់ទើបតបថា កុំប្រែប្រាជ្ញាណាអ្នកអើយ ប្រសិនអាល័យខ្ញុំមែនហើយ ម្តេចធ្វើតោះតើយដូច្នោះណា ៗ វិស័យកើតជាប្រពន្ធប្តី គប្បីជួនទុក្ខជួនសុខា ទើបហៅស្រឡាញ់ពេញស្នេហា នេះមាត់តែថាអាណិតណាស់ ៗ ឯចិត្តបែកបែរប្រែប្រឹនទៀត គិតរកថ្មីទៀតចោលឯចាស់ ហើយថាផ្កាគ្រាប់ជាប់គន់ស្រះ ខ្ញុំជួនចិត្តប្រាស់យ៉ាងនេះឯង ៗ ហ៊ានចោលតាលក្លើងនេះសំបុក ធ្លាក់កូនត្រសុកទៅក្នុងព្រៃ គ្មានសល់រូបសោះអស់ឆ្អឹងឆ្អែង ឃើញមានតែផ្សែងហុយដគ្គាល ៗ ឲកូនសំឡាញ់ពេញចិត្តស្ម័គ្រ ក្តាយទឹកដើមអ្នកធ្លាក់ថើមក្តួល ម្តាយសោកពិលាបសព្វខ្សែកខ្សួល ឈឺទៀបនេះឈ្លួលញ៉ាំពន់ពោះ ៗ

បក្សាបៀតបែរតែចាំស្តាប់ ប្រពន្ធសារសព្វស្តីបញ្ចោះ ទឹងទំណួប្រចណ្ឌប្រដែងឈ្មោះ គំពេះគំពមតាមគ្រោធា ៗ ទើបលោមប្រលោមថាព្រលឹង មាសទឹងទឹងថ្ងៃពៅពិសា បងត្រូវគិតឥតមាយា ជាក់ជាស្រឡាញ់ពេញពោះ ៗ ដែលពុំបានមកដោយពេលពិត ដោយសារផ្កាតែស្មើស្មាប់សោះ គម្រើយគម្មកាត់ឲ្យបាត់ឈ្មោះ សូមប្អូនសង្គ្រោះអត់ទោសា ៗ

(មានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

## ទំនៀមបេះក្រវាញ

### អ្នកស្រី ពេជ-សល់ រៀបរៀង

ក្រវាញជាប្រភេទលម្វឹយ៉ាន មានផ្លែប្រើជាថ្នាំកែរោគ មានដើមតូច ៗ សំប៉ែត ៗ មានស្រទាប់ដូចដើមខ្ញាយ ឬដើមរមៀត ហើយមានកំពស់ពីដំបូងជា ២០ ឬ ៣០ សង់ទីម៉ែត្រ មានក្រពុំផ្កាដុះចេញពីគល់ ដូចជាផ្កាខ្ញី ។ ផ្លែក្រវាញមានជាតិហឹរ ។ ដើមក្រវាញមានសភាពខុសគ្នាពីដើមក្រកោបន្តិច គឺ ដើមក្រកោមានកំពស់ដល់ទៅមួយម៉ែត្រ ឬ មួយម៉ែត្រកន្លះដូចដើមរំដេង ឯដើមក្រវាញមានកំពស់តែ ២-៣ តឹកប៉ុណ្ណោះ ។

ក្រវាញជារបស់ក្រ មិនមានដុះគ្រប់ស្រុកទេ ច្រើនដុះតែនៅដីភ្នំ ហើយដោយដុំ ៗ ផង គេឃើញមាននៅក្នុងខេត្តពោធិសាត់ បាត់ដំបង កំពង់ស្ពឺ ។ បណ្តាខេត្តទាំង ៣ នេះ ខេត្តពោធិសាត់មានដុះក្រវាញច្រើនជាងគេ ។ ក្រវាញចាប់ផ្កាផ្លែតាំងពីខែផល្គុន ដល់ទៅខែអាសាធ ទើបទុំល្មមបេះ ប៉ុន្តែគេពុំទាន់ហ៊ានបេះទេ ទាល់តែមានបង្គាប់ពីចៅហ្វាយស្រុកទៅមេឃុំ ៗ បង្គាប់ទៅមេព្រៃ (គឺមនុស្សម្នាក់ដែលអ្នកស្រុកគេតាំងឡើងសម្រាប់មើលការខុសត្រូវក្នុងព្រៃក្រវាញនោះ) ឲ្យទៅមើលក្រវាញសិនបើឃើញថាល្មមបេះបានហើយ ទើបមេព្រៃធ្វើសេចក្តីរាយការណ៍ជូនទៅមេឃុំ ៗ ធ្វើសេចក្តីប្តឹងទៅចៅហ្វាយស្រុក ៗ កំណត់ថ្ងៃឲ្យបេះក្រវាញ

ទើបហៅថាបេះ ប៉ុន្តែនៅខាងខែត្រពោធិ៍សាត់ គេមិនហៅថាបេះក្រវាញទេ គេថា "ឡើងក្រវាញ" ទៅវិញ ។

អ្នកឡើងក្រវាញសុទ្ធតែជាតិព័រដែលមានសណ្ដាប់ធ្នាប់ ខុសអំពីខ្មែរអ្នកស្រុកយើងធម្មតា ។ ជាតិព័រនេះជាមនុស្សមួយពួកដែលពុំសូវរវះរវាមទីងការបង់បានបង់មានទេ គេធ្វើស្រែចំការដែរ តែជាការបន្ទាប់បន្សំទេ គេចូលចិត្តរកស៊ីតែឡើងក្រវាញ ។ ឯទីលំនៅទៀតសោតក៏មិនបានជាធំដុំមាំមួនល្អដែរ ច្រើនតែជាខ្ទមតូច ៗ នៅក្បែរដើមភ្នំ ។ ជាតិព័រ ច្រើនលែងខ្លួនទទេ ស្លៀកតែសំពត់ឥតអាវទាំងស្រីទាំងប្រុស ។ ជាតិនេះ កាន់សាសនាព្រាហ្មណ៍ ប៉ុន្តែជាតិនេះ មានបន្តិចបន្តួចនូវជាការយើងដូចជាពុទ្ធសាសនិកខ្មែរធម្មតាដែរ ។ នៅក្នុងខែត្រពោធិ៍សាត់ ស្រុកលាជមានតែ ៥ ឃុំទេ ដែលមានក្រវាញ គឺឃុំតាំងលួច ១ ឃុំតាពេញពង់១, ឃុំប្រកព្រាល ១, ឃុំស្រែតាំងយ៉ា ១, ឃុំពាមព្រុស ១ ។

នៅពេលដែលត្រូវឡើងក្រវាញ គេរៀបធ្វើពិធីបូជាយ៉ាងខ្ជាប់ខ្ជួន មានសង់ពេនក្រលនៅកន្ទុងអ្នកតា សម្រាប់ដេកនៅដកពេញគ្រប់៣ថ្ងៃ ដែលឡើងក្រវាញ ហើយពិធីនេះ ត្រូវឡើងតំណាលគ្នាទាំង ៥ ឃុំផង ។

មេព្រៃរៀបបូជាអ្នកតាហើយ ប្រាប់ទៅពួកអ្នកឡើងក្រវាញថា កាលណាពួកស្នូរគេវាយគង ៣ ដង ត្រូវរៀបចំប្រដាប់ប្រដាឡើងក្រវាញគ្រប់គ្នា។ លុះធ្វើពិធីបូជាបួងសួងសុំសេចក្ដីសុខឲ្យអ្នកឡើងក្រវាញហើយ មេព្រៃវាយ

គង់ ៣ ដង អ្នកឡើងក្រវាញក៏នាំគ្នាយកសក្រែក ដងវែក ជាល ទៅឡើងក្រវាញរៀងខ្លួន ។

អ្នកឡើងក្រវាញទាំងប៉ុន្មាន ត្រូវតែមិននិយាយពាក្យអាសគ្រាម មិនស្លៀកខោ មិនស្លៀកសំពត់សំឡូយ មិនពាក់មួក មិនជូតក្បាល មិនដើរកាត់ផ្លូវរបស់គេ គឺអ្នកណាឡើងផ្លូវណា ឡើងផ្លូវនោះទៅ មិនហៅឈ្មោះសត្វថា ខ្លា ពស់...ជាដើម ។

គេឲ្យស្លៀកតែសំពត់បង់ក្បិន បើឈ្មោះណា កន្លងគ្រហាមទាំងប៉ុន្មានយ៉ាង ខាងលើនេះ អ្នកតានឹងបណ្ដាលហេតុឲ្យឃើញការមិនស្រួលមួយរំពេច មានឲ្យឃើញខ្លាជាដើម ។ បើឃើញដូច្នេះ អ្នកឡើងក្រវាញត្រូវទៅប្រាប់មេព្រៃឲ្យគេលក់ជាស្រាមួយដប អង្ករ ១០ នាល សំពត់ ១ សារ ហើយអ្នកប្រព្រឹត្តខុស ត្រូវទៅសុំទោសចំពោះមុខអ្នកតាជាមួយនឹងមេព្រៃ ទើបរួចគ្រោះ ។ បើពុំនោះទេ នឹងត្រូវខ្លាអូសយកទៅស៊ី ដំរីព្រេច ពស់ចឹក ជ្រូកព្រៃខាំពុំខាន, ជួនកាល អ្នកប្រព្រឹត្តខុសមិនដឹងខ្លួន ក៏ស្រាប់តែមានភ្លៀងធ្លាក់មកទាំងយប់ទាំងថ្ងៃឥតស្រាកស្រាន នាំឲ្យរំខានដល់អ្នកឡើងក្រវាញ ឃើញដូច្នោះ មេព្រៃគេអាចដឹងបានថា មានអ្នកណាមួយខុសគ្រហាម បើរកមុខមិនឃើញ មេព្រៃត្រូវប្រជុំអ្នកឡើងក្រវាញទាំងអស់មកធ្វើបកិច្ចដោយឲ្យធ្វើគប់ភ្លើងមួយៗម្នាក់ អុជឲ្យឆេះឡើង ហើយដេញឆ្លួលគ្នាវែកទៅមកនៅចំពោះមុខអ្នកតា ទើបភ្លៀងរាំងវិញ ។

លុះគ្រប់កំណត់វារៈ៣ថ្ងៃ ដែលគេត្រូវឈប់ឡើងក្រវាញ អ្នកឡើងទាំងប៉ុន្មានត្រូវកើបផ្លែផលរបស់ខ្លួនមកទុកក្នុងរៀងៗខ្លួន ហើយមេព្រៃគេដើរកត់ត្រាឲ្យដឹងថាបានចំនួនប៉ុន្មាន រួចគេកាត់ឲ្យអ្នកបេះម្នាក់២៥នាឡិ សល់ពីនោះគេកត់បញ្ជូនទៅសាលាស្រុក ដើម្បីលក់ជាផ្លូវការ ។

រឿងពិចារណាលើនេះ គឺអធិប្បាយចំពោះតែទំនៀមខេត្តពោធិ៍សាត់ ឯទំនៀមនៅក្នុងខេត្តកំពតនិងកំពង់ស្ពឺ ដែលជាខេត្តមានដុះក្រវាញដែរនោះ មានទំនៀមល្អៀងគ្នាបន្តិចៗ ដូចជាមេព្រៃ នៅខាងខេត្តកំពត គេហៅថាគ្រួសួន នៅក្នុងខ្មែរខ្លះគេហៅថាគាបារស្មឹង ។ នៅខាងខេត្តកំពត បើអ្នកឡើងក្រវាញប្រព្រឹត្តខុសត្រណម គ្រួសួនគេមិនលក់ដូចនៅខាងខេត្តពោធិ៍សាត់ទេ គេធ្វើទណ្ឌកម្មយ៉ាងធ្ងន់ដល់អ្នកមានទោសនោះដោយគេដាក់ថ្នាក់ គឺគេចងជើងទាំងពីរ ដៃទាំងពីរភ្ជាប់ទៅនឹងក ហើយគេយកឈើទៅលើពោះឲ្យខ្លួនកោងឡើង ទើបគេវាយ១០០រំពាត់ ប៉ុន្តែរំពាត់នោះគេចងរួមគ្នាតែមួយបាច់ចំនួន១០០ក្នុងៗ ការធ្វើទណ្ឌកម្ម និងការលក់ទាំងប៉ុន្មានខាងលើនេះ សុទ្ធតែជាកិច្ចរំដោះគ្រោះ អ្នកដែលខុសត្រណមទេ បើពុំនោះទេ អ្នកប្រព្រឹត្តខុសនឹងត្រូវបង់ជីវិតដោយខ្លាស៊ី ដំរីព្រៃបួសពស់ចឹក ។

ពណ៌នាអំពីទំនៀមបេះក្រវាញចប់តែប៉ុណ្ណេះ ។

# សុភាសិត ជាតិ ស៊ីរី និង លីបង់

លោក ភ៉ីយ-ប៊ុក ប្រែរៀបរៀង

---

១- កាលណាគេនិយាយពីខ្លួន, មនុស្សស្មោះត្រង់បង្ហាញមុខឲ្យគេឃើញភ្លាម ។

២- បើអ្នកមានចរិយាល្អហើយ, អ្នកកុំខ្លាចអ្នកណាសោះឡើយ ។

៣- បើមនុស្សស្មោះត្រង់ដួលធ្លាក់ដល់ដី, គាត់មិនបេះឈឺទេ ។

៤- អ្នកណាលួចម្ជុលពីថ្ងៃនេះ, អ្នកនោះ ដល់ទៅអនាគតនឹងលួចឧដ្ឋ ។

៥- អ្នកណាគ្មានទោសកំហុស, អ្នកនោះនឹងគ្មានសេចក្ដីខ្មាសអៀនទេ ។

៦- ចាំចាស់ជរាគ្រាំគ្រា ទើបតែប្រែចរិយា, នេះជាការប្រព្រឹត្តិលាមកបំផុត ។

៧- ចូរអ្នកចៀសចេញឲ្យឆ្ងាយ ពីសេចក្ដីអាក្រក់ ហើយចូរអ្នកប្រៀនទៅ ។

៨- ចោរមកលួចយើង វាមិនប្រាប់យើងទេ ។

៩- កិត្តិសព្ទល្អ គឺជាថ្លៃនៃជីវភាព ។

១០- ហុចដៃទៅចាប់ដៃគេ តែត្រូវរាប់ម្រាមដៃឯងជាមុន ។

១១- ដុំសម្រាមមិនដែលកាច់បាក់ទេ ។

១២- កេរ្តិ៍ឈ្មោះល្អ ប្រសើរជាងមានគោគទ្រព្យ ។

១៣- នារីដែលមានចរិយាអាក្រក់ មិនជាទីភ័យនៃជនដទៃឡើយ។

១៤- គេថាចំពោះបុគ្គលម្នាក់ៗ ធ្វើយ៉ាងណា បានយ៉ាងនោះ ។

១៥- មុននឹងចេញពីទឹកនៃងឬ ជំណែង, មនុស្សតែងមិនខ្វាចនឹងប្រព្រឹត្តទុច្ចរិត ដោយញឹកញាប់ ។

១៦- ព្រះអាទិត្យអស្តង្គតទៅហើយ, សេចក្តីលំបាកគ្រប់យ៉ាងនៅតែមាន ។

១៧- បើជាគេពាសនាដេកលក់, ចូរអ្នកកុំដេកលក់តាម ។

១៨- ត្រូវគិតបរាជ័យ មុនគិតជោគជ័យ ។

១៩- រាំបាអ្នកធំ កុំជិតពេក ។

២០- គិតគូរមុនធ្វើ ។

២១- មួយរៀលនៅក្នុងហោប៉ៅ ប្រសើរជាងដប់រៀល នៅក្រៅហោប៉ៅ ។

២២- ការអាក្រក់បន្តិចបន្តួច ល្បីលេចឮជាងការល្អធំសម្បើមអស្ចារ្យ ។

២៣ វត្ថុតូចហើយបិតថេរ ប្រសើរជាងវត្ថុធំដែលមិនបិតថេរ ។

២៤- បើអ្នកចង់រក្សាគេហដ្ឋានឲ្យបានសុខ, ចូរអ្នកមើលមនុស្សទាំងអស់ថាជាចោរ ។

២៥- បើអ្នកចង់លួចទ្រព្យចោរ, ចូរអ្នកយកប្រាក់របស់អ្នកទៅលាក់ក្នុងផ្ទះចោរ ។

២៦- បើអ្នកដេញពួកកំសាកតាល់ដើម, ពួកកំសាកនោះរត់ត្រឡប់ជាមានសេចក្ដីក្លាហានទៅវិញ ។ ត្រូវចាំសុភាសិតមួយថា «ដេញទាន់កុំជាន់កែង» ។

២៧- អ្នកកុំត្រាប់ទៅតាមទំនើត អ្នកទិញដល់គេ ។

២៨- កុំឲ្យយឺតពេក, ឆាប់ពេក ។

២៩- គ្មានអ្នកណាគេចផុតពីគ្រោះថ្នាក់ តែត្រូវរាំងជាទ័រទ្ទ ។

៣០- ខ្ញុំមិនទាន់ស្លាប់ទេ, តែខ្ញុំឃើញអ្នកទាំងឡាយស្លាប់ ។

៣១- អ្នកណាឈានជើងវែងពេក, មុខជារយះជើងមិនខាន ។

៣២- អ្នកណាដែលមិនមកលេងនឹងឯង, ត្រូវឯងទៅលេងផ្ទះអ្នកនោះ ។

៣៣- មនុស្សរស់ដោយសារចិត្ត សត្វតិរច្ឆានរស់ដោយសារពេញ ។

៣៤- កាលបើយើងឃើញសេចក្ដីទុក្ខលំបាករបស់អ្នកដទៃ, ទុក្ខលំបាកចំពោះខ្លួនដូចជាធាយទន់ទូលរង ។

៣៥- សេចក្តីត្រូវការជាបុព្វហេតុ ឲ្យកើតមធ្យោបាយ ។

៣៦- មនុស្សគមានគំនិតប្រសើរ ជាងមនុស្សល្ងង់ចង់និយាយ ។

៣៧- ផ្លូវកណ្តាលជាផ្លូវដ៏ប្រសើរ ។

៣៨- ដើម្បីនឹងសម្រេចទៅតាមវត្តបំណង, បុរសត្រូវធ្វើជាស្ត្រី ។

៣៩- ការបន្ទោសត្រូវតែទៅតាមវិជ្ជា ។

៤០- ស៊ូឲ្យខ្វាក់ភ្នែក កុំឲ្យខ្វាក់ចិត្ត ។

៤១- ក្មេងតូចចេះដឹង ប្រសើរជាងចាស់ ។

៤២- សុភាសិតមិនដែលកុហកទេ ។

៤៣- អ្នកប្រាជ្ញមានកំហុស ដែលគេពិនិត្យជាងគេ ។

៤៤- បើអ្នកប្រើមនុស្សមានប្រាជ្ញា, មិនបាច់ទូន្មានច្រើនទេ, បើអ្នកប្រើមនុស្សល្ងង់ ត្រូវចាត់មនុស្សម្នាក់ ឲ្យដើរតាមប្រកិតពីក្រោយ ។

៤៥- អ្នកណាស្បថញយ, អ្នកនោះកុហកញឹក ។

៤៦- ចូរអ្នកស្រឡាញ់សច្ចធម៌, បើទុកជាសច្ចធម៌នោះនាំឲ្យអ្នកមានទុក្ខលំបាកខ្លាំង, ហើយចូរអ្នកស្អប់ពាក្យកុហក, បើទុកជាកុហកនោះនាំឲ្យបានសេចក្តីសុខ ។

៤៧- ពោលពាក្យពិត ជាអំបិលនៃមនុស្ស ហើយទុកឲ្យអ្នកកុហកជាដូចម្តេច ក៏ជាចុះ ។

៤៨- ចូរអ្នកអង្គុយខ្ទះវៀចចុះ តែចូរពោលពាក្យត្រង់ ។

៤៩- កុហកបានត្រឹមតែបាយពេលល្ងាចទេ, តែដល់ពេលបាយព្រឹកតទៅទៀតមិនបានទេ ។

៥០- អ្នកកុហក, បើទុកជានិយាយពាក្យពិត, មិនយូរមិនឆាប់គេលែងជឿ ។

៥១- បើពាក្យកុហកជួយស្រោចស្រង់មនុស្សបាន, ពាក្យពិតក៏កាន់តែជួយស្រោចស្រង់មនុស្សបាន ច្រើនជាងនោះទៅទៀត ។

៥២- ត្រូវដេញតាមមនុស្សកុហក រហូតដល់មាត់ទ្វារផ្ទះ ។

៥៣- អ្នកណាដែលមានចិត្តស្មោះស្ម័គ្រនឹងអ្នកដទៃ, អ្នកនោះនឹងចែកកោតទ្រព្យគ្នាបាន ។

៥៤- អ្នកណាដែលមានបំណងចង់ពោលពាក្យកុហក, អ្នកនោះខំព្យាយាមរកសាក្សីពីចម្ងាយ ។

៥៥- មនុស្សនីមួយ ៗ ត្រូវកាត់នំទៅតាមធ្មេញរបស់ខ្លួន ។

៥៦- បើកាលណាគេរកដោះសាមិនរួច, គេទៅជានិយាយច្រើន ។

៥៧- វត្ថុអ្វីដែលគេហាមប្រាម ចេះតែចង់បាន, វត្ថុអ្វីដែលគេលាក់លៀម ចេះតែចង់ឃើញ ។

៥៨- ពាក្យល្អមួយម៉ាត់, មានតម្លៃជាងពាក្យអាក្រក់ ១០ ម៉ាត់ ។

៥៩- កុំឲ្យមនុស្សល្ងង់ខ្ចីទ្រព្យទាំងឡាយ , ព្រោះវាយល់ថា វត្ថុនោះ ជារបស់វា ។

៦០- កុំឲ្យធ្វើចិត្តរឹងត្អឹងពេក , អ្នកនឹងដួលធ្លាក់ ។

៦១- មនុស្សក្នុងពេលខ្វះ, ត្រូវធ្វើខ្វាក់ , គ , ថ្លង់ ។

៦២- មនុស្សខ្វះ ប្រឡាំសំពោរឯងថា ទឹកឃ្មុំ ។

៦៣- គ្មានអ្នកណាពោលថា "ខ្ញុំអាក្រក់" ។

៦៤- អ្នកណាគាប់ទទួលពាក្យផ្សុសប៉ោ ដែលគេពោលចំពោះខ្លួន ដោយឥតមានទោមនស្ស, អ្នកនោះនឹងធ្វើកិច្ចឲ្យពបស្មើនឹងផែនដីបាន ។

៦៥- ការធ្វើចិត្តមធ្យម ចំពោះកិត្តិយសដែលខ្លួនបាន មានតម្លៃស្មើនឹងកិត្តិយសទាំងឡាយ ។

៦៦- វត្ថុដែលធ្វើដោយចិត្តសប្បាយរីករាយ គ្មានអស់កំឡាំងទេ ។

៦៧- អ្នកណាគ្មានអស់កំឡាំង, អ្នកនោះនឹងសម្រាកពុំបាន ។

៦៨- អ្នកណាមិនដាក់លេខ ៩, មិនអាចរាប់លេខ ១០ ឃើញ ។

៦៩- អ្នកណាមិនធ្លាប់ក្បៀសទឹកនឹងបាតដៃខ្លួនទាន , អ្នកនោះស្រេកជានិច្ច ។

៧០- បើមនុស្សធំទន់ពោលថា ខ្ញុំឃ្លាន ឲ្យជឿចុះ , បើពោលថា ខ្ញុំអស់កំឡាំង កុំជឿសោះឡើយ ។

៧១- កុំចាំសំណាងយកទ្រព្យសម្បត្តិមកប្រគល់ឲ្យ ត្រូវតែរត់ដេញទ្រព្យសម្បត្តិពីក្រោយ ។

៧២- ភោគទ្រព្យនឹងអាចរកបាន ដោយប្រើឧបាយកល ។

៧៣- ការអ្វីដែលអ្នកធ្វើខ្លួនឯងមិនបាន, កុំឲ្យអ្នកឯទៀតធ្វើ ។

៧៤- ការអ្វីដែលអ្នកធ្វើបានលទ្ធផលដោយលំបាក ជាការប្រសើរ ។

៧៥- មិនបាច់កើតទុក្ខទេ, ចំពោះវត្ថុដែលគេរកបានទៀត ។

៧៦- វត្ថុដែលទិញមិនបាន, ម្ដេចក៏ចង់បានធ្វើអ្វី ។

៧៧- ស្លាប់ដោយកិត្តិយស ប្រសើរជាងរស់នៅដោយខ្មាសគេ ។

៧៨- ស៊ូធ្វើការថ្ងៃអាទិត្យនិងថ្ងៃបុណ្យ, កុំឲ្យតែៈទៅពឹងពាក់បងប្អូនមានភោគទ្រព្យ ។

៧៩- អ្នកដែលស្តាប់មិនឮតាមត្រចៀក, គេធ្វើឲ្យស្តាប់ឮតាមកញ្ចឹងក ។

៨០- បើអ្នកស្ទៀកពាក់ ត្រូវពាក់ខោ-អាវសូត្រ, បើចង់ទៅ-មកញឹកញយ, ចូរអ្នកទៅមកដំណាក់ព្រះអង្គម្ចាស់ ។

៨១- ដំបូងសន្យាប្រាក់, ដល់ចុងក្រោយចាយចុះតាមចិត្ត ។

៨២- មនុស្សកំណាញ់បង្ហាញនូវគុណវិបត្តិ ហើយកាត់នូវមេត្រីភាព ។

៨៣- មនុស្សកំណាញ់ នឹងស្លាប់លំបាកពន់ពេក ។

៨៤- មនុស្សកំណាញ់ មិនដែលដើរចំពីមុខផ្ទះអ្នកដទៃ ។

៨៥- ស្រឡាញ់ប្រាក់របស់ឯង, អ្នកនឹងគ្មានចិត្តស្អប់ប្រាក់របស់ឯង អ្នកនឹងគ្មានបច្ចាមិត្ត ។

៨៦- មានភោគទ្រព្យ គ្មានសប្បុរសធម៌ ប្រៀបដូចជារុក្ខជាតិឥតផ្លែ ។

៨៧- អ្នកណាគិតតែពីអាហារឆ្មា, មុខជាត្រូវកណ្ដុរស៊ីត្រចៀក ។

៨៨- វត្ថុដែលបានមកគ្មានអស់កំឡាំង ក៏ត្រូវចាយទៅវិញឥតស្ដាយ ។

៨៩- ជញ្ជាំងទាប, អ្នកណាក៏ហ៊ានលោតលើង ។

៩០- ខ្លួនតូច, សកម្មភាពធំ ។

៩១- ចូរអ្នកបង្ហាញធ្មេញអ្នក, ហើយអ្នកផងទាំងពួងនឹងខ្លាចឯង ។

៩២- ក្បាលស្រាលធ្វើឲ្យដើរអស់កំឡាំង ។

៩៣- វាយទឹក វានៅតែទឹកដដែល ។

៩៤- បើអ្នកអាក់អន់ចិត្ត, រាប់ពី ១ ដល់ ១០, ការអាក់អន់ចិត្តនឹងបាត់ឯង, បើអ្នកខឹងរាប់ពី ១ ដល់ ១០០, ការខឹងនឹងបាត់ ។

៩៥- ការស្ងប់ស្ងៀមប្រសើរជាងការក្ដៅក្រហាយ ។

៩៦- ខន្តីជាកូនសោនៃការធ្វើសេចក្ដីទុក្ខឲ្យស្បើយទៅ ។

៩៧- ខ្ទីធ្វើកំពូលកុំឲ្យរាបស្មើ ។

៩៨- កុំនិយាយការប្រស្រ័យនឹងអ្នកស្រវឹងស្រា ព្រោះថាមិនយូរមិនឆាប់ អ្នកស្រវឹងស្រានោះ គង់តែនឹងជិះខ្នងជាមិនខាន ។

៩៩- កុំឲ្យស្រោះប្រោះផង់ដីនឹងដំណាំង ឬចង់ដឹងថា ខែប្ដូរទឹកមានមក ដល់ពេលណា, គេតាំងអស់ផល់ពេលវេលាវាមកឯង ។

១០០- បើគ្នាស្លុតទៅមាត់ប្រាំងហើយ, កុំឲ្យប្រានគ្នា, ឯងនឹងធ្វើឲ្យអ្នកនោះធ្លាក់ទៅមិនខាន ។

១០១- អពមង្គលមកដល់មុន, សុភមង្គលមកដល់ក្រោយ ។

១០២- ពេលវេលាសម្លាប់ខ្លួនឯង ។

១០៣- អ្នកណាបរិភោគទឹកទន្លេ, នឹងលេបទឹកស្អុយបានដោយងាយ ។

១០៤- ការពិសោធន៍ ជាសាលាមួយសំខាន់បំផុត ។

១០៥- ការទម្លាប់មិនលះបង់ចោលយើង, លុះតែយើងចូលក្ដារមឈូស ។

១០៦- គេស្រឡាញ់មនុស្ស តាមសំលៀកបំពាក់ ។

១០៧- មុខល្អជាចំណុចឲ្យស្គាល់ថា ចរិយាល្អ ។

១០៨- ភ្នែកធំ មិនប្រសើរផល់ភ្នែកតូច ។

១០៩- ប្រមុះធំ មានដំឡៃធំ ។

១១០- បើអ្នកចង់ស្ថិតនៅកណ្ដាលពួកភ្នែកខ្វាក់ទាំងពីរ ត្រូវយកដៃបាំងភ្នែកទាំងពីរ ។

១១១- បើគេគ្មានបង្គម គេមិនបរិភោគសាច់ទេ ។

១១២- ចូរអ្នកមើលខ្លួនឯងក្នុងកញ្ចក់ អ្នកនឹងដឹងដំឡៃខ្លួន ។

១១៣- អ្នកមានភ្នែកម្ខាង ជាស្ដេចនៃអ្នកមានភ្នែកខ្វាក់ទាំងពីរខាង ។

១១៤- មនុស្សតូចទាប ធ្វើការទំនាស់ ៧០ ដង ក្នុង ១ ថ្ងៃ ។

១១៥- បើជោគវាសនាលះបង់អ្នក, ចូរអ្នកធ្វើដូចមនុស្សស្លាប់, បើជោគវាសនាចូលមកស្ថិតនៅក្នុងចិត្តអ្នក ចូរអ្នកដើរទៅខាងមុខ ។

១១៦- កាលណាគេទទឹក, គេមិនខ្លាចទឹកភ្លៀងទេ ។

១១៧- ដំណឹងអាក្រក់ផ្សាយឆាប់ ។

១១៨- វាសនាវិលដូចកង់រទេះ, ពេលវេលាជាអ្នកប្រាប់ ។

១១៩- វាសនាវិល ជួនកាលសម្រាប់អ្នកធំ ជួនកាលសម្រាប់អ្នកតូចតាច ។

១២០- ពិភពលោកជាជណ្ដើរ ដែលមនុស្សឡើងទៅ តាមវេនគ្នាម្នាក់ម្ដង ៗ ។

១២១- ម្រាមដៃអ្នកមិនស្មើគ្នាទេ ។

(នៅមានត)

រឿងសាមកុក

## កណ្ឌទី ៣៤

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសច្ចានស្នេហាជាតិ ។

ដែលខុងបេងនិយាយដូច្នោះ ដោយបានពាំគ្រោះឃើញកុងស្វនតម្រាថា តទៅមុខ ឡេវពីនឹងបានជាធំសម្រេចផែនដីក្នុងកុក ១, ប៊ូកុក ១, ស៊ុនគួនកុក ១, ជាសាមកុក ដូច្នេះបានជាស្រុកចិនទាំងពួងនោះ សេចក្ដីពប់អានថា ខុងបេងជាអ្នកប្រាជ្ញមានដម្រិះប្រាជ្ញា បេះដឹងមើលតម្រារហូតទៅខាងមុខ ជាទីសរសើរពេញស្រុកជពបមកដល់សព្វថ្ងៃនេះ ។

ខណៈកាលឡេវពីបានស្ដាប់ខុងបេងប្រាប់ដូច្នោះ ក៏គំនាប់ហើយថា បើដូច្នោះ ខ្ញុំសូមអញ្ជើញលោកទៅនៅជួយធ្វើរាជការ ជួយទំនុកបំរុងណែនាំពន្យល់ខ្ញុំតទៅ ។ ខុងបេងឆ្លើយថា ខ្លួនខ្ញុំបានជាមនុស្ស

ស្រុកស្រែក្រៅមានជម្រះប្រាជ្ញាតិច ធ្លាប់ធ្វើការតែដោយបែបទាបថោក ដែលលោកនឹងហៅយកទៅធ្វើជការ រំលឹកប្រដៅលោកនោះ ជាការល្អិតសុខុមណាស់ ក្រែងធ្វើទៅមិនបាន កនឹងនាំឲ្យខូចការរបស់លោក ៗ ទៀវពីបានឮដូច្នោះ ក៏តអ្វីថា បើលោកមិនបានទៅជួយទំនុកបំរុងផែនដីហើយ អាណាប្រជានុរាស្ត្រទាំងពួង ក៏នឹងបានសេចក្តីក្តៅក្រហាយ ទៀវពីនិយាយហើយ ក៏សោកាកិលាបនូវបន្ទាបជ្រុលជ្រប់សញ្ជប់សញ្ជឹង មិនងើបមុខសោះ ៗ ខុនបេងឃើញដូច្នោះក៏យល់ថា ទៀវពីមានសេចក្តីប្រាថ្នាស្រឡាញ់ពេញចិត្តដោយពិតត្រង់មែន ទើបនិយាយថា បើលោកមានសេចក្តីស្នេហ៍ស្រឡាញ់ខ្ញុំបាទជាប្រាកដមែនហើយ ក៏កុំយំសោកជាទុក្ខព្រួយឡើយ ខ្លួនខ្ញុំក៏នឹងទ្រាំ ទៅជួយធ្វើការពជការជូនលោកតទៅ ទោះបីបើខ្ញុំបាទ នឹងយល់ឃើញការធ្ងន់ស្រាលប្រការដូចម្តេចក៏ ក៏នឹងជួយទំនុកបំរុងទៅតាមសតិបញ្ញានឹងកំឡាំង កុំឲ្យលោកព្រួយឡើយ ៗ ទៀវពីឮហើយក៏មានអំណរណាស់ ទើបហៅគួនអ៊ូ, ទៀវហ៊ុយឲ្យចូលមកគោរពគំនាប់ខុនបេងតាមសេចក្តីសមគួរ ហើយយកទាំងរបស់ទ្រព្យគឺព្រែនឹងមាសប្រាក់ ដែលយកមកនោះ ជូនទៅខុនបេងជាបណ្ណាការ ៗ

ខុនបេងទទួលយករបស់ទ្រព្យនោះហើយ ក៏ឃាត់ទៀវពី, គួនអ៊ូ, ទៀវហ៊ុយ ឲ្យនៅទទួលដំណេក ១ យប់ លុះព្រឹកឡើងទើបហៅដូកាត់កិនជាប្អូនមក ហើយប្រាប់ថា ដ្បិតទៀវពីមានសេចក្តីឧស្សាហ៍ស្វះស្វែងមក

រកបានដល់ ៣ គ្រាហើយ ម្ដាយនិយាយអង្វរគេឡូបនៅជួយធ្វើការ ទំនុកបំរុង លុះខុនបេននឹកគិតប្រយោជន៍ឲ្យខ្លួនទៅនោះ ក៏មានចិត្តអាណិត ពីព្រោះឡៅពីមកនិយាយដោយសុចរិត ហេតុនេះ ទើបផ្ដាច់ចិត្តទៅ នៅជាមួយនឹងឡៅពី នៅនោះក្រោយប្ដូរល្ងាចក្សាគ្រប់គោស្រែចំការ នឹងបណ្ដាទ្រព្យរបស់តាំងពីដូនតាទុកឲ្យលួច ក៏បើឲ្យខ្លួនចាត់ចែងកាយជាអស្សារ ឥតការ ប៉ុនេះទៅជួយឡៅពីបានសម្រេចការជាប្រយោជន៍គន់ផែនដី ហើយ ក៏នឹងត្រឡប់មកនៅធ្វើស្រែចំការគេស៊ីជាមួយគ្នាដូចដើមវិញ លុះខុនបេនផ្ដាំទុកដាក់ឲ្យជួកតែកិនជាផ្លូវខ្ទួលសត្វគ្រប់ហើយ ឡៅពី, គួនអ៊ី, ទៀវហ៊ុយក៏គិតលាច់លាដូកាកកិន ទាំងខុនបេនទៅស្រុកសុខរអៀ លុះ ទៅដល់ហើយ ឡៅពីក៏ធ្វើសេចក្ដីការ: ទីងឧបត្ថម្ភទំនុកបំរុងខុនបេនទុក ជាទីគ្រូអាចារ្យ សម្រាប់ឲ្យរៀនមានប្រៀនប្រដៅគាមគ្រប់ការ ទំនងបរិភោគ អាហារក៏រួមសម្រាប់ជាមួយគ្នាជានិច្ចកាល ទោះបីមានការដូចម្ដេចៗ ក៏ ពិគ្រោះប្រឹក្សាគ្រប់កិច្ចការទាំងពួង ស្រេចលើខុនបេនទាំងអស់ ។

លុះនៅមកថ្ងៃមួយនោះ ខុនបេននិយាយនឹងឡៅពីថា ឥឡូវចូច ជីកស្រះ ១ ធំ ទុកក្នុងស្រុកគីជីរហៅថា ស្រះហៀនមុទី ហើយហ៊ឹក ហាត់សេនាទាហានទាំងពួង ឲ្យជំនាញស្ទាញស្ទាត់ក្នុងចម្បាំងដើងទឹក មុខជានឹងលើកទៅវាយយកស្រុកកាំងតាំងជាប្រាកដហើយ សូមឲ្យលោក ប្រើបំរើឲ្យទៅស៊ើបស្ដាប់ការពេជការក្នុងស្រុកកាំងតាំង ទីងជីនពុំដំណឹង

បានប្រឹងប្រៀបរៀបស្រុកទេសឲ្យមាំមួនហើយ ឬនៅឡើយ ៗ ទៀតពីព្ទ ហើយក៏យល់ឃើញផង ទើបប្រើបរើឲ្យចេញទៅស៊ើបស្ដាប់ការឯស្រុកកាំងតាំង ៗ

ឯស៊ុនគួន មានចិត្តមេត្រីស្រឡាញ់អាណាប្រជាជនទាំងពួង ទើបឲ្យសាងផ្ទះថ្មកំពែង ជាលំនៅនៃអ្នកពងការទុកជាទីសម្រាប់អាណា-ប្រជានុរាស្ត្រទាំងពួង ដែលមានទុក្ខក្ដៅក្រហាយចូលមកពិភាក្សាតាំងឲ្យកៅយ៉ុង, ទៀវហៀន ជាធំសម្រាប់ទទួលអ្នកមានតម្រិះប្រាជ្ញាដែលទៅមក ហើយប្រឹងប្រៀបរៀបចំសេនាទាហានបញ្ចុះបញ្ចូលមនុស្សទាំងពួង បានជាច្រើន ឯខតេកជាពួកស្រុកហ្វាយទេ, បៀមជុនជាពួកស្រុកផងសៀ, លើបង៍ពួកស្រុកថៃគួន, ទៀវប៉ែងពួកស្រុកយីឡាំ, ជីហួន, ឡូកចេក ឧង៍ទៀវគ៊ុនជាពួកស្រុកគង៍ង៉ី, ឡេងថងឧង៍សាទជាពួកស្រុកហ្វាយទេ ៩ នាក់នេះ ស៊ុនគួនតាំងទុកជាទីប្រឹក្សា, ឯលឺបង៍ជាពួកស្រុកយីអេង៍, ឡូកស៊ុនជាពួកស្រុកគង៍ង៉ី, ស៊ីសេងពួកស្រុកឡូកសៀ គួ-ជៀង៍ពួកស្រុកគង៍កុន, គេង៍អង៍ពួកស្រុកលោកាំង៍ ៥ នាក់នេះ ស៊ុនគួនតាំងទុកជាសេនាទាហាន ៗ កាលព្រះចៅហៀនតេសោយរាជសម្បត្តិបាន ៧ ឆ្នាំនោះ ចូចូចាត់ថែងទាហានឲ្យទៅរាយស្រុកអ៊ួនសៀវ ទើបមានសំបុត្រទៅដល់ស៊ុនគួនជាសេចក្ដីថា: សូមឲ្យបញ្ជូនកូនប្រុសម្នាក់មកថ្វាយព្រះចៅហៀនតេ ឲ្យធ្វើរាជការក្នុងស្រុកក្រុងជាសេចក្ដីគាប់ប្រសើរ ៗ

ខណៈនោះ ស៊ុនគួនក៏ប្រឹក្សានឹងមាតា ។ ទើបឲ្យហៅទៀវជៀវនឹងជីវយ៉ីទាំង២ នាក់ ចូលមកប្រឹក្សាតាមដែលមានសំបុត្រទៅនោះ ទៀវជៀវឆ្លើយថា ដែលចូចូឲ្យមានសំបុត្រមកដូច្នេះ ក៏តាមប្រវេណីស្រុកទេស ដូចទំនៀមពីដើម បើនឹងមិនបញ្ជូនកូនលោកទៅធ្វើជាការកុនីស្រុកក្រុងទេ កំនង់ខុសដោយទំលាប់ទំនៀម គង់តែចូចូនឹងមានចិត្តព្យាបាទ លើកកងទ័ពមកធ្វើអន្តរាយដល់យើង ហើយយើងក៏កំឡាំងនៅតិច ឃើញថានឹងតស៊ូមិនបាន ។ ជីវយ៉ីបានឮទៀវជៀវនិយាយដូច្នោះ ក៏និយាយនឹងស៊ុនគួនថា សព្វថ្ងៃនេះ ខ្លួនលោកបានជាធំក្នុងស្រុកកាំងតាំង មានស្រុកឡើងដល់ ៦ មណ្ឌល , ទាហានក៏ព្រមព្រៀងសុទ្ធតែស្ម័គ្រស្រឡាញ់លោក មួយទៀតស្បៀងអាហារក៏មិនបានបរិបូណ៌ ដែលនឹងគិតគោរពញញើតខ្លាចចូចូនោះមិនគួរសោះ សូម្បីបើលោកបញ្ជូនកូនទៅហើយ ក៏ដូចជាយកកូនទៅទុកជារបស់បញ្ចាំ តទៅមុខក៏នឹងបានសេចក្តីក្តៅក្រហាយជាច្រើន សូមលោកកុំអាលបញ្ជូនទៅ ពោះបើចូចូនឹងលើកកងទ័ពមកវាយស្រុកយើង ក៏នឹងស៊ូតគ្នាត្រាតែអស់ជម្រះប្រាជ្ញា ។

ឯនាងនឹហ៊ូយ៉េនដែលជាមាតា នឹងស៊ុនគួនបានស្តាប់ជីវយ៉ីនិយាយដូច្នោះក៏យល់ឃើញត្រូវផង ទើបនិយាយនឹងបំរើការសំបុត្រថា ដែលចូចូនឹងឲ្យបញ្ជូនកូនទៅថ្វាយនោះមិនបានទេ អ្នកឯងត្រូវទៅប្រាប់ចូចូ

វិញចុះ ។ គ្រាកាលដែលអ្នកនាំសំបុត្រត្រឡប់វិលទៅប្រាប់ចូទូ ។ ខឹងណាស់ ក៏រៀបចំកងទ័ពលើកទៅវាយស្រុកកាំងតាំង ទទួលកងទ័ពខាងទិសឧត្តរលើកមកវាយស្រុកហ៊ូតោ ក៏បានតតាំងច្បាំងគ្នាជាប់ដៃ ទើបមិនបានលើកទៅវាយស្រុកកាំងតាំងបង្អង់ឈប់ទៅវិញ ។

លុះព្រឹកឡើងចូលឆ្នាំថ្មី ជាខែកត្តិក ស៊ុនគួនក៏រៀបលើកកងទ័ពទូកទៅវាយ ហងចបានតតាំងច្បាំងគ្នាកណ្តាលទន្លេជាពន្លឹក ហងចតទល់មិនបាន ក៏បែកចូលទៅស្រុកឡេងនោះវិញ ទាហានស៊ុនគួនក៏ចុះទូករហោស់ដេញចូលទៅដល់មាត់ព្រែកស្រុកកាំងហែ កាំឡេងជាទាហានហងចច្បាំងទល់គ្នា ហើយបាញ់ធ្នូទៅឡេងតោស្លាប់ ឡេងថងជាកូនអាយុ ១៥ ឆ្នាំ មានកំឡាំងអង់អាចខ្លាំងពូកែ ក៏ចូលដណ្តើមយកសពឡេងតោជាបិតាបាន ។ ខណៈនោះ មានខ្យល់ជំនោរបក់មកខ្លាំងណាស់ កងទ័ពទូកស៊ុនគួនទីងពារទំលាយចូលទៅពុំបាន ក៏លើកថយត្រឡប់វិលមកស្រុកកាំងតាំងវិញ ។

ឯស៊ុនសៀងប្អូនស៊ុនគួន ដែលទៅឈរនៅស្រុកតាន់អៀងនោះ មានគំនិតអាក្រក់ផឹកតែស្រា ស្រវឹងកាចសាហាវ មិនបានប្រណីមេត្តានាម៉ឺន និងបណ្តាស្រ្តីទាំងពួង តែងតែវាយដំប្រចំដាក់ធ្វើទោសផ្តន្ទាផ្សេងៗ អ៊ុយឡាំនិងតៃអ៊ួន ជាបាល័ដ្ឋមានចិត្តខឹងគុំគួន ក៏ទៅគប់គិតគ្នានឹងបៀនហង

ដែលជាមនុស្សស្និទ្ធស្នាលនឹងស៊ិនសៀន គិតនឹងសម្លាប់ស៊ិនសៀនចេញ លុះមកដល់កំណត់ចូលឆ្នាំថ្មី ជាប្រពៃណីទំនៀមទម្លាប់ នាម៉ឺនមុខមន្ត្រីទាំងពួង ត្រូវចូលទៅគំនាប់ស៊ិនសៀន ។ គឺឲ្យរៀបតុលៀងអាហារបណ្ដាមន្ត្រីទាំងពួង នាងឈីហ៊ួយយិនភរិយារបស់ស៊ិនសៀន ដឹងកិច្ចកលដែលនឹងទាយពោះគ្រោះថ្នាក់អាក្រក់ល្អ ក៏ទាយមើលឃើញថា វេលាព្រឹកនេះស្វាមីនឹងមានគ្រោះកាចណាស់ ទើបជំរាបស៊ិនសៀនជាស្វាមីថា ពេលព្រឹកនេះ អ្នកកុំចេញទៅទទួលលៀងពួកមន្ត្រីខុំរាជការនៅទីសាលាកណ្ដាលដូចពេលសព្វដងនោះឡើយ ដ្បិតអ្នកនឹងមានគ្រោះកាចណាស់ ។

ស៊ិនសៀនឮភរិយាឃាត់ហាមដូច្នោះក៏មិនជឿ លុះព្រឹកឡើងជួបជុំមន្ត្រីខុំរាជការ ស៊ិនសៀនក៏ចេញទៅលៀងអាហារនៅសាលាកណ្ដាល លុះនាម៉ឺនគំនាប់បរិភោគអាហារហើយ ទាំងអស់គ្នាក៏លាចេញទៅ ស៊ិន-សៀនក៏ត្រឡប់វិលមកផ្ទះវិញ លុះដើរដល់មាត់ទ្វារ នឹងចូលទៅក្នុងផ្ទះ បៀនហានជាមនុស្សស្និទ្ធដែលដើរដិតមកតាមពីក្រោយ ឃើញស៊ិនសៀនប្រហែសខ្លួនមិនបានរវាំង ក៏ហូតដាវដែលសៀតបង្កប់នោះកាប់ស៊ិនសៀនដួលចុះដាច់ខ្យល់ស្លាប់នៅទីនោះ ១ រំពេច ។ អ៊ីឡាំនឹងតែអ៊ួនក៏ចាប់បៀនហានថាជាក្បត់ ធ្វើប្រទូសរ៉ាយដល់ស៊ិនសៀនជាចៅហ្វាយឯង ឲ្យនាំទៅសម្លាប់ចេញ ហើយក៏រឹបយកទ្រព្យរបស់ស៊ិនសៀនមកប្រមូលទុក

របអ៊ីឡាំឲ្យអះញ៉ញខ្លួននាងឈីហ៊ួយអ៊ិនមកជំពប់ថា ឥឡូវបៀនហានប្រែ ចិត្តក្បត់សម្លាប់ស្វាមីអ្នកឡើងជីវិតទៅហើយ ខ្ញុំក៏បានសងសឹកជំនួសអ្នក ឲ្យយកបៀនហានទៅសម្លាប់ជីវិតចេញ ខ្លួនអ្នកជាស្រីគួរប្រតិបត្តិតាមយើង ទៅចុះ បើប្រសិនមិនព្រមធ្វើកិរិយាយើង ៗ ក៏ត្រូវតែប្រហារជីវិតឲ្យ ស្លាប់ទៅតាមគ្នា ៗ នាងឈីហ៊ួយអ៊ិនក៏ធ្វើកលឧបាយតបថា ខ្លួនខ្ញុំជា ស្រីអត់អំពីស្វាមីទៅហើយ ក៏ជាមនុស្សអភ័ព្វរូបកាយ ប្រុសទាំងឡាយ រមែងមើលងាយប្រមាថណាស់ ដែលអ្នកមានមេត្តាទឹងទុលយកខ្ញុំម្ចាស់ ទុកជាភរិយាតទៅនោះ ខ្ញុំក៏មានសេចក្ដីត្រេកអរពន់ប្រមាណ តែថាវេលា នេះ ខ្លួនខ្ញុំកំពុងមានសេចក្ដីសោកសៅថ្មី ៗ កំពុងតែកាន់ទុក្ខប្ដីមិនទាន់ រលង សែនសំពះតាមទំនៀមប្រពៃណីជាទីគោរពផ្ទះ ខ្ញុំទឹងបេះតែធ្វើ បំភានត្រឡប់ទៅរាប់អានស្រឡាញ់អ្នកភ្លាម ៗ ទៅ ក៏ខ្លាចគេគរហានិន្ទា បើខ្ញុំរួចផុតរះនេះតែ ២-៣ វេលាទៅទៀត ក៏នឹងប្រតិបត្តិអ្នកតាមត្រូវការ ៗ អ៊ីឡាំបានឮពាក្យនាងឈីហ៊ួយអ៊ិនថាដូច្នោះ ក៏សោមនស្សត្រេកអរពន់ ប្រមាណណាស់ ទើបត្រឡប់ទៅកាន់ទីលំនៅវិញ ៗ

នាងឈីហ៊ួយអ៊ិន ក៏ឲ្យមនុស្សជាទីស្និទ្ធស្នាលម្នាក់លបចេញទៅរក ស៊ុនតោ, ប៉ៅអេង ដែលជាខ្ញុំរាជការចាស់របស់ស៊ុនសៀងចូលមក ហើយ យំសោកថា ឥឡូវអ៊ីឡាំនឹងតែអ៊ុនទាំង ២ នាក់នេះ វះគិតដោយគំនិតទុច្ចរិត

ប្រើបៀនហានឲ្យសម្លាប់ស៊ុនសៀនស្លាប់ទៅហើយ ។ រើជញ្ជូនយករបស់ទ្រព្យទាំងប៉ុន្មានទុកជាប្រយោជន៍ខ្លួន ថែមមករុកគួនបង្ខំខ្ញុំយកទៅធ្វើជាភរិយាឲ្យបាន ខ្ញុំក៏ព្រួយព្រាណដោយគិតខ្លាចអំណាចគេ ធ្វើជាអង្វរមិនឲ្យទាន់អញ្ជាស្រ័យ សន្មតថ្ងៃនឹងឲ្យគេមកជួបហើយ តើអ្នកទាំង ២ នាក់ដែលជាទីទុកចិត្តស្និទ្ធរាប់អាននឹងបានជួយសង្គ្រោះខ្ញុំកើតឬទេ ? បើអ្នកអាណិតខ្ញុំក៏ដូចជាអាណិតដល់ស៊ុនសៀនជាប្តីខ្ញុំដែលស្លាប់នោះ សូមឲ្យមានសំបុត្រជាប្រញាប់ទៅដល់ស៊ុនគួនជាបងថ្លៃ ឲ្យជ្រាបហេតុផលទាំងអម្បាលនេះផងចុះ ឯខ្លួនយើងនៅឯណេះ ក៏នឹងគិតទាយសម្លាប់អ៊ុយឡាំ, តៃអ៊ួនឲ្យបានទាំង ២ នាក់ចេញ ។ ឯស៊ុនគោ, ចៅអេងបានឮដូច្នោះក៏ឆ្លើយតបថា ខ្ញុំបាទនេះជាខ្ញុំកន្ទការចាស់របស់ស៊ុនសៀន ។ បានអាណិតអាសូរមេត្តាករុណាព្រះគុណក៏រកទីបំផុតគ្មានឡើយ ដែលបានដឹងថា អ៊ុយឡាំ, តៃអ៊ួនធ្វើប្រទូសរ៉ាយដល់ស្វាមីនៃអ្នក ក៏គិតតែនឹងសងសឹកតបគុណវិញជាដរាប និយាយហើយក៏លាចេញមកកាន់ទីលំនៅវិញ ទើបតែងសំបុត្រតាមរឿងហេតុសព្វគ្រប់ ចាត់បំរើទៅទាំងយប់ទាំងថ្ងៃឲ្យយកទៅឲ្យស៊ុនគួន ។

លុះព្រឹកឡើងថ្ងៃមួយ នាងឈីហ៊ួយក៏ឲ្យហៅស៊ុនគោ, ចៅអេងចូលមកអែបបង្កប់នៅក្បែរគ្រែដំណេក ទើបចាត់ឲ្យតែងតុសែនរំលឹកទៅស្វាមីតាមប្រពៃណីស្រេចហើយ ក៏ដូតទឹកដំរះកាយតែងខ្លួនស្លៀកពាក់ធ្វើ

គិរិយាបថដូចជាមានសេចក្តីស្នេហាស្រឡាញ់ចង់បានស្វាមីថ្មី ។ ឯអ៊ុំឡាំលុះដឹងដំណឹងថា នាងឈីហ៊ួយមិនតែងគ្រឿងសែនខ្មោចប្តីដូច្នោះក៏ទៅរង់ចាំនៅក្បែរទីនោះ ៗ លុះដល់ពេលយប់ នាងឈីហ៊ួយមិនក៏ឲ្យបំរើទៅអញ្ជើញអ៊ុំឡាំចូលមកបរិភោគអាហារ នាងក៏វាក់ស្រាឲ្យអ៊ុំឡាំផឹកស្រវឹងហើយ ក៏ធ្វើបីដូចជាមានចិត្តស្រើបស្រឡាញ់ប្រប់កៃបខ្លួនឲ្យពានពាល់ទៅលើអ៊ុំឡាំជាអ្នកនាំពា ហើយដើរចូលទៅខាងក្នុងដំណេក ៗ អ៊ុំឡាំក៏ដើរតាមទៅ ៗ ខណៈនោះ ស៊ុនកោ, ចៅអេងក៏ស្ទុះចេញមកកាប់អ៊ុំឡាំដួលស្លាប់នៅប្របមាត់ទ្វារ, ហើយនាងឈីហ៊ួយមិនក៏ឲ្យបំរើទៅជំពបតៃអ៊ួនទៀតថា ថ្ងៃនេះជាថ្ងៃល្អ សូមអញ្ជើញលោកទៅពិសាក្រយា តៃអ៊ួនសំគាល់ថាពិត ក៏រៀបខ្លួនចូលទៅ លុះទៅដល់ប្របទ្វារខាងក្នុង ស៊ុនកោ, ចៅអេងក៏ព្រួតគ្នាចាប់ខ្លួនតៃអ៊ួនបានហើយនាំទៅប្រហារជីវិតទៀត រួចលើកតាហានទៅចាប់កិរិយាបុត្រ ទាំងស្ត្រីគេបក្ខពួកអ៊ុំឡាំ ទាំងតៃអ៊ួនសម្លាប់ចេញទាំងអស់ នាងឈីហ៊ួយមិនក៏ឲ្យគាត់យកក្បាលអ៊ុំឡាំនិងតៃអ៊ួនទៅសែនគំនាប់ នៅចំពោះមុខម៉ុងដែលបញ្ចុះសពស្វាមី ៗ

ឯស៊ុនគួនលុះបានទទួលសំបុត្រដឹងសេចក្តីហើយ ក៏មានសេចក្តីក្រៅក្រោធពន់ប្រមាណណាស់ ទើបលើកតាហានខ្ស្រុតទៅដល់ស្រុកតាន់អៀង ឮថានាងឈីហ៊ួយមិន ប្រើឧបាយកលសម្លាប់អ៊ុំឡាំនិងតៃអ៊ួន

បានហើយ ក៏មានសេចក្ដីត្រេកអរណាស់ ទើបតាំងឲ្យស៊ុនកោ, ចៅគេង នៅឈរក្សាស្រុកតាន់គៀង បានរៀបចំស្រុកជាស្រួលបួលស្រេចហើយ ក៏នាំយកនាងឈីហ៊ួយ៉ិនជាប្អូនថ្លៃ លើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ ហើយតាំងជីវយ៉ិជាមេកងទ័ពធំ បង្គាប់បញ្ជាលើសេនាទាហានទាំងពួង សម្រាប់ខាងទូកចម្បាំង ៧ ពាន់ តាំងពីនោះក៏នៅជាសុខសប្បាយក្សេម-ក្សាន្តមករហូតព្រះចៅហៀនតេសោយរាជសម្បត្តិបាន ១២ ឆ្នាំ ។

ដល់ខែកត្តិកខាងខ្នើត នាងឈីហ៊ួយ៉ិនជាមាតាស៊ុនគួនកើតពេកឈឺធ្ងន់ជាប់ ទើបឲ្យហៅខ្លួនជីវយ៉ី នឹងរៀវៀវចូលមកហើយផ្ដាំថា កាលពីដើមខ្លួនយើងជាពួកស្រុកតង់ង៉ី បិតាមាតាស្លាប់នៅក្រោ ចិញ្ចឹមគេក្លា តែបងប្អូន៣នាក់ លុះតមកបានស៊ុនកៀនជាស្វាមី ក៏បង្កើតបុត្របាន៤ នាក់ កាលយើងមានផ្ទៃពោះទម្ងន់ស៊ុនសេកជាបុត្រច្បង បានយល់សប្តិឃើញថា ដួងព្រះចន្ទ្រចូលមកនៅក្នុងផ្ទៃ លុះដល់ទម្ងន់ស៊ុនគួនយល់សប្តិឃើញទៀតថា ដួងព្រះអាទិត្យចូលមកនៅក្នុងផ្ទៃវិញ គ្រូទំនាយថាៈបុត្រយើងទាំង២នាក់នេះ អំណើតទៅទីងបានជាធំ តែស៊ុនសេកនោះអាយុខ្លីដល់នូវសេចក្ដីស្លាប់មុនប្អូន កាលជិតនឹងស្លាប់បានលើកប្រគល់ស្រុកកាំងតាំងទុកឲ្យស៊ុនគួនជាប្អូនធ្វើចៅហ្វាយស្រុកនេះ ឥឡូវខ្លួនយើងឈឺជាទម្ងន់ណាស់ មុខជាមិនរស់រួចជីវិតទេ យើងសូមលាអ្នកទាំង២ឡើយ

បើប្រសិនយើងនឹងស្លាប់ហើយ ចូរអ្នកមានសេចក្ដីអាណិតអាសូរជួយ ណែនាំស៊ិនគួនឲ្យបានសេចក្ដីសុខក្នុងកិច្ចការ រក្សាខេត្រខ័ណ្ឌកុំបោះបង់ ចោលគ្នាឡើយ ហើយនាងនឹហ៊ួយិនក៏ផ្ដាំនាងស៊ិនគួនទៀតថា ប្រសិន តទៅមុខកូននឹងធ្វើការអ្វី ចូរពិគ្រោះប្រឹក្សានឹងជីវ័យហើយនឹងទៀវជៀវជា ធំ កូនកុំប្រមាទត្រូវឲ្យដឹងសេចក្ដីធ្ងន់ស្រាលខុសត្រូវ កុំប្រកាន់ទិដ្ឋិមានះ អាងខ្លួនជាធំ ត្រូវតែនិយមរាប់អានអ្នកតូច ដូចជាជីវ័យនឹងទៀវលៀវក៏ ត្រូវកូនធ្វើសេចក្ដីគារវៈគោរពខ្លាចអ្នកទាំង២ជាទីគ្រូអាចារ្យធំ កុំគិតធ្វើការ អ្វីសម្រេចតែនឹងគំនិតរបស់ខ្លួនម្នាក់ឯងឡើយ មួយទៀតនាងនឹកកូនថៃ ប្អូនម៉ែ ដែលជាម្ដាយចុង នឹងម្ដាយមីងកូននោះ បើម៉ែស្លាប់ទៅកូនក៏ត្រូវ គោរពប្រតិបត្តិគោរពខ្លាចកុំបើស្មើសមើលងាយ ត្រូវទុកដាក់ខ្លួនជាកូននឹង ម្ដាយបង្កើតដូចម៉ែនេះឯងដែរ មួយទៀតនាងស៊ិនហ៊ួយិនជាប្អូនរួមបិតា ជាមួយនឹងកូននោះ វាក៏នៅក្រមុំ ត្រូវកូនខំគិតចាំមើលរក្សាឲ្យជាប្រក្រតី បើប្រសិនជានឹងឲ្យមានស្វាមី ក៏ត្រូវឲ្យកូនពិគ្រោះសេនាអ្នកដែលមាន សតិបញ្ញាក្សត្រត្រកូលឲ្យគួរសមសមលើកឲ្យជាភរិយាគេចុះ លុះនាង នឹហ៊ួយិនផ្ដាំស៊ិនគួនអស់ហើយ ក៏ទទួលមរណៈកាលកន្លងគណៈនោះ ស៊ិនគួនក៏តាក់តែងរៀបចំការសព តាមទំលាប់ប្រវេណីជាទីរុងរឿងហើយ ហែទៅបញ្ចុះនៅទីគួរសម ។

(នៅមានត)

# រឿង នាយឆ្មា

## លោក លាង-ហាប់-អាន ប្រែរៀបរៀង

មានសេចក្តីដំណាលថា ក្នុងកាលពីព្រេងនាយ មានបុរសកំសត់ទុគ៌តម្នាក់ នៅពេលមុនអស់សង្ខារ បានចែកទ្រព្យខ្លួនដល់បុត្របីនាក់ ។ បុត្រច្បងគាត់បានប្រគល់ឲ្យត្បាល់កិនមួយ, បុត្របន្ទាប់ឲ្យសត្វលា ១, ចំណែកបុត្រពៅ បានចែកឲ្យឆ្មាមួយ ។

លុះបានទទួលកេរ្តិ៍មត៌កពីបិតារៀងខ្លួនហើយ បុត្រពៅតែងមានសេចក្តីប្រណៃទនឹងចង ៗ ជាប្រក្រតី ហើយតែងពោលថា "ឱ! បងទាំងពីរ គេស្រុះស្រួលគ្នារកស៊ី គេនឹងទទួលផលប្រសើរចំពោះកេរ្តិ៍ឧត្តមនេះ ចំណែករូបខ្ញុំបើមានតែឆ្មាមួយយ៉ាងនេះ តើនឹងយកទៅរកស៊ីចិញ្ចឹមជីវិតបានឬទេ?" ។

បានឮសេចក្តីពោលជាពាក្យកញ្ញយរបស់ម្ចាស់យ៉ាងនេះ ឆ្មាដែលមានប្រាជ្ញាឈ្លាសវៃ ក៏តបដោយវាចាដ៏ទន់ភ្លន់ទៅម្ចាស់ថា "សូមលោកម្ចាស់កុំប្រណែន លោកម្ចាស់ដេរស្បោងឲ្យខ្ញុំមួយមក ហើយកាត់ស្បែកជើងមួយសម្រាប់យ៉ាងជាប់ ដើម្បីការពារទីនបន្លា ជាបំផុតលោកម្ចាស់មុខជានឹងបានឃើញច្បាស់ នូវផលដ៏ឧត្តមនៃកេរ្តិ៍ ដែលបិតាលោកម្ចាស់ប្រគល់ជូននេះជាប្រាកដ" ។

ដោយសេចក្តីអន្ទររបស់ខ្លាជារឿយ ៗ នាយបុរសជាម្ចាស់ក៏ដេរស្បោងយ៉ាងល្អ ទាំងកាត់ស្បែកជើងមួយគូយ៉ាងជាប់ប្រគល់ឱ្យខ្លា ៗ

បានជួបបំណងហើយ នាយខ្លាតាំងពាក់ស្បែកជើង នៅជើងក្រោយទាំងពីរយ៉ាងជំនាញ ទាញស្បោងយកមកពាក់នៅក ហើយជើងខាងមុខប្រវាំចាប់ខ្សែយ៉ាងជាប់ ក្រោកឈរត្រដុប ដើរត្រដោះទៅក្នុងព្រៃសម្បូណ៌ទៅដោយទន្សាយ ៗ ដល់កន្លែងដ៏សមគួរហើយ នាយខ្លាតាំងឈប់ស្រាយស្បោងពីក បើកមាត់យ៉ាងធំ ហើយរត់ទៅបោចប្រមូលស្មៅខ្ចីយ៉ាងស្រស់ ទាំងត្រកួនដ៏ខៀវខ្ចីល្អ លូកញាត់បញ្ចេញស្លឹកមកក្រៅ ៗ តមក, នាយខ្លាតាំងឃ្លាំចាំមើលទន្សាយ ដែលអត់ឃ្លាន រត់ប្រវាត់ទាំងចូលស៊ីស្មៅត្រកួនក្នុងស្បោង នាយខ្លាទាំងស្ទុះទៅសង្គ្រប់ចាប់ ៗ

គ្រាន់តែប្រះខ្លួនដេកក្លាម មានទន្សាយអត់ឃ្លានមួយស្ទាត់ខាងការលួច ឃើញត្រកួនខ្ចីនៅមាត់ស្បោង ក៏ចូលទៅកកេរស៊ី រហូតដល់ទៅក្បាលខ្លួនបាត់ទៅខាងក្នុង ៗ បានដៃក្លាម, នាយខ្លាស្ទុះក្តិតរូតខ្សែខ្ទាប់ ៗ ទន្សាយជាប់ជុចបំរាសព្រួសប្រាស នៅក្នុងស្បោង ៗ នាយខ្លាតាំងបញ្ចេញបុទ្ធិប្រហារទន្សាយគ្មានបង្អង់ដៃ ៗ

នាយខ្លាអរណាស់ ក៏តាំងប្រកទន្សាយទៅក្នុងស្បោងស្រេច, ពាក់មកលើ-ក ហើយដើរដំរង់ទៅព្រះរាជដំណាក់ព្រះមហាក្សត្រ ក្នុងនគរនោះ ដើម្បីសូមផ្ញើអ្នកយាមចូលទៅជួបគាល់ព្រះរាជា ៗ អ្នកយាមក៏អនុញ្ញាត

នាំនាយឆ្មាទៅគាល់ព្រះមហារាជ ក្នុងព្រះរាជមន្ទីរ ។ នៅចំពោះព្រះភក្ត្រ, នាយឆ្មាតាំងលុតជង្គង់ថ្វាយបង្គំផងអញ្ជលីតាមទំនៀម ហើយក្រាបទូលថា :

«បពិត្រព្រះករុណាដ៏មានបុណ្យ នេះគឺជាទន្សាយរបស់លោកចុកញ៉ាមហាបុរស ជាម្ចាស់របស់ទូលព្រះបង្គំជាខ្ញុំ ដែលនៅឯនាយទុំ៖ បានតម្រូវទៅទូលព្រះបង្គំជាខ្ញុំ ឲ្យនាំយកមកថ្វាយព្រះអង្គ ដោយគោរពដ៏ក្រៃ-លែង» ។ ខាងព្រះរាជតំណែងផែនខេត្ត ព្រះរាជាទ្រង់ត្រាស់ទៅនាយឆ្មាថា ហៃបុគ្គលស្លូតសរ ចូរឯងនាំសេចក្តីគោរពដ៏ខ្ពង់ខ្ពស់របស់យើងទៅជូនលោកចុកញ៉ាឯងដោយមេត្រី» ។

ក្នុងកាលមួយ នាយឆ្មាចូលទៅដេកលម្ហែ ក្នុងជ្រុកស្រូវ ហើយការស្ទាក់ចាំចាប់កណ្ដុរធំ ។ បន្តិចមក ខាងក្រោយមានកណ្ដុរសាំងដើរចិត្តា ឥឡូវចូលទៅក្នុងស្បោងនោះ ។ នាយឆ្មារួបទាត់ស្បោងជាប់ ហើយនាំឆ្មាទៅព្រះបរមរាជវាំង ថ្វាយព្រះរាជាដោយប្រពៃ ។ ព្រះមហាក្សត្រ ទ្រង់ទទួលយកយ៉ាងស្មោះស្ម័គ្រ ហើយព្រះអង្គទ្រង់បានប្រទានការជប់លៀងនាយឆ្មា នូវក្រយាហារយ៉ាងឈ្ងុយឆ្ងប់ ។

នាយឆ្មាតែងចូលទៅគាល់ព្រះរាជាជាប្រក្រតី ។ ជារឿយៗ នាយឆ្មាតែងនាំសត្វ ដែលខ្លួនចាប់បានទូលថាជារបស់ម្ចាស់ យកទៅថ្វាយព្រះអង្គយ៉ាងគាប់គួរ ។ ថ្ងៃមួយ, នាយឆ្មាបានដំណឹងច្បាស់ថា

ព្រះរាជានឹងទ្រង់យាងចេញទៅប្រថាប់មាត់ស្ទឹង ជាមួយព្រះរាជបុត្រដ៏ឆើតឆាយក្នុងលោក ។ នាយឆ្មាអរណាស់ ហើយនិយាយទៅម្ចាស់ខ្លួនថា "បពិត្រលោកម្ចាស់, បើលោកធ្វើតាមខ្ញុំ លោកនឹងមានលាភប្រសើរ សូមលោកទៅងូតទឹកក្នុងស្ទឹង ត្រង់ទីកន្លែងដែលខ្ញុំបង្ហាញ លោកម្ចាស់នឹងបានទទួលលាភដ៏ប្រពៃ ដែលខ្ញុំនឹងអធិដ្ឋានសុំបួងសួងជូនឲ្យបានសម្រេច ។

នាយប្រុសជាម្ចាស់ ក៏ធ្វើតាមបង្គាប់នាយឆ្មា ដោយពុំមានយល់ការណ៍អ្វីបន្តិចបន្តួចឡើយ ។ ក្នុងពេលដែលព្រះរាជា ព្រមទាំងព្រះរាជបុត្រីយាងទៅដល់មាត់ស្ទឹង នាយប្រុសចុះទៅងូតទឹក ។ នាយឆ្មាតាំងស្រែកអស់ទំហឹងមួយរំពេចថា "ជួយផង! ជួយផង! នុ៎ះទេ លោកចៅពញាមហាបុរសលង់ទឹក" ។ ឮពាក្យនោះឡើងនោះភ្លាម ព្រះរាជាក៏ទ្រង់បើកព្រះភក្ត្រចេញពីរាជរថមក ហើយទ្រង់ស្គាល់ជាក់ជានាយឆ្មាដែលតែងយកសត្វទៅថ្វាយព្រះអង្គ ។ ទ្រង់ក៏ចាត់ឲ្យទាហានស្ទុះចុះទៅជួយស្រង់នាយប្រុសជាម្ចាស់ឆ្មា ។

ក្នុងពេលដែលគេកំពុងតែស្រង់នាយប្រុស, នាយឆ្មាក៏ចូលទៅជិតទៀបព្រះមហាក្សត្រ ក្រាបទូលថា "ក្នុងពេលដែលម្ចាស់ខ្ញុំលង់ទឹកនោះ មានចោរកំណាចមកឆក់សំពត់អាវម្ចាស់ ដែលដាក់លើមាត់ច្រាំងយកទៅ

បាត់ហើយ" ប៉ុន្តែដោយពិត គឺនាយឆ្មានោះដែលយកទៅលាក់ ក្នុងក្រហែងផែនថ្មនោះ ។

ព្រះរាជាទ្រង់មានព្រះរាជឱង្ការ ត្រាស់បង្គាប់ឲ្យនាយឃ្លាំងរត់ទៅព្រះរាជដំណាក់ រើសសំពត់ការដ៏មានដំឡៃ យកមកជូនលោកឧកញ៉ាមហាបុរសផ្លាស់ ។ លះស្លៀកពាក់ស្រេច នាយបុរសក៏ឡើងមកក្រាបបង្គំព្រះរាជា ។ ព្រះអង្គទ្រង់សន្ទនាយ៉ាងស្មោះជាមួយបុរសនោះ ។ ឯព្រះរាជបុត្រីគង់ក្នុងរាជរថ ក៏បេះតែឆ្មៀងព្រះនេត្រទាំងគូ លបមើលនាយបុរសជាញឹកញយ ។ ចំណែកនាយបុរសវិញ ក៏បាលក្ខុយក្តែកញញឹមទៅរកព្រះនាងក្សត្រី ដោយមេត្រី ។

បន្ទាប់មក, ព្រះរាជាក៏ទ្រង់ហៅនាយបុរសឲ្យឡើងទៅលើព្រះរាជរថព្រះអង្គ បកំសាន្ត ទីនីទស្សនាទូទៅទេសភាពផ្សេងៗតាមស្រុកស្រែ ។ មានអំណរណាស់ នាយឆ្មាតាំងរត់នាំដើរយ៉ាងលឿន ពីមុខក្បួនរាជរថទៅ ។ គ្រប់វាលស្រែដែលមានមនុស្សកុះករ កំពុងច្រូតស្រូវ នាយឆ្មាតាំងនិយាយបន្ទាបថា "នែបងប្អូន! បើព្រះរាជាយាងមកដល់ សួរបញ្ជាក់អំពីម្ចាស់ស្រែទាំងនេះ ត្រូវអ្នកពល់គ្នាឆ្លើយស្របទូលព្រះអង្គថា ជាស្រែរបស់លោកឧកញ៉ាមហាបុរស ឮទេ ? បើអ្នកណានាំលោកទទឹង អ្នកនោះឯងនឹងទទួលទោសទណ្ឌកម្មជាពុំខានឡើយ" ។

ដល់ស្រែមួយៗ ព្រះរាជាតែងត្រាស់បញ្ជាក់សួរពីម្ចាស់ស្រែ" ។ ពួក

ម្ចាស់ស្រែ ព្រមទាំងអ្នកច្រូតកាត់ទាំងអស់ ក៏ទូលតបថាជាស្រែរបស់លោកឧកញ៉ាមហាបុរស ។

ព្រះរាជា មានព្រះទ័យអស្ចារ្យពេក, ទ្រង់ត្រាស់សរសើរទៅនាយបុរសថា «ប្រសើរណាស់ លោកមានភោគសម្បត្តិស្ដុកស្ដម្ភណាស់ទេតើ» ។ នាយបុរស លុះឮព្រះរាជបន្ទូលសរសើរយ៉ាងនេះ ក៏បន្ថែមសេចក្ដីថា «បពិត្រព្រះករុណាដ៏មានបុណ្យ ភោគទ្រព្យទាំងនេះផ្ដល់ផលច្រើនជាអនេក ក្នុងមួយឆ្នាំ ៗ» ។

នាយឆ្មាដើរមុខក្បួន តែងបង្ហាប់អ្នកស្រែ ឲ្យឆ្លើយដូចបំណងខ្លួនជានិច្ច ។ ព្រះរាជា ដែលទ្រង់ចង់ជ្រាបហេតុពិត ក៏ចេះតែយាងឆ្ងាយទៅៗ ឥតគណនា ។ ព្រះអង្គទ្រង់ត្រាស់សួរទៅកន្លែងណា ក៏សុទ្ធតែជាស្រែរបស់លោកឧកញ៉ាមហាបុរសទាំងអស់ គ្មានចេះចន្លោះ ។ ព្រះអង្គរឹងរឹតតែស្ញប់ស្ញែងនឹងភោគសម្បត្តិនាយបុរសនេះពន់ពេក ។

ដោយល្បឿនដ៏រហ័សដូចព្រួញ នាយឆ្មាក៏ប្រុតខ្លួនទៅដល់ប្រាង្គប្រាសាទយ៉ាងធំមួយ ដែលជាប្រាសាទយក្សអ្នកមានស្ដុកស្ដម្ភម្នាក់ ។ ឯវាលស្រែចំការទាំងប៉ុន្មាន ដែលឆ្លងកាត់ពីដែនគេ ព្រះរាជាបានទតមកនោះ គឺសុទ្ធតែជាកន្លែងចំណុះរបស់យក្សនេះទាំងអស់ ។ នាយឆ្មាចូលទៅក្នុងប្រាសាទនោះគ្មានញាប់ញ័រអ៊ើបទិចបន្តិចឡើយ ។ នាយយក្សក៏ទទួលនាយឆ្មាអ្នកដំណើរទេសចរយ៉ាងស្រពន់ ។ តមក, នាយឆ្មាក៏

និយាយសរសើរពីគុណភាពនាយយក្ស ។ នាយឆ្មាក៏និយាយតថា "បពិត្រលោកម្ចាស់, ខ្ញុំធ្លាប់ដឹងឮសថា លោកជាអ្នកមានឫទ្ធិ ឥតអ្នកណាស្មើទេ, លោកអាចប្រែក្លាយខ្លួនទៅជាសត្វបានតាមបំណង ទំហំដូចកណ្ដុរជាដើម ខ្ញុំបានជួបជាគេដំណៀតានសោះ ចំពោះពាក្យទាំងនេះ តើជាពិតប្រាកដមែនឬ?" ។ បន្ទាប់ពីឮពាក្យឆ្មាតគួន យក្សក៏និយាយតកាត់ភ្លាមថា ពុំខ្ញៀនោះ ជាការពិតស្រឡះហើយ កុំថាឡើយទៅជាកណ្ដុរ ទោះជាស្រមោចសត្វ ក៏ខ្ញុំក្លាយទៅបានដែរ ។ អ្នកចាំមើលចុះ ខ្ញុំនឹងប្រែក្លាយទៅជាកណ្ដុរភ្លាម ?" ។ ថាហើយ, យក្សតាំងពេញសិល្បះប្រែក្លាយខ្លួនទៅជាកូនកណ្ដុរក្រហមមួយរត់ទៅ ។ លោតលើដីកញ្ច្រោល ។ បានឱកាសភ្លាម នាយឆ្មាហក់វៃខាំកូនកណ្ដុរនោះនៅតែមួយក៏ត់ទៅដល់គនីនោះ ។ យក្សសាបសិល្ប ក៏រលាយខ្លួនសូន្យនៅក្នុងពោះឆ្មានោះទៅ ។

បន្ទាប់មក, ក្បួនព្រះរាជរថព្រះមហាក្សត្រ ក៏ហែមកដល់ទីនោះ ។ នាយឆ្មាឮស្សូរសេះក៏ស្ទុះចេញពីប្រាសាទមកទទួលព្រះរាជាភ្លាម ។ នាយឆ្មាទូលថា "បពិត្រព្រះករុណាដ៏មានជោគ ឥឡូវ ដល់មកប្រាសាទលោកឧកញ៉ាម្ចាស់ទូលព្រះបង្គំជាខ្ញុំហើយ សូមព្រះអង្គទ្រង់មេត្តាស្ដេចយាងចូលទៅក្នុងសាលលេង" ។ រីឯតែស្មែន ព្រះរាជាទៅជាលាន់ព្រះឱស្ឋថា "យីអើ! លោកឧកញ៉ាមហាបុរស ជាអ្នកមានសុភសម្ព

ណាស់ហ្ន៎ ! ” ៗ តមក, ព្រះអង្គក៏ត្រាស់ឲ្យគង់ទំពចូលទៅក្រសាលលេង នៅក្នុងបរិវេណប្រាសាទនោះ ៗ

នាយបុរសក៏ចុះពីលើរាជរថ ហុចដៃទៅឲ្យនាងក្សត្រីកាន់ ហើយក៏នាំព្រះរាជាចូលទៅក្នុងបន្ទប់មួយធំទូលាយ ដែលមានភាជន៍មាសរៀបសុទ្ធសឹងតែម្ហូបឈ្ងុយឈ្ងប់ ដែលយករៀបទុកទីងបរិភោគ ៗ ព្រះរាជាទ្រង់មានព្រះអំណររកអ្វីប្រៀបផ្ទឹមគ្មាន ៗ ព្រះអង្គឆ្មៀងព្រះនេត្រាមើលទៅសម្បត្តិទ្រព្យក្នុងប្រាសាទ មានសុទ្ធសឹងតែមាស-ប្រាក់-ពេជ្រ-ត្បូងដ៏មានដំឡៃ ៗ ព្រះរាជាទ្រង់ជោគទៅក្នុងសេចក្ដីស្ញើច ក៏ទ្រង់ត្រាស់ទៅនាយបុរសថា “លោក ! ខ្ញុំជឿជាក់ហើយថា លោកជាអ្នកមហាសេដ្ឋីធំមែន ! ខ្ញុំទុកលោកជាព្រះជីតុបតិរបស់ខ្ញុំ ! ឥឡូវនេះ ខ្ញុំលើកព្រះរាជបុត្រីខ្ញុំជូនលោកធ្វើជាមហេសី ដើម្បីជាតំណាងនៃសេចក្ដីរាប់អានរបស់ខ្ញុំ!” ៗ មានអំណរណាស់, ដូចជាបានទៅកើតឋានសួគ៌ ទីដែលជោគជាំទៅដោយសេចក្ដីស្នេហាពេញចិត្ត, នាយបុរសឱនកាយទទួលលាភ ចំពោះព្រះភក្ត្រព្រះមហារាជ ព្រមទាំងទទួលធ្វើជាបុត្រប្រសារបស់ព្រះអង្គ ដោយស្វាមីភក្តិ ៗ តមក, ព្រះមហាក្សត្រក៏រៀបអភិសេកបុត្រីនឹងនាយបុរសនោះ ហើយទ្រង់ក៏ប្រគល់រាជសម្បត្តិឲ្យនាយបុរសគ្រងជំនួសព្រះអង្គ ៗ ចំណែកនាយឆ្មាក៏បានឡើងឋានន្តរស័ក្តិជានាម៉ឺនធំមួយ ៗ តពីនោះមក, នាយ

ឆ្មាលែងចាប់កណ្ដុរ ទីងសត្វឯទៀតបរិភោគ ជាអាហារទៀតហើយ ។ នាយឆ្មាតែងមានអ្នកបំរើធ្វើ-ស្ដាត្នាខបន្ទោះ ។

ជាអវសាន, នាយបុរសភ្ញាក់ខ្លួនពិចារណាឃើញច្បាស់នូវសេចក្ដីគិតខុសរបស់ខ្លួនកាលជានមុន ។ នាយបុរសបញ្ញាក់ខ្លួនឯងថា «ក្ដីអាករមាតាបិតា ជាទ្រព្យឧត្តមត្រជាក់ត្រជំ គួរបុត្រធីតាទទួលយក ហើយគេក្យឲ្យគន់រង់កុំឲ្យខកចិត្តឲ្យសោះ» ។

ចប់ ។

## និគមវចនៈ

មាតាបិតាអាសូរបុត្រ　　ចែកក្ដីបរិសុទ្ធទុកឲ្យកូន
ក្ដីនោះបិតថេរពុំសោះសូន្យ　　ជួយជូនឲ្យបានក្ដីសុខា ។
វិញទ្រព្យក្ដីម្ដាយឪពុក　　ចែកទុកឲ្យកូនពលរូបា
ទោះបីតាមចោកឬថ្វីថា　　គួរកូនរក្សាដោយស្មោះស្មាន ។
ឯកូនវៀងនេះដូចកូនពៅ　　បានឆ្មាមួយទៅកំដរប្រាណ
ឆ្មានោះជាក្ដីគាប់កល្យាណ　　ជួយឲ្យម្ចាស់បានចំរើនសុខសម្ត ។
ម្ចាស់បានជាធំពេកកន្ទង　　លើសជនជាបរិយាងឧត្តម
ដោយក្ដីត្រជាក់ជួយឧបត្ថម្ភ　　ឲ្យបានជាធំក្នុងលោកិយ ។

## ផ្នែកកំណត់និងប្រវត្តិការណ៍

# អនុសិរិប្ចរមហាសន្និបាតមន្ត្រីសង្ឃលើកទី ១៥ ឆ្នាំ ១៩៥៩

លោក ស្រី-អ៊ូ រៀបរៀង

កាលពីថ្ងៃសៅរ៍ ១៥ កើត ខែបុស្ស ឆ្នាំចសំរិទ្ធិស័ក ព.ស ២៥០១ (២៤-១-៥៩) វេលាម៉ោង ១៤ និង ៣០ នាទី នៅវត្តបទុមវតី មានការប្រជុំមន្ត្រីសង្ឃ និងចៅអធិការ ខាងគណៈធម្មយុត្តកងទីក្រុង ក្រោមអធិបតីភាពនៃសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្ត ចំពោះមុខលោក អ៊ុច-វ៉ែន អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ។

ម៉ោង ១៥ មានការប្រជុំមេគណ អនុគណ ខែត្រក្រៅ និងមន្ត្រីសង្ឃ ចៅអធិការ ខាងគណៈមហានិកាយ ក្នុងទីក្រុង នៅមហាកុដិវត្តឧណ្ណាលោម ក្រោមអធិបតីភាពនៃសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ចំពោះមុខលោក អ៊ុច-វ៉ែន អនុរដ្ឋលេខាធិការក្រសួងធម្មការ ។

លោក អ៊ុច-វ៉ែន បានថ្លែងសុន្ទរកថាមួយដ៏ពិរោះពិសា ពណ៌នាអំពីកិច្ចសិក្សាព្រះពុទ្ធសាសនា និងវិធីពង្រីកការសិក្សាព្រះពុទ្ធសាសនាឲ្យរីតតែចំរើនឡើង ។

បន្ទាប់មក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បានលើកយកបញ្ហាខាងកិច្ចប្រតិបត្តិធម៌វិន័យ ជាច្រើនយ៉ាងមកដោះស្រាយ ទាំងបានធ្វើការអប់រំព្រះសង្ឃទាំងឡាយ ដោយមានថេរដីកាថា អនុសំវច្ឆរមហាសន្និបាតនេះ អាចនាំឲ្យព្រះសង្ឃទាំងឡាយមានសាមគ្គីធម៌កាន់តែមុតមាំឡើង ដោយបានធ្វើឧបោសថកម្មរួមជាមួយព្រះសង្ឃនាយករបស់ខ្លួន ។

ថ្ងៃអាទិត្យ១ កើត ខែបុស្ស (២៩-១-៥៩) មានមហាសន្និបាតមន្ត្រីសង្ឃ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃព្រះមហាក្សត្រទាំងពីរព្រះអង្គ និងសម្តេចព្រះឧបយុវរាជ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដូចរៀបរាប់តទៅនេះ :

ម៉ោង ៧ ជួបជុំព្រះសង្ឃទាំងពីរគណៈ; ចំរើនសត្តប្បករណ៍ ឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះព្រះបិតានៅព្រះចេតិយព្រះកែវមរកត ។

ម៉ោង ៧ និង ៣០ នាទី ជួបជុំព្រះសង្ឃទាំងពីរគណៈ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

ម៉ោង ៨ និង ១៥ នាទី លោកចៅ សែនកុសល ប្រធានរដ្ឋសភា លោក សម-ញាណ ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងសមាជិកនៃសភាទាំងពីរ, លោកជា-ឆិនកុក ទេសរដ្ឋមន្ត្រីប្រតិភូនៅទីស្តីការនាយករដ្ឋមន្ត្រី, លោក ផូ-ព្រឿង ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាង

មហាផ្ទៃនិងធម្មការ, ព្រមទាំងសមាជិករដ្ឋាភិបាលខ្លះ ហើយនិងបុគ្គលិកនៅក្រសួងធម្មការ រង់ចាំធ្វើគារវកិច្ចព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះឧបយុវរាជ នៅខាងទ្វារពុទ្ធិក-វិទ្យាល័យព្រះសុរាម្រឹត ។

ម៉ោង ៨ និង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះឧបយុវរាជ ដោយមានឯកឧត្ដមប្រាក់-ព្រាព្រឿង, ឯកឧត្ដម អ៊ូ-ឈឹន, ឯកឧត្ដមទ្រឿង-កាង សមាជិកឧត្ដមប្រឹក្សានៃព្រះមហាក្សត្រ, លោកវរសេនីយត្រី ស-ហោ ជាព្រះរាជអង្គរក្ស, លោក យឹម-ត្រយង់ នាយខុទ្ទកាល័យមន្ទីរព្រះរាជាយុត្តកៈ, លោក វង្ស-សារ៉េន លេខាធិការផ្ទាល់ព្រះអង្គ ព្រមទាំងព្រះរាជបរិពារឯទៀតជាច្រើន បានហែអមព្រះអង្គផង ក៏បានស្ដេចយាងមកដល់ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ ពេលនោះ ក្រុមទាហានរក្សាព្រះអង្គ និងក្រុមភ្លេង បានលើកអាវុធវន្ទានិងបន្លឺទំនងភ្លេងប៉ាលីឡា ថ្វាយជាព្រះកិត្តិយស, បន្ទាប់មក ក្រុមភ្លេងនៃក្រុមទាហានរក្សាព្រះអង្គ ក៏បានបន្លឺទំនងភ្លេងជាតិ (នគររាជ) ថ្វាយគោរពជាព្រះរាជកិត្តិយស ។

ឥស្សរជនដែលទៅរង់ចាំទទួលសំដែងសេចក្ដីគោរព ចំពោះព្រះមហាក្សត្រទាំងពីរព្រះអង្គនៅទីនោះ ក៏បានដង្ហែព្រះអង្គ ចូលទៅគង់ប្រថាប់លើព្រះសុវណ្ណគោជ្ជៈ ក្នុងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្រោយពេលដែលព្រះនរបតីទាំងពីរព្រះអង្គ ទ្រង់សំដែងគារវកិច្ច ចំពោះព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយក ទាំងពីរគណៈជាប្រធានរួចហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ថ្លែងព្រះរាជសុន្ទរកថាទទួលព្រះពរអំណរព្រះស្រីយសទៅកេមន្ត្រីសង្ឃទាំងឡាយ ដែលមានសេចក្តីដូចតទៅនេះ :

## ព្រះរាជសុន្ទរកថា

សូមពិតតុទជីកា ព្រះតេជ-គុណគ្រប់អង្គ ខ្ញុំករុណាមានហឫទ័យរីករាយជាទីបំផុត ដោយបានឃើញព្រះតេជគុណជាច្រើនអង្គ បាននិមន្តមកជួបជុំនៅទីនេះ ។

មហាសន្និបាតមន្ត្រីសង្ឃ ដែលបានធ្វើបន្ទូន ១៩ លើកមកហើយ ដោយគិតទាំងលើកនេះផង មានប្រយោជន៍ដ៏សំខាន់ អាចឱ្យព្រះតេជ-គុណរាល់អង្គ ជ្រាបច្បាស់អំពីព្រឹត្តិការណ៍ខ្លះ ខាងពុទ្ធចក្រនិងខាងអាណាចក្រ ដែលបានកើតឡើងក្នុងបច្ចុប្បន្នសម័យនេះ ។

ខ្ញុំករុណា សូមថ្លែងសេចក្តីសរសើរ ដោយគោរពដ៏ជ្រាលជ្រៅ ចំពោះព្រះសង្ឃ ក្នុងព្រះរាជាណាចក្រខ្មែរទាំងមូល ដែលបានខិតខំព្យាយាមជាប់ជានិច្ច ក្នុងការសិក្សាប្រតិបត្តិធម៌និងវិន័យ តាមដំបូន្មានព្រះសក្យមុនីសម្មាសម្ពុទ្ធបរមគ្រូ ដែលជាទីពឹងពំនាក់របស់សត្វលោកទាំងអស់គ្នា ។

សេចក្តីព្យាយាមបែបនេះ ជាវត្ថុមួយមានដំឡៃថ្លៃថ្លាណាស់ ធ្វើឲ្យព្រះពុទ្ធសាសនា មានពន្លឺស្មើរតែត្រចង់ត្រចះ ពាសពេញលើផ្ទៃប្រទេសយើង ជាហេតុនាំឲ្យអធិករណ៍ដែលមានកើតឡើង ក្នុងភាពខ្លះវិនាសបាត់បង់ទៅវិញ បានដោយស្រួលផង ។

ខ្ញុំករុណា សូមព្រះតេជៈគុណពាក់ព្រះគន្ធ មេត្តារំលឹកដល់ពុកពុទ្ធបរិស័ទ សូមឲ្យកាន់សាមគ្គីធម៌ ឲ្យបានរឹងរឹតតែខ្លាំងខ្លួនទៅទៀត ពីព្រោះសេចក្តីព្រមព្រៀង ជាគុណសម្បត្តិមួយដ៏បវរ អាចធ្វើឲ្យជាតិសាសនានៃព្រះមហាក្សត្រិយ បានចំរើនរុងរឿងជានិច្ច សត្រូវជិតឆ្ងាយក៏ពុំអាចរំលាយឯករាជភាព និងអព្យាក្រឹតភាព របស់យើងឲ្យសាបសូន្យទៅវិញបានឡើយ ។

នៅទីបំផុតនេះ ខ្ញុំករុណាសូមប្រកាសបើកមហាសន្និបាតមន្ត្រីសង្ឃលើកទី ១៥ ហើយសូមវេទនាស័ព្ទសាធុការពរ ប្រគេនចំពោះព្រះតេជៈគុណគ្រប់ព្រះអង្គ ដែលជាវិសេសនាទីជាទីគោរពនៃខ្ញុំករុណា សូមឲ្យបានប្រកបតែនឹងសេចក្តីសុខ សេចក្តីចំរើនគ្រប់ទិវា រាត្រី កុំបីខានឡើយ ។

លុះចប់ព្រះពជសុន្ទរកថានេះហើយ លោកឆ្នុះព្រឿងទេសាជ្ញមន្ត្រីទទួលបន្ទុកខាងមហាផ្ទៃនិងធម្មការ បានឡើងថ្លែងសុន្ទរកថាមួយដែលមានសេចក្តីដូចតទៅនេះ :

# សុន្ទរកថានៃទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងធម្មការ

សូមព្រះតេជៈដ៏កល់លើត្បូង !

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតទាំង ២ ព្រះអង្គ
សូមព្រះរាជទានក្រាបបង្គំទូលសម្តេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ
សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ ទ្រង់ប្រោសព្រះរាជទានអនុញ្ញាត ថ្វាយនូវអំណរដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាធិគុណនៃព្រះករុណាថ្លៃវិសេសទាំងពីរព្រះអង្គ និងសម្តេចជាម្ចាស់ ដែលបានស្តេចយាងជាព្រះរាជាធិបតីភាព ក្នុងឱកាសពិធីអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទី ១៥ សម្រាប់ឆ្នាំ១៩៥៩នេះ ដោយសោមនស្សចេតនាដ៏ឧត្តម និងដោយគោរពជាទីបំផុត ។

សូមទ្រង់ព្រះមេត្តាប្រោស !

ក្នុងវារៈជាដំបូងនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះរាជវរោកាសល្អងធូលីព្រះបាទ ដើម្បីប្រស្រ័យនឹងព្រះថេរានុត្ថេរៈទាំងឡាយមានសម្តេចទាំងពីរព្រះអង្គជាប្រធាន ដែលបាននិមន្តមកប្រមូលប្រជុំក្នុងទីនេះ ដោយបំណងចង់ឲ្យព្រះសង្ឃទាំងឡាយ បានជ្រាបច្បាស់នូវកិច្ចការ

ទាំងពួងខាងពុទ្ធចក្រនឹងអាណាចក្រខ្លះ ។

សូមថ្វាយបង្គំសម្តេចទាំង ២ ព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈជាព្រះរាជាគណៈ មេគណអនុគណទាំងអស់ ដោយគោរព ។

ខ្ញុំព្រះករុណា សូមអំណរគុណ ចំពោះសម្តេច ព្រមទាំងព្រះករុណាគ្រប់ព្រះអង្គយ៉ាងក្រៃលែង ព្រោះការជួបជុំនេះ ទុកជាទស្សនានុត្តរិយៈមួយដ៏ប្រសើរ ជាអានិសង្សនាំឲ្យខ្ញុំព្រះករុណា បានស្គាល់ព្រះភក្ត្រព្រះតេជព្រះគុណគ្រប់ព្រះអង្គ ។

សម្តេច !

ព្រះករុណាគ្រប់ព្រះអង្គ !

ប្រទេសកម្ពុជា មានភ័ព្វល្អណាស់ ដោយមានព្រះពុទ្ធសាសនាប្រតិស្ឋាននៅ ជាសាសនាប្រដៅសត្វ ឲ្យដើរទៅកាន់សេចក្តីស្ងប់ គឺសន្តិភាព ដែលសកលលោកតែងនិយមស្រឡាញ់ពេញចិត្ត ហើយបំពេញសកម្មភាពរបស់ខ្លួន ដើម្បីសន្តិភាព ដូចព្រះករុណាគ្រប់ព្រះអង្គជ្រាបស្រាប់ហើយ ។

ខ្ញុំព្រះករុណាមានសេចក្តីសង្ឃឹមកក់ក្តៅយ៉ាងមាំ ចំពោះព្រះសង្ឃដែលជាសិស្សផ្ទាល់នៃព្រះពុទ្ធបរមគ្រូថា នឹងយកសេចក្តីស្ងប់ជាមាគ៌ានៃសេចក្តីប្រតិបត្តិ តាមគម្រោយនៃព្រះពុទ្ធជាម្ចាស់ ។

ដោយគុណធម៌ដ៏ប្រសើរនេះហើយ បានជាព្រះពុទ្ធសាសនា មានអាយុកាលគង់នៅមកដល់សព្វថ្ងៃនេះ ប្រទេសទាំងឡាយដែលមិនធ្លាប់ជឿកាន់ព្រះពុទ្ធសាសនាពីដើមមក, សព្វថ្ងៃនេះ កាន់តែនិយមកាន់ច្រើនឡើងហើយ ដោយគេបានបង្កើតពុទ្ធសមាគមស្ទើរតែគ្រប់ប្រទេស ដោយគេយល់ច្បាស់ថា ព្រះពុទ្ធសាសនាមានអានុភាពទាញចិត្តមនុស្សឲ្យប្រកាន់យកសន្តិភាពជាគោល នៃសេចក្ដីប្រតិបត្តិគ្រប់ជំពូក គឺលះបង់ការគោយាតបៀតបៀនគ្នាទៅវិញទៅមក ដូចព្រះតេជព្រះគុណបានជ្រាបស្រាប់ហើយ ។

ក្នុងបច្ចុប្បន្នកាលនេះ បើប្រៀបធៀបសាសនសិក្សានិងសេចក្ដីប្រតិបត្តិខាងព្រះពុទ្ធសាសនា ឃើញថា សាសនសិក្សាមានដំណើរលឿនជាងសេចក្ដីប្រតិបត្តិជាច្រើនដង ព្រោះសាសនសិក្សា មានអាគារពុទ្ធិកសិក្សាដុះឡើងគ្រប់ខេត្ត-ស្រុក ក្នុងព្រះរាជាណាចក្រទាំងមូល ហើយសមណសិស្សវិញសោត ក៏មានចំនួនកាន់តែច្រើនឡើងជាលំដាប់រាល់ឆ្នាំ គួរយ៉ាងដូចកាលពីមុន ដែលប្រទេសយើងពុំទាន់បានឯករាជ្យពេញទីនៅឡើយ មានអាគារសិក្សាខាងពុទ្ធិកបឋមសិក្សាចំនួន៤៦៤ខ្នង សមណសិស្សចំនួន ៣ ១៩០ រូប អាគារសិក្សាខាងធម្មវិន័យចំនួន ១ ០៦១ ខ្នង សិស្ស៨ ២៣១រូប ។ ចាប់តាំងពីថ្ងៃទី១១ ខែវិច្ឆិកា ១៩៥៣ ដែលប្រទេសយើងបានទទួលឋានៈជារដ្ឋឯករាជ្យពេញបរិបូណ៌ ដោយព្រះរាជ

បេសកកម្មប្រយុទ្ធ នៃសម្តេចសហជីវិនជាម្ចាស់មកដល់ ខែធ្នូ ឆ្នាំ ១៩៥៨ ឃើញអាគារខាងបឋមសិក្សាចំនួនជិត៦០០ ខ្នង សមណសិស្ស ៣.៣៦៤ រូប ។ ប៉ែកខាងធម្មវិន័យមានអាគារសិក្សាចំនួន ១.១៦៥ ខ្នង សមណ-សិស្សចំនួន ១១.៩១៩ រូប ឃើញថា អាគារសិក្សាចំរើន ១០៧ ខ្នង សមណសិស្សចំនួន ៣.៦៨៨ រូប ។

ចំណែកខាងសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត គឺសាលាបាលីជាន់ខ្ពស់ កាលពីមុនមានសិស្សតែ ១០០ រូប ឥឡូវនេះ មានសិស្សចំនួនជាងមួយរយប្លាយ ឯក្នុងឆ្នាំ ១៩៥៩ នេះ ក្រសួងធម្មការនឹងចាប់បើកបង្រៀនរៀងខែឧសភាខាងមុខ ទៅមហាពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ ដែលទើបនឹងបង្កើតឡើងជាដំបូង នៅប្រទេសកម្ពុជា មានសមណសិស្សចំនួន ៥០ រូប សម្រាប់បំពេញវិជ្ជាជាន់ខ្ពស់ ជាអគ្គការសិក្សាថ្នាក់លើបង្អស់ ប៉ែកខាងព្រះពុទ្ធសាសនា មិនបាច់ទៅបំពេញវិជ្ជានៅប្រទេសក្រៅឡើយ ព្រោះមហាវិទ្យាល័យនេះ អាចផ្តល់ដល់ព្រះសង្ឃនូវវិជ្ជាជាន់ខ្ពស់ តាមបំណងគ្រប់គ្រាន់ហើយ ។

សេចក្តីចំរើនខាងសាសនសិក្សា ដែលបានរៀបរាប់មកនេះខ្ញុំព្រះករុណាជឿជាក់ថា បានកើតឡើងដោយសេចក្តីខ្នះខ្នែងនៃព្រះតេជព្រះគុណគ្រប់ព្រះអង្គ យកព្រះទ័យទុកដាក់បំពេញករណីយកិច្ច តាមសមត្ថភាព តាមផែនការនៃសម្តេចព្រះបិតាឯករាជ្យជាតិ ដែលព្រះអង្គទ្រង់

ដួញព្រះហឫទ័យ បំពេញព្រះរាជករណីយកិច្ច បូជាចំពោះមាតុប្រទេស ជាទីស្នេហានៃព្រះអង្គ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ។

ខ្ញុំព្រះករុណា សូមព្រះតេជព្រះគុណជាមន្ត្រីសង្ឃខេត្រស្រុកគ្រប់ព្រះអង្គ មេត្តាបន្តសេចក្តីព្យាយាមរកមធ្យោបាយយ៉ាងណា ឱ្យបានដំណើរនៃការសិក្សាទាំងសេចក្តីប្រតិបត្តិមានល្បឿនទៅជាមួយគ្នា ព្រោះកិច្ចនេះ ជាភារៈលើព្រះតេជព្រះគុណគ្រប់ព្រះអង្គត្រូវបំពេញជាការចាំបាច់ ។

បពិត្រព្រះករុណាគ្រប់ព្រះអង្គ ! ដែលខ្ញុំព្រះករុណាបានពោលពីល្បឿននៃការសិក្សានិងសេចក្តីប្រតិបត្តិនេះ ដោយចំណង់ចង់ឱ្យព្រះពុទ្ធ-សាសនានៅប្រទេសយើង រីកតែមានកិត្តិនាមល្បីល្បាញជាវិសាលភាព ព្រោះហេតុថា ប្រទេសយើងពិតមែនតែជាប្រទេសតូច មានពលរដ្ឋតិច ប៉ុន្តែ ប្រទេសទាំងឡាយជាពុទ្ធសាសនិកដូចគ្នា បានទទួលស្គាល់ថាជាផ្ទកាន់ព្រះពុទ្ធសាសនា មានសេចក្តីប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ ត្រឹមត្រូវតាមពុទ្ធោវាទ, មានពុទ្ធសាសនិក ៩៩% ដែលមានជំនឿជឿស៊ប់មាំមួន ។

កិត្តិគុណដ៏ប្រពៃនេះ បានកើតឡើង ដោយសារថ្វីព្រះហស្ត នៃសម្តេចព្រះបិតាឯករាជ្យជាតិ ដែលព្រះអង្គទ្រង់បំពេញព្រះរាជបេសកកម្មទាក់ទងជាមួយនឹងប្រទេសឯទៀតដ៏ច្រើន នាំឱ្យបរទេសទទួលស្គាល់ថាប្រទេសមានចក្រទាំងពីរ គឺពុទ្ធចក្រនិងអាណាចក្រ មានដុំរិលទៅស្មើគ្នាតាមគម្រោងមាគ៌ានៃសម្តេចសហាដីវិនជាម្ចាស់ ដែលព្រះអង្គបានត្រាយ

ផ្លូវឲ្យពលរដ្ឋរបស់ព្រះអង្គ ដើរដើរតាមព្រះអង្គ ។

ដើម្បីរកព្រឹត្តិគុណដ៏ថ្លៃថ្នូរនេះ ឲ្យបានឋិតថេរចិរកាលតទៅអនាគត បានដោយប្រពៃនោះ ខ្ញុំព្រះករុណាសូមផ្ញើសេចក្តីសង្ឃឹមទុកចិត្តយ៉ាងមាំ ចំពោះព្រះតេជព្រះគុណជាមេគណអនុគណគ្រប់ខេត្ត-ស្រុកទាំងអស់ ថានឹងខំយកព្រះទ័យទុកដាក់ ដឹកនាំលោកគ្រូចៅអធិការគ្រូសូត្រ ទូទៅអស់ភិក្ខុ-សាមណេរគ្រប់រូប ឲ្យប្រតិបត្តិគោរពច្បាប់ព្រះពុទ្ធសាសនានិងគោរពច្បាប់អាណាចក្រ ដោយព្រះទ័យស្មោះស្ម័គ្រ ចេះប្រើសិទ្ធិនិងសេរីភាពឋិតនៅក្នុងក្របខ័ណ្ឌច្បាប់, គ្រង់ណាដែលច្បាប់សម្រេចហើយ ត្រូវតែប្រតិបត្តិតាម ព្រោះការគោរពច្បាប់ជាករណីយកិច្ចនៃពលរដ្ឋគ្រប់រូបត្រូវបំពេញ ។

អាស្រ័យហេតុនេះ សូមព្រះករុណាគ្រប់ព្រះអង្គជាមន្ត្រីសង្ឃ ពន្យល់ពុទ្ធបរិស័ទឲ្យយល់ច្បាស់នូវសិទ្ធិនិងសេរីភាពនិងករណីយកិច្ច ដែលត្រូវប្រើ ត្រូវប្រតិបត្តិ ។ .

មួយទៀត ខ្ញុំព្រះករុណាសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីនាំយកសេចក្តីអំណរអរគុណ របស់ព្រះរាជរដ្ឋាភិបាលនិងសេចក្តីសរសើរប្រគេនដល់ព្រះអង្គ ដែលជាសិស្សានុសិស្ស ព្រមទាំងសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ដែលបានបំពេញការហាត់កម្មលើកដីសង់ពុទ្ធិកមហាវិទ្យាល័យទាំងប៉ុន្មាន ដែលបានចង្អុលឲ្យឃើញថា ការដឹកនាំរបស់សម្តេចព្រះបិតាឯកពជ្យ នោះទៅរកឧត្តមប្រយោជន៍ជូនជាតិនេះ បានសាយដល់ព្រះភិក្ខុ

សង្ឃដូចជាដល់គ្រហស្ថបោះ ដែលជាប្រាក់ ជាទ្រព្យ ជាទំនប់ទប់ទឹក ជាផ្លូវ ជាអណ្តូង ជាផ្ទះ ។ល។

ឯការហត្ថកម្ម គឺការជីកស្រះ អណ្តូង ទំនប់ទប់ទឹក ធ្វើថ្នល់ ធ្វើផ្លូវលំ ធ្វើផ្ទះសាលារៀន ។ល។ ចំរើនបានដល់យ៉ាងណានោះ ព្រះរាជាគណៈ ៥-៦ ព្រះអង្គ ដែលបាននិមន្តទៅទស្សនាក្នុងពេលថ្មីៗនេះ ព្រះអង្គទត ឃើញច្បាស់នឹងព្រះនេត្រស្រាប់ហើយ ។

ទីបំផុតនៃសុន្ទរកថានេះ ទូលព្រះបង្គំ សូមបង្អោនព្រះរាជកុសលដ៏ថ្លៃថ្លានេះ ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ សូមស្ថិតនៅជាសុខ ក្នុងព្រះសិរីរាជសម្បត្តិ អស់កាលជាយូរអង្វែងតទៅ ព្រមទាំងសូមថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះឧបយុវរាជ សូមព្រះអង្គប្រកបដោយសិរីសួស្តីជ័យមង្គលគ្រប់ប្រការ ឈ្នះមារសត្រូវទាំង ៨ ទិស កំចាត់បង់នូវឧបសគ្គគ្រប់ប្រការ កុំឲ្យកើតមានចំពោះព្រះអង្គ ដើម្បីទ្រង់ដឹកនាំនាវាកម្ពុជា ឲ្យបានដល់ត្រើយពោលគឺវឌ្ឍនភាព ដូចការប្រទេសទាំងឡាយជានិច្ចនិរន្តរ៍តអង្វែងទៅ ។

លុះចប់សុន្ទរកថានេះហើយ ទើបព្រះសាសនសិរ៉ា គាង់.អែល អនុគណស្រុកមុខកំពូល (កណ្តាល) តំណាងមន្ត្រីសង្ឃទាំងអស់ ឡើងថ្វាយសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ :

# សុន្ទរកថាតំណាងមន្ត្រីសង្ឃ

អាត្មាភាព សូមថ្វាយព្រះពរព្រះករុណា ជាអម្ចាស់ជីវិតទាំងពីរព្រះអង្គ នឹងសម្តេចព្រះឧបយុវរាជព្រះបិតាឯករាជ្យជាតិ

សូមទ្រង់ជ្រាប ។

អាត្មាភាព ជាតំណាងព្រះរាជាគណៈ ឋានានុក្រម-មេគណ-អនុគណ គ្រប់ស្រុកខេត្ត ក្នុងព្រះរាជាណាចក្រ សូមព្រះរាជទានព្រះរាជវរោកាស សូមថ្លែងសេចក្តីដោយសង្ខេប តបចំពោះសេចក្តីថ្លែងការណ៍នៃលោកអ្នកឧកញ៉ាទេសរដ្ឋមន្ត្រី ទទួលបន្ទុកខាងក្រសួងធម្មការ នឹងសាសនសិក្សាធិការ ដែលបានថ្លែងហើយអម្បាញ់មិញនេះ ។

ដោយបានស្តាប់សេចក្តី អំពីសាសនសិក្សាដែលថ្លែងថា មានការលូតលាស់ចំរើនតាមលំដាប់កាល មានល្បឿនលឿនជាងពីក្នុងកាលមុន ឯខាងការប្រតិបត្តិវិញ មានដំណើរទន់ខ្សោយថយចុះពុំស្មើគ្នានឹងល្បឿននៃសាសនសិក្សា ។

ការនេះយើងឃើញថា មុខគួរឲ្យរីករាយខ្លះ មុខគួរឲ្យព្រួយបារម្ភខ្លះដែរ ។ ការប្រតិបត្តិតាមព្រះពុទ្ធសាសនា ឲ្យសមតាមព្រះបរមពុទ្ធានុញ្ញាតនោះ ឃើញថាទន់ខ្សោយខ្លះដែរ តែនឹងទុកថាទន់ខ្សោយពេកក៏ពុំបាន បើយើងប្រៀបធៀបសេចក្តីប្រតិបត្តិព្រះសង្ឃយើង នឹងព្រះសង្ឃប្រទេសដទៃ ។ ពេលនេះ ការសិក្សាយើងក៏ពុំនឹងធ្វើដំណើរឈានទៅមុខល្អហើយ

គួរឲ្យយើងសង្ឃឹមទុកជាមុនថា តទៅ សេចក្ដីប្រតិបត្តិក៏នឹងដើរទៅតាមក្រោយជាលំដាប់ពុំខាន ព្រោះកាលបើបរិយត្តិបានល្អណាស់ហើយ ព្រះសង្ឃមានការចេះដឹងប្រពៃហើយ សេចក្ដីប្រតិបត្តិ ក៏នឹងកើតមានជាលំដាប់ពុំខាន ដោយសង្ឃឹមទៅលើព្រះរាជរដ្ឋាភិបាល ដែលមានព្រះមហាក្សត្រទាំងពីរព្រះអង្គ និងសម្ដេចព្រះបិតាឯករាជ្យជាតិជាប្រមុខ ដែលទ្រង់កំពុងតែរៀបចំសព្វថ្ងៃនេះ ។

អាត្មាភាព សូមថ្លែងសេចក្ដីអំណរគុណគណៈសង្ឃ ដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

ក្នុងអវសានកថានេះ អាត្មាភាពសូមលើកកុសលរាសី ដែលគណៈសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល បានអប់រំ និងប្រព្រឹត្តតាមព្រះបរមពុទ្ធោវាទ គ្រប់ខណៈនោះដែលជាកុសលដ៏ឧត្តមទាំងប៉ុន្មានប្រមូលផ្ដុំជាព្រះរាជកុសល ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតទាំងពីរព្រះអង្គ និងសម្ដេចព្រះឧបយុវរាជ ព្រះបិតាឯករាជ្យជាតិ សូមព្រះអង្គប្រកបដោយឥដ្ឋមនុញ្ញផលវិបុលសុខ និងសុភមង្គលគ្រប់ប្រការ ក្នុងព្រះសិរីរាជ-សម្បត្តិនិងព្រះរាជករណីយកិច្ចដ៏ប្រសើរ ដែលជាដំណើរញ៉ាំងប្រទេសជាតិមាតុភូមិ ឲ្យលូតលាស់ចំរុងចំរើន ឈ្នះអស់បច្ចាមិត្រជិតឆ្ងាយ សូមកុំបីមានឧបទ្រវហេតុអ្វីមួយ ចូលមកជ្រៀតជ្រែកបែកញែកនិងព្រះបេស្ដាបានឡើយ ។

មួយទៀត សូមបាវចនាគឺជាតិសាសនាព្រះមហាក្សត្រ ទាំងបីម៉ាត់នេះ ឋិតនៅជាស្ថាពរបវរសួស្តីជានិរន្តរ៍ ក្នុងព្រះរាជអាណាចក្រកម្ពុជា ឲ្យបានអស់កាលយូរអង្វែងតរៀងទៅ ឥតបីគណនា ។

លុះចប់ព្រះសុន្ទរកថានេះហើយ ព្រះសង្ឃទាំងឡាយ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន បានសូត្រជ្រាយធម៌ជយន្តោ ថ្វាយសព្ទសាធុការពរ ចំពោះព្រះនរបតីទាំងពីរព្រះអង្គ និងសម្តេចព្រះបិតាឯករាជ្យជាតិ ។

ក្រោយដែលព្រះសង្ឃសូត្រជ្រាយធម៌ជយន្តោនោះមក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ ទ្រង់ស្តេចយាងប្រាស្រ័យស្និទ្ធស្នាលជាមួយព្រះសង្ឃ អស់រយៈវេលាយ៉ាងយូរ ទើបស្តេចថ្វាយបង្គំលាព្រះសង្ឃ យាងត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារដង្ហែតាមព្រះអង្គ ដូចកាលដែលស្តេចយាងមកដល់ ។

លុះព្រះករុណាទាំងពីរព្រះអង្គ ទ្រង់ស្តេចយាងទៅព្រះបរមរាជវាំងហើយ សម្តេចព្រះឧបយុវរាជនាយករដ្ឋមន្ត្រី ទ្រង់សព្វព្រះរាជហឫទ័យ ថ្លែងព្រះរាជសន្ទរកថាមួយ ស្តីអំពីស្ថានការណ៍ក្នុងប្រទេស ក្រៅប្រទេស នាបច្ចុប្បន្នសម័យនេះ ប្រគេនព្រះសង្ឃ និងឥស្សរជនទាំងឡាយស្តាប់ ដែលមានសេចក្តីយ៉ាងក្បោះក្បាយ អស់រយៈវេលាជាង ១ ម៉ោងទើបចប់ ។

នៅទីបំផុត សម្តេចព្រះបិតាឯករាជ្យជាតិ ទ្រង់ផ្តាំចំពោះព្រះសង្ឃ

ទាំងឡាយ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធានជា ការស្ថាបនាអាគារសិក្សា ចាប់តាំងពីថ្នាក់តូចរហូតដល់ថ្នាក់ទី ៦ ទើបសព្វថ្ងៃនេះ មានសន្ទុះលឿនណាស់ទៅហើយ ដោយសេចក្តីប្រឹងប្រែងរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទ ៗ ការកសាងទាំងនេះឈ្មោះថាជាការគាប់ប្រសើរណាស់ ប៉ុន្តែ ដោយថវិកាជាតិយើងទន់ខ្សោយ ព្រមទាំងពិបាកនឹងរកបុគ្គលិកសម្រាប់បង្រៀនតាមថ្នាក់នោះផង សូមព្រះសង្ឃនិងពុទ្ធបរិស័ទបន្ថយការស្ថាបនានោះសិន ៗ ជាពិសេស សូមព្រះករុណាគ្រប់អង្គ មេត្តាជួយពន្យល់ណែនាំពួកពុទ្ធបរិស័ទឲ្យខំប្រឹងប្រែងប្រកបរបរកសិកម្មឲ្យបានពេញទំហឹងឡើង ដើម្បីឲ្យមានផលិតផលបរិបូណ៌ យកទៅលក់នៅប្រទេសក្រៅ កាលបើយើងសម្បូណ៌ផលិតផលចេញទៅប្រទេសក្រៅហើយ យើងនឹងសម្បូណ៌ ហើយយើងអាចនឹងពង្រីកកិច្ចសិក្សាបានដោយងាយជាប្រាកដ ៗល ៗ

លុះចប់ព្រះសង្កថានេះហើយ ព្រះសង្ឃទាំងឡាយ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន បានសូត្រថ្វាយពុទ្ធជ័យមង្គលប្រសិទ្ធិស័ព្ទសាធុការពរថ្វាយ ចំពោះសម្តេចព្រះបិតាឯករាជ្យជាតិ ជាកិច្ចបញ្ចប់មហាសន្និបាត នៅពេលព្រឹកនោះ ៗ បន្ទាប់ពីនោះមក សម្តេចទ្រង់ថ្វាយបង្គំលាព្រះសង្ឃ យាងត្រឡប់ទៅព្រះរាជដំណាក់វិញ ៗ

ម៉ោង ១០.៣០ ប្រគេនភត្តកាន់ព្រះបរមនាមនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ដល់ព្រះសង្ឃចំពោះមុខទេសរដ្ឋមន្រ្តីទទួលបន្ទុកខាងក្រសួងធម្មការ ព្រមទាំងមន្ត្រីក្រសួងធម្មការ ឧបាសកឧបាសិកា នៅបរិវេណឈាបនដ្ឋានវត្តឧណ្ណាលោម ។

# របៀបវារៈនៃការប្រជុំព្រះសង្ឃ

របៀបវារៈនៃការប្រជុំព្រះសង្ឃ ដែលធ្វើនៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រោមអធិបតីភាពនៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ នៅថ្ងៃទី ២៥ មេសា ឆ្នាំ ១៩៥៩ មានសេចក្តីដូចតទៅនេះ :

ម៉ោង ១៤ សម្តេចព្រះសង្ឃនាយកនិងព្រះសង្ឃទាំងឡាយនិមន្តមកដល់។

ម៉ោង ១៤.១០ ការបើកកិច្ចប្រជុំ ដោយសម្តេចព្រះសង្ឃនាយក ។

ម៉ោង ១៤ ៣០ សន្និសីទ អំពីព្រះពុទ្ធសាសនាដែលមានការទាក់ទងនឹងកិច្ចសិក្សា ក្នុងប្រទេស ដោយព្រះពោធិវង្ស ។

ម៉ោង ១៥.៣០ សន្និសីទ អំពីការត្រួតត្រាទូទៅ នៃសាលាពុទ្ធិក-បឋមសិក្សា ដោយលោក យឹម-វ៉ែនទីប្រឹក្សាបច្ចេកទេស ។

ម៉ោង ១៥-៣០ ការប្រគេនភេសជ្ជៈដល់ព្រះសង្ឃ ។

ម៉ោង ១៦.៤០ សន្និសីទ អំពីឧត្តមសិក្សា ដោយលោក អៀង-គុនសាគី អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ ។

X XX

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( តមក )

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

**អច្ឆា** បុព្វបទ សំដៅ...។ - *គមិ* ទៅត្រង់ ។ - *ចរ* ឬ - *ធ* ត្រង់ទៅ។ - *ប្រូ* ដើរមកជិត ។ - *យា* ទៅជិត ។ - *រុច* អញ្ជើញ ។ - *វទ* សំពះ ។

**អច្ឆិទ្រ** គុ. ដែលមិនដាច់ពីគ្នា, ដាច់រដឹក, ដែលនៅល្អ ។ អច្ឆិទ្រមិ, អច្ឆិទ្រេណ, យ៉ាងរដឹក, ឥតដាច់គ្នា ។

**អច្ឆរិកា អច្ឆរី** ស្ត្រី. ច្រក, កង់ ។

**អច្ឆេទ្យ** គុ. ដែលមិនគប្បីកាត់ចេញបាន ។

**អច្យុត** គុ. ដែលមិនច្យុត, ដែលមិនកម្រើក, មាំមួន, រឹតថេរ ដែលមិស្លាប់។ បុំ. ព្រះវិស្ណុ, ព្រះក្រឹស្ណ; ឈ្មោះទេពតាផ្សេង ៗ ។ អច្យុតាបុរស បុំ. ឈ្មោះអ្នកចម្បាំង ។

**អជិ** មើលពាក្យ អញ្ជ ។ - *អជ* : អជតិ-តេ, ( ខាងវេទ ) កិរិយានាំ ។

**អជ** បុំ ពពែ ។ អជា ស្ត្រី. ពពែញី ។ - *គរ* បុំ. ពស់ថ្លាន់ ។ - *មីឍ* ឬ *មីឍ្ហ* បុំ. ឈ្មោះយុធិស្ឋិរ; ឈ្មោះឝ្មូតរាប្រ្ត; ឈ្មោះជនផ្សេង ៗ ទៀត ។ - *ប* បុំ. អ្នកគង្វាលពពែ ។ - *បាល* បុំ. អ្នកគង្វាលពពែ ។ - *មុខី* ស្ត្រី. ឈ្មោះរាក្សសី ។ *អជ-គល-ស្តន* បុំ. ដូកនៅកនៃពពែញី ។ - *អជាវិ* បុំ. ពហុ ពពែឬចៀម ។ *អជា-វិក* នបុំ., អជាវិកា ស្ត្រី. ពហុ. ប្រែដូចគ្នានឹងអជាវិ ។ *អជៃកបទ*, បុំ. នាមនៃព្រះរាជា ។

(នៅមានត)